TRAVERSES

លេខ 53
ខែធ្នូ ឆ្នាំ 2023

# អត្តភាព នៅក្នុងខ្សែសង្វាក់តម្លៃ និងការគ្រប់គ្រងគុណភាព

សម្រួលសម្រួលដោយ Paul Belchi ( Iram )




©Paul Belchi

អត្ថបទបោះពុម្ពផ្សាយរបស់កម្មវិធី “គំនិតផ្តួចផ្តើម Groupe initiatives”

Groupe initiatives

ស្នាដៃ និងអត្ថបទបោះពុម្ពផ្សាយលើកនេះរបស់ Traverses ទទួលបាន ការគាំទ្រផ្នែកហិរញ្ញវត្ថុពីទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ ( Agence Française de Developpement - AFD )

In partnership with

RÉPUBLIQUE FRANÇAISE
Liberté
Égalité
Fraternité

AFD
AGENCE FRANÇAISE DE DÉVELOPPEMENT

## អត្ថបទបោះពុម្ពផ្សាយរបស់ TRAVERSES

គោលបំណងនៃអត្ថបទបោះពុម្ពផ្សាយរបស់ Traverses គឺដើម្បីដកស្រង់បទពិសោធន៍សំខាន់ៗជាមេរៀនពីការអនុវត្តរបស់អង្គភាពជាសមាជិកកម្មវិធី "គំនិតផ្តួចផ្តើម Groupe initiatives" ដើម្បីរួមចំណែកដល់ការជជែកពិភាក្សាអំពីយុទ្ធសាស្រ្ត និងវិធីសាស្រ្តនានានៅក្នុងវិស័យសាមគ្គីភាពអន្តរជាតិ។ វិធីសាស្រ្តនេះ គឺផ្អែកលើការផ្លាស់ប្តូរទៅវិញទៅមកនូវការអនុវត្តនៅក្នុងក្របខណ្ឌកម្មវិធី Gi និងនៅថ្ងៃចុះទស្សនកិច្ចសិក្សាដែលបើកចំហចំពោះបណ្តាភាគីពាក់ព័ន្ធនានាមកពីសមាគម វិស័យសាធារណៈ វិស័យសិក្សាធិការ និងវិស័យសាជីវកម្ម។ ស្នាដៃនេះបានដកស្រង់បទពិសោធន៍ពីការអនុវត្តកន្លងមករបស់បណ្តាសមាជិក និងដៃគូរបស់សមាជិក រហូតឈានទៅដល់ការចងក្រងអនុសាសន៍ និងតួនាទីជាសមូហភាព។

# សេចក្តីថ្លែងអំណរគុណ


**ការសម្របសម្រួល៖** Paul Belchi (Iram), Souad Barry *(កម្មវិធីគំនិតផ្តួចផ្តើម Groupe initiatives)*

**គណៈកម្មាធិការដឹកនាំកម្មវិធី និងអ្នកនិពន្ធ៖** Paul Belchi (Iram), Picheth Seng និង Clément Vialade (Agrisud International), Dorian Dejace (APDRA), Sophoan Min និង Savoeurn Meang (AVSF), Patrick Renaud (Geres), Sokharith Touch (Gret), Jean- Marie Brun (ARTE-FACT ក្នុងនាម Iram)។
**អ្នករួមវិភាគទាន៖** Elise Perniceni (Gret) ។

សម្រាប់ការសហការចូលរួមក្នុងកិច្ចពិភាក្សានេះ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖ លោក ញ៉ែម សារឿន (នាយក កម្មវិធី CESPA) លោក សួន ចំរើន (អ្នកសម្របសម្រួលកម្មវិធី CESPA) លោក ហ៊ុន សុឃីន និង សុខ គន្ធីដា (អ្នកផលិតកម្មវិធី CESPA) ថៃ សូដា (នាយករង Ecofar), សឿន ឆាយ (អ្នកផលិតចូលរួមក្នុងគម្រោង DeFiP), វ៉ែង នាង (សមាជិក PMUAC), អឿ សំអាត (នាយក PMUAC), ធុង ចំប៉ា (អ្នកផលិត និងឈ្មួញប្រមូលទិញមកពីសហគមន៍កសិកម្មបៃតង), តាន់ ឌីណារី (ប្រធានគម្រោង Agris ទទួលបន្ទុកសហគមន៍កសិកម្មបៃតង)ភឿន គឹមលី (ប្រធានមន្ទីរពាណិជ្ជកម្មខេត្តសៀមរាប) ញឹម ថាំងចេង (នាយកប្រតិបត្តិក្រុមហ៊ុន AMRU Rice) លោក Emmanuel Dollfus (អនុប្រធាន AFD) Laure Steer (មន្ត្រីកម្មវិធីអង្គការ Iram); ធីម គឹមសួ (មន្ត្រីផ្នែកធនធាន និងភស្តុភារទូទៅ), ជិន ចាវអាន (មន្ត្រីទំនាក់ទំនង), កែវ សុជាតា (នាយកអង្គការ Gret), Damien Lagandré (នាយកប្រចាំតំបន់អង្គការ Gret) ។

យើងសូមថ្លែងអំណរគុណយ៉ាងកក់ក្តៅបំផុតចំពោះសហសេវិករបស់យើងមកពីអង្គភាពទាំង 6 នៃកម្មវិធី *"គំនិតផ្តួចផ្តើមGroupe initiatives"* ដែលបានចូលរួមក្នុងការងារនេះនៅគ្រប់ដំណាក់កាល។ យើងក៏សូមថ្លែងអំណរគុណផងដែរចំពោះដៃគូទាំងអស់នៅកម្រិតមូលដ្ឋាន (អ្នកផលិត ឈ្មួញប្រមូលទិញស្រូវអង្ករ អង្គការសង្គមស៊ីវិល អាជ្ញាធរមូលដ្ឋាន វិស័យឯកជន) ដែលបានខិតខំប្រឹងប្រែងជួយគាំទ្រដល់ការងារនេះ តាមរយៈការផ្តល់មតិកែលម្អដែលបានពីបទពិសោធន៍ជាក់ស្តែងនៅកម្រិតមូលដ្ឋាន។

In partnership with

RÉPUBLIQUE FRANÇAISE
Liberté
Égalité
Fraternité

AFD AGENCE FRANÇAISE DE DÉVELOPPEMENT

អត្ថបទបោះពុម្ពផ្សាយនេះទទួលបានការឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD) ។ ទោះជាយ៉ាងនេះក្តី គំនិត និង ទស្សនៈដែលបានលើកឡើង មិនតែងតែតំណាងឱ្យគំនិត និងទស្សនៈរបស់ AFD នោះទេ។

# មាតិកា


បទវិចារណកថា....4

សេចក្ដីផ្ដើម....5

ការកំណត់ក្របខណ្ឌ – បញ្ហាប្រឈមក្នុងការគ្រប់គ្រងគុណភាពរបស់អង្គភាពនានានៅក្នុងខ្សែសង្វាក់តម្លៃនៅកម្ពុជា....6

- ការទ្រទ្រង់និរន្តរភាពនៃកំណើនសេដ្ឋកិច្ច និងកសិកម្មនៅកម្ពុជា គឺជាបញ្ហាចោទមួយ....6
- ការគាំទ្រការធ្វើសមាហរណកម្មអ្នកផលិតជាលក្ខណៈគ្រួសារទៅក្នុងខ្សែសង្វាក់តម្លៃជាកាតាលីករជំរុញនិរន្តរភាពនៃប្រព័ន្ធស្បៀងអាហារ....7

សកម្មភាពអង្កេតស្រាវជ្រាវ និងចំណុចបញ្ហា....8

- សកម្មភាពផ្សេងៗ និងសនិទានភាពនៃកិច្ចអន្តរាគមន៍ទូទៅ....8
- បញ្ហាទាក់ទងនឹងអង្គភាព និងការគ្រប់គ្រងគុណភាព....9

ការកំណត់គុណភាព៖ រវាងការឆ្លើយតបនឹងទីផ្សារ និងលើកកម្ពស់ការអនុវត្តដែលមានស្រាប់....10

អង្គភាពជារចនាសម្ព័ន្ធដ៏សំខាន់សម្រាប់ការគ្រប់គ្រងគុណភាព និងចូលទៅកាន់ទីផ្សារ....13

- ការបង្កើតអង្គភាពដែលមានគោលដៅរួម និងមុខងារដែលបានកំណត់....13
- អង្គភាពជារចនាសម្ព័ន្ធដ៏សំខាន់ក្នុងការគ្រប់គ្រងគុណភាព....15
- អង្គភាពជារចនាសម្ព័ន្ធដ៏សំខាន់សម្រាប់ការធ្វើពាណិជ្ជកម្ម....18

តួនាទីគាំទ្រជាបន្តចំពោះសមាជិក Gi....20

អនុសាសន៍....21

ករណីសិក្សា - សន្លឹកព័ត៌មាន....22

- Agrisud....22
- APDRA....25
- AVSF - Iram....27
- Geres....29
- Gret....31




កសិករចំណាននៅជ្រាយ ណែនាំអំពីរបៀបធ្វើរងបន្លែ ឆ្នាំ 2023

# ការគាំទ្រអង្គភាពអ្នកផលិត ដើម្បីអភិវឌ្ឍន៍ជនបទប្រកបដោយចីរភាពនៅកម្ពុជា



កម្មវិធី "*គំនិតផ្តួចផ្តើម Groupe initiatives*" គឺជាបណ្តុំអង្គភាពសាមគ្គីភាពអន្តរជាតិ ដែលមានគោលបំណងធ្វើការរួមគ្នា ដើម្បីឱ្យមានការរស់នៅក្នុងពិភពមួយដែលមានការគោរពសិទ្ធិផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌សម្រាប់ទាំងអស់គ្នា។ ក្នុងចំណោមនោះ មានអង្គភាពចំនួនប្រាំមួយដែលមានវត្តមាននៅកម្ពុជា (ពោលគឺ អង្គការ Agrisud International, APDRA, AVSF, Geres, Gret, Iram) ហើយភាគច្រើនបានធ្វើការអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ប្រទេសកម្ពុជាបានប្រែក្លាយទៅជា "ប្រទេសមានចំណូលមធ្យមកម្រិតទាប" នៅក្នុងឆ្នាំ 2015។ វិស័យវាយនភណ្ឌ កសិកម្ម ទេសចរណ៍ ហើយថ្មីៗនេះគឺវិស័យសំណង់ និងអចលនទ្រព្យ បានធ្វើឱ្យប្រាក់ចំណូលមានភាពល្អប្រសើរឡើងយ៉ាងខ្លាំង និងកាត់បន្ថយចំនួនប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រពី 47.8% ក្នុងឆ្នាំ 2007 មកនៅត្រឹម 9.5% ក្នុងឆ្នាំ 2019 (ថ្វីត្បិតតែតួលេខនេះមានការងើបឡើងវិញក្នុងអំឡុងពេលនៃការឆ្លងរាតត្បាតជាសាកលនៃជំងឺកូវីដ ១៩ ក៏ដោយ) ទោះបីជាលទ្ធផលមិនល្អប្រសើរជាងប្រទេសជិតខាងក៏ដោយ បើនិយាយអំពីគុណភាព សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

ទោះជាយ៉ាងនេះក្តី កំណើនសេដ្ឋកិច្ចបានកើតមានឡើងដំណាលគ្នាជាមួយនឹងការកើនឡើងនូវបញ្ហាប្រឈមក្នុងការទ្រទ្រង់និរន្តរភាពនៃប្រព័ន្ធផលិតកម្មកសិកម្ម និងប្រព័ន្ធថាមពល ខណៈដែលបញ្ហាធនធានទឹក និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុកាន់តែរងសម្ពាធធ្ងន់ធ្ងរទៅៗ។ ក្នុងបរិបទនេះ តើការអភិវឌ្ឍសេដ្ឋកិច្ច ការប្រយុទ្ធប្រឆាំងភាពក្រីក្រ និងការថែរក្សាបរិស្ថានអាចរក្សាបានតុល្យភាពដោយរបៀបណា? ជាតួយ៉ាង នៅក្នុងកម្មវិធី "*គំនិតផ្តួចផ្តើម Groupe initiatives*" សមាជិករបស់យើងតែងរួមចំណែកដល់ការជជែកពិភាក្សាដោយផ្អែកលើមូលដ្ឋាននៃការអនុវត្ត និងជំនាញជាសមូហភាព។ ចាប់ផ្តើមពីសកម្មភាពនៅនឹង

*Marie-Noëlle Reboulet, ប្រធានកម្មវិធី Gi*



មូលដ្ឋាន ដើម្បីគាំទ្រដល់ការដាក់បញ្ចូលអ្នកផលិត និងសិប្បករជាលក្ខណៈគ្រួសារទៅក្នុងខ្សែសង្វាក់តម្លៃ និងផ្តល់លទ្ធភាពដល់ពួកគេចូលទៅកាន់ទីផ្សារដែលអាចរកប្រាក់ចំណេញ សមាជិកទាំងប្រាំមួយរបស់យើងពិនិត្យមើលជាពិសេសលើបញ្ហាប្រឈមក្នុងការគ្រប់គ្រងគុណភាពតាមរយៈអង្គភាពនៅក្នុងវិស័យផ្សេងៗ។

ឆ្លងតាមបទពិសោធន៍ និងការអនុវត្តរបស់ខ្លួនកន្លងមក សមាជិករបស់យើងសម្រេចបានវឌ្ឍនភាពរួមគ្នា ហើយក៏មានបំណងរួមចំណែកជាពិសេសក្នុងការពិចារណាលើបញ្ហាផ្សេងៗជាមួយភាគីពាក់ព័ន្ធនានានៅក្នុងមូលដ្ឋាន ខ្សែសង្វាក់តម្លៃ និងវិស័យអភិវឌ្ឍន៍នៅកម្ពុជា ដើម្បីកំណត់ពីតួនាទីរបស់ទីភ្នាក់ងារ និងប្រតិបត្តិករជនបទ ក៏ដូចជារួមចំណែកដល់គោលនយោបាយសាធារណៈ។ នេះគឺជាតួនាទីដ៏សំខាន់មួយសម្រាប់អង្គការអភិវឌ្ឍន៍អន្តរជាតិដូចជាស្ថាប័នរបស់យើង ផ្តើមចេញពីទស្សនៈសាមគ្គីភាពអន្តរជាតិ ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព( SDGs )។

យើងសង្ឃឹមថា ការងាររួមគ្នានេះនៅកម្ពុជា នឹងក្លាយជាកិច្ចសហប្រតិបត្តិការលើកដំបូងដ៏រឹងមាំរវាងសមាជិកនៃកម្មវិធី "*គំនិតផ្តួចផ្តើម Groupe initiatives*" ជាមួយនឹងភាគីពាក់ព័ន្ធទាំងអស់នៅក្នុងស្រុក។

សេចក្តីផ្តើម

## ការដកស្រង់បទពិសោធន៍កន្លងមករបស់កម្មវិធី Gi នៅកម្ពុជា

តាមរយៈ Traverses 53, កម្មវិធី Gi បានព្យាយាមដកស្រង់បទពិសោធន៍ សិក្សាស្វែងយល់ និងពិភាក្សាអំពីការអនុវត្តក្នុងចំណោមសមាជិករបស់ខ្លួនដែលកំពុងធ្វើប្រតិបត្តិការនៅកម្ពុជា ហើយភាគច្រើនបានធ្វើសកម្មភាពអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ការសិក្សានេះធ្វើឡើងជាផ្នែកមួយនៃគម្រោង Syner- Gi ក្រោមប្រធានបទ៖ "ពង្រឹង និងរៀបចំរចនាសម្ព័ន្ធអង្គភាពសង្គមស៊ីវិលក្នុងវិស័យអភិវឌ្ឍន៍ និងដៃគូរបស់ខ្លួន ដើម្បីជំរុញការដាក់បញ្ចូលជំនាញជាសមូហភាព" ដែលត្រូវបានគាំទ្រដោយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (Agence Française de Développement) ក្នុងគោលបំណងជួយគាំទ្រការចែករំលែក និងផ្សព្វផ្សាយអំពីការអនុវត្តរបស់សមាជិក Gi សំដៅពង្រឹងសម្ព័ន្ធភាពរបស់ខ្លួនក្នុងវិស័យជំនាញ និងវិស្វកម្មគម្រោង និងជាចុងក្រោយលើកកម្ពស់គុណតម្លៃ និងវិធីសាស្ត្ររបស់ខ្លួនឱ្យបានកាន់តែប្រសើរឡើងទាក់ទងនឹងសាមគ្គីភាព ជំនួយអភិវឌ្ឍន៍ និងការប្រយុទ្ធប្រឆាំងបញ្ហាវិសមភាព។


© Sophoan Yin

សមាជិក Gi នៅកម្ពុជា (ពោលគឺ Agrisud International, APDRA, AVSF, Geres, Gret, Iram) បានសម្រេចអនុវត្តសកម្មភាពរួមគ្នាដើម្បីចែករំលែកបទពិសោធន៍ទាក់ទងនឹងការគាំទ្រអង្គភាពក្នុងវិស័យកសិកម្ម និងសិប្បកម្ម និងការគ្រប់គ្រងគុណភាព ដែលជាបញ្ហាចម្រុះវិស័យមួយពាក់ព័ន្ធនឹងអង្គភាពទាំងអស់នេះ។ ក្រុមមកពីអង្គភាពដែលជាសមាជិក Gi នៅកម្ពុជា អាចនឹងបានចែករំលែករួចហើយនូវការអនុវត្ត និងបទពិសោធន៍របស់ខ្លួន តាមរយៈដំណើរទស្សនកិច្ច និងកិច្ចប្រជុំនានា។ អង្គភាពមួយចំនួន គឺជាដៃគូនៅក្នុងគម្រោងរួមគ្នា (ពោលគឺ Agrisud និង Gret, AVSF និង Iram) ។ ការអនុវត្តរួមគ្នាដោយផ្អែកតាមបទពិសោធន៍រៀងៗខ្លួនកន្លងមក ទាក់ទងនឹងអង្គភាពនៅក្នុងខ្សែសង្វាក់តម្លៃ និងកាគ្រប់គ្រងគុណភាពតាមរយៈការអនុវត្តជាក់ស្តែងរបស់ខ្លួន ធ្វើឡើងតាមរយៈកិច្ចពិភាក្សាជាបន្តបន្ទាប់ ដោយមានការរៀបចំរចនាសម្ព័ន្ធ និងការវិភាគជាផ្លូវការ ធ្វើការវាយតម្លៃសមិទ្ធផល និងលើកឡើងពីដំណើរការអភិវឌ្ឍន៍ដែលពាក់ព័ន្ធនឹងសកម្មភាពរបស់ខ្លួន។

គោលបំណងនៃការសិក្សានេះ គឺដើម្បីចែករំលែកបទពិសោធន៍ជាមេរៀនដែលបានរៀនសូត្រកន្លងមក ដើម្បីស្វែងយល់ និងពិភាក្សាអំពីវិធីសាស្ត្រ ការអនុវត្ត និងឧបករណ៍របស់ខ្លួន ដើម្បីកំណត់កត្តារចនាសម្ព័ន្ធសម្រាប់ការអភិវឌ្ឍខ្សែសង្វាក់តម្លៃសម្រាប់

អ្នកផលិត និងសិប្បករជាលក្ខណៈគ្រួសារ ដើម្បីចងក្រងអនុសាសន៍ និងកសាងគោលជំហរ។ វិធីសាស្ត្រទាំងនេះរួមមានការវាយតម្លៃ និងលើកកម្ពស់បទពិសោធន៍ និងការអនុវត្តដែលពាក់ព័ន្ធ និងប្រកបដោយភាពច្នៃប្រឌិត ការពង្រឹងសក្តានុពលផ្ទៃក្នុងរបស់ Gi នៅកម្ពុជា តាមរយៈការកំណត់តម្លៃបន្ថែម ការបំពេញបន្ថែម និងការរួមបញ្ចូលគ្នា ជំរុញការពិភាក្សាជាមួយភាគីពាក់ព័ន្ធនៅក្នុងមូលដ្ឋាន ខ្សែសង្វាក់តម្លៃ និងការអភិវឌ្ឍនៅកម្ពុជា ក៏ដូចជារួមចំណែកដល់គោលនយោបាយសាធារណៈ។ ដំណើរការដកស្រង់បទពិសោធន៍កន្លងមក ធ្វើឡើងតាមដំណាក់កាលជាច្រើន៖

- **ដំណាក់កាលកំណត់ក្របខណ្ឌ** (ក្នុងខែឧសភា ឆ្នាំ 2023 ធ្វើឡើងពីចម្ងាយ) ដើម្បីកំណត់បញ្ហា និងស្វែងយល់បញ្ហាចម្រុះវិស័យតាមរយៈការដកស្រង់បទពិសោធន៍កន្លងមក និងវាយតម្លៃករណីសិក្សា។
- **ដំណើរទស្សនកិច្ចសិក្សាមកកាន់ប្រទេសកម្ពុជា** (ខែមិថុនា ឆ្នាំ 2023) របស់អ្នកសម្របសម្រួល ដើម្បីចូលរួមសិក្ខាសាលាពិភាក្សាអំពីបញ្ហានានាជាមួយសមាជិក Gi និងដៃគូសំខាន់ៗរបស់ខ្លួន និងដើម្បីចុះត្រួតពិនិត្យគម្រោងរបស់ខ្លួន។
- **សិក្ខាសាលានៅរាជធានីភ្នំពេញ** (ប្រារព្ធឡើងនៅថ្ងៃទី 05 ខែតុលា ឆ្នាំ 2023) មានអ្នកចូលរួមជាង 70 នាក់ ជាមួយនឹងបទបង្ហាញរបស់សមាជិក Gi និងដៃគូរបស់ខ្លួន អំពីបទពិសោធន៍របស់ខ្លួន បន្ទាប់មកមានការជជែកពិភាក្សាជាមួយវាគ្មិន និងអ្នកចូលរួមខាងក្រៅ។
- **ការបោះពុម្ពផ្សាយស្នាដៃដែលបានពីការដកស្រង់បទពិសោធន៍នៅក្នុងកម្រងឯកសាររបស់** Traverses រួមទាំងការវិភាគចម្រុះវិស័យ និងសន្លឹកព័ត៌មានសង្ខេបតាមករណីសិក្សា។

ការកំណត់ក្របខណ្ឌ

# បញ្ហាប្រឈមក្នុងការគ្រប់គ្រងគុណភាពរបស់អង្គភាពនានានៅក្នុងខ្សែសង្វាក់តម្លៃនៅកម្ពុជា

ការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា គឺអាស្រ័យលើការលើកកម្ពស់ធនធានធម្មជាតិសំខាន់ៗរបស់ប្រទេស ពោលគឺធនធានទឹក ដីដ៏ច្រើនសន្ធឹកសន្ធាប់ និងប្រព័ន្ធអេកូឡូស៊ីផ្សេងៗ។ សកម្មភាពសក្តានុពលជាច្រើនបាននិងកំពុងដំណើរការអភិវឌ្ឍន៍ រាប់ចាប់ពីកសិកម្មខ្នាតធំដែលប្រើដើមទុនច្រើន រហូតដល់ផលិតកម្មជាលក្ខណៈគ្រួសារ និងរាប់ចាប់ពីគំរូប្រើប្រាស់ដីដែលមានជីជាតិតាមវិធីដែលមិនមាននិរន្តរភាព (ជាពិសេសបន្ទាប់ពីសកម្មភាពឈូសឆាយដី) រហូតដល់ប្រព័ន្ធកសិកម្មប្រកបដោយនិរន្តរភាព។ កសិដ្ឋានលក្ខណៈគ្រួសារមួយចំនួន បានប្រកាន់ខ្ជាប់ការអនុវត្តដែលឆ្លើយតបនឹងគោលដៅប្រកបដោយនិរន្តរភាព ប៉ុន្តែប្រឈមមុខនឹងការខ្វះខាតការទទួលស្គាល់គ្រប់គ្រាន់ ជាពិសេសក្នុងចំណោមភាគីពាក់ព័ន្ធនៅក្នុងខ្សែសង្វាក់តម្លៃផ្នែកលំហូរខាងក្រោម។ ដូច្នេះ ការគាំទ្រការធ្វើសមាហរណកម្ម កសិដ្ឋានទៅក្នុង ខ្សែសង្វាក់តម្លៃទាំងនេះ គឺជាមធ្យោបាយជាក់ស្តែងមួយក្នុងការពង្រឹង និងផ្សព្វផ្សាយការអនុវត្តប្រកបដោយនិរន្តរភាពរបស់ខ្លួន។

ក្នុងបរិបទនេះ សមាជិកទាំងប្រាំមួយរបស់ Gi ដែលបាននិងកំពុងធ្វើការនៅកម្ពុជា (ពោលគឺ Agrisud International, APDRA, AVSF, Geres, Gret, Iram) មានគោលបំណងរួមគ្នាក្នុងការដកស្រង់បទពិសោធន៍ សិក្សាស្វែងយល់ និងពិភាក្សាអំពីបទពិសោធន៍ និងការអនុវត្តរបស់ខ្លួនលើប្រធានបទអង្គភាពនៅក្នុងខ្សែសង្វាក់តម្លៃ និងការគ្រប់គ្រងគុណភាព។

## ការទ្រទ្រង់និរន្តរភាពនៃកំណើនសេដ្ឋកិច្ច និងកសិកម្មនៅកម្ពុជា គឺជាបញ្ហាចោទមួយ

អស់រយៈពេលពីរទស្សវត្សរ៍ឈានដល់ការឆ្លងរាតត្បាតជាសាកល នៃជំងឺកូវីដ 19 ក្នុងឆ្នាំ 2020 ប្រទេសកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចដ៏រឹងមាំ ហេតុក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ 2015។ កំណើនដ៏ខ្លាំងបានមកពីការនាំចេញសម្លៀកបំពាក់ វិស័យកសិកម្ម ទេសចរណ៍ និងវិស័យជាច្រើនទៀត ហើយថ្មីៗនេះ គឺវិស័យសំណង់ និងអចលនទ្រព្យ។ កត្តានេះបានរួមចំណែកដល់ការថយចុះគួរឱ្យកត់សម្គាល់នូវចំនួនប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ (ពី 47.8% ក្នុងឆ្នាំ 2007 មកនៅត្រឹម 9.5% ក្នុងឆ្នាំ 2019 (ថ្វីត្បិតតែមានការងើបឡើងវិញក្នុងអំឡុងពេលនៃការឆ្លងរាតត្បាតជាសាកលនៃជំងឺ កូវីដ ១៩ ក៏ដោយ)។ ក្នុងឆ្នាំ 2019 ការរួមចំណែកពីវិស័យកសិកម្មនៅក្នុងផលិតផលក្នុងស្រុកសរុប (GDP) មានចំនួនប្រមាណ 22.1% តំណាងឱ្យប្រជាជនប្រហែល 3 លាននាក់នៅក្នុងវិស័យនេះ (ស្មើនឹង 32.3% នៃកម្លាំងពលកម្មសរុប) ភាគច្រើនជាអ្នកផលិតខ្នាតតូច។ ទោះបីជាវិស័យកសិកម្មរបស់កម្ពុជាមានភាពខ្លាំងយ៉ាងណាក៏ដោយ (ធនធានទឹកក្នុងស្រុក ប្រព័ន្ធអេកូឡូស៊ីចម្រុះ ធនធានមនុស្សសំខាន់ៗ) ប៉ុន្តែវិស័យកសិកម្មនៅតែប្រឈមនឹងបញ្ហាក្នុងការអនុវត្តដែលមិនប្រកបដោយនិរន្តរភាព (ការកាប់បំផ្លាញព្រៃឈើ ភាពទន់ខ្សោយនៃការត្រួតពិនិត្យសម្ភារកសិកម្ម) ដោយបន្តពឹងផ្អែកលើការនាំចេញទំនិញមិនទាន់កែច្នៃមួយចំនួន (ឧទាហរណ៍ ស្រូវ កៅស៊ូ) និងកង្វះការធ្វើពិពិធកម្មផលិតកម្ម និងតម្លៃបន្ថែម។

ទាក់ទងនឹងសន្តិសុខស្បៀង និងសុវត្ថិភាព ស្ថានភាពនៅកម្ពុជាមានភាពល្អប្រសើរឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ទោះយ៉ាងណា ប្រទេសកម្ពុជានៅដើរយឺតជាងបណ្តាប្រទេសជិតខាង លើផ្នែកគុណភាព សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ កង្វះអាហារូបត្ថម្ភនៅតែជាបញ្ហាដែលកើតមានក្នុងចំណោមក្រុមប្រជាជនក្រីក្រ និងងាយរងគ្រោះបំផុត ខណៈដែលប្រទេសកម្ពុជាប្រឈមនឹងកង្វះគោលនយោបាយ និងស្តង់ដារបច្ចេកទេសសម្រាប់ត្រួតពិនិត្យ និងគ្រប់គ្រងសន្តិសុខស្បៀងក៏ដូចជាកង្វះការសម្របសម្រួលគ្រប់គ្រាន់ពីសំណាក់ទីភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធ។



អ្នកផលិតស្រូវជាសមាជិក PMUAC កំពុងស្ទូងស្រូវដោយដៃ

©AVSF

# ការគាំទ្រការធ្វើសមាហរណកម្មអ្នកផលិតជាលក្ខណៈគ្រួសារនៅក្នុងខ្សែសង្វាក់តម្លៃជាគន្លឹះដើម្បីជំរុញនិរន្តរភាពនៃប្រព័ន្ធស្បៀងអាហារ

នៅពីក្រោយសកម្មភាពនេះ Gi បានគាំទ្រដល់ការធ្វើសមាហរណកម្មកសិករ និងសិប្បករជាលក្ខណៈគ្រួសារទៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ទាំងក្នុងស្រុក ថ្នាក់ជាតិ និងអន្តរជាតិ អស់រយៈពេលជាច្រើនឆ្នាំ ឬរាប់ទសវត្សរ៍ ក្នុងករណីខ្លះ។ គោលបំណង គឺដើម្បីជំរុញការចែករំលែកតម្លៃរបស់ខ្លួនកាន់តែប្រសើរឡើង និងរួមចំណែកដល់ការលើកកម្ពស់ប្រាក់ចំណូល និងជីវភាពរស់នៅ ការរក្សាឱ្យមានការងារធ្វើនៅតំបន់ជនបទ និងជាចុងក្រោយ ប្រយុទ្ធប្រឆាំងភាពក្រីក្រ និងអសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ អង្គការ Agrisud International, APDRA Pisci- culture paysanne, AVSF, Gret និងអង្គការ Iram បានចូលរួមនៅក្នុងខ្សែសង្វាក់តម្លៃលើវិស័យកសិកម្ម ចំណែក Geres ចូលរួមក្នុងខ្សែសង្វាក់តម្លៃលើវិស័យ ថាមពល។

ការធ្វើសមាហរណកម្មអ្នកផលិត និងសិប្បករជាលក្ខណៈគ្រួសារទៅក្នុងខ្សែសង្វាក់តម្លៃ ជាមួយនឹងការបង្កើនលទ្ធភាពចូលទៅកាន់ទីផ្សារដែលរកប្រាក់ចំណេញ គឺអាចលើកកម្ពស់ការអនុវត្តរបស់ពួកគេកាន់តែប្រកបដោយនិរន្តរភាពថែមទៀត ដោយមានការគាំទ្រពីសមាជិក Gi ជាពិសេសការអនុវត្តក្នុងវិស័យកសិអេកូឡូស៊ី ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាពនៃបរិក្ខារថាមពល។ ការអនុវត្តទាំងនេះគឺជាដំណោះស្រាយមួយចំពោះបញ្ហាប្រឈមកាន់តែខ្លាំងឡើង ក្នុងការទ្រទ្រង់និរន្តរភាពនៃប្រព័ន្ធផលិតកម្មកសិកម្មក្នុងបរិបទនៃការរិចរិល និងសំណឹកដី ការបាត់បង់ជីវចម្រុះ សម្ពាធលើធនធានទឹក និងការប្រែប្រួលអាកាសធាតុ។ ពួកគេក៏បានបំពេញតាមគោលដៅទ្រទ្រង់និរន្តរភាពរបស់ប្រព័ន្ធថាមពលនៅក្នុងស្ថានភាពដែលជីវម៉ាស (ធ្យូង និងអុស) មានច្រើនលើសពី 40% នៃការផ្គត់ផ្គង់ថាមពលចម្បងនៅកម្ពុជា ដូច្នេះហើយនៅតែមានកត្តាចម្បងដែលនាំឱ្យមានការរិចរិល និងការកាប់បំផ្លាញព្រៃឈើ (ការកាប់បំផ្លាញព្រៃឈើប្រចាំឆ្នាំចំនួន 5% នៅចន្លោះឆ្នាំ 2010 និង 2014 និង 1.2% នៅចន្លោះឆ្នាំ 2016 និង 2021)។

អ្នកផលិត និងសិប្បករជាលក្ខណៈគ្រួសារ តែងមានការពិបាកក្នុងការតភ្ជាប់ទៅកាន់ទីផ្សារ ដោយប្រឈមមុខនឹងការខ្វះខាត និងភាពមិនស៊ីសង្វាក់នៃព័ត៌មាន ក៏ដូចជាប្រតិបត្តិករជាឈ្មួញកណ្តាលនៅក្នុងខ្សែសង្វាក់ ក្នុងករណីដែលការរំពឹងទុកកាន់តែច្រើនឡើងរបស់អ្នកប្រើប្រាស់ និងគោលនយោបាយ អមជាមួយនឹងតម្រូវការស្តង់ដារគុណភាព និងលក្ខណៈបច្ចេកទេសកាន់តែខ្លាំង ខណៈមានការប្រកួតប្រជែងខ្លាំងពីខាងក្រៅប្រទេស និងអ្នកផលិតទ្រង់ទ្រាយធំ ។

ជាងនេះទៀត ដោយសារអង្គភាពងាយរងឥទ្ធិពល ហើយទន់ខ្សោយមានសមត្ថភាពខ្សោយក្នុងការវិនិយោគ និងផ្តល់ហិរញ្ញប្បទានកត្តាផលិតកម្ម ហើយពួកគេនៅតែមានតម្រូវការខ្លាំងក្នុងការកសាងសមត្ថភាពផ្នែកបច្ចេកទេស រៀបចំរចនាសម្ព័ន្ធ និងផ្នែកពាណិជ្ជកម្ម បានធ្វើឱ្យពួកគេមិនអាចសម្របខ្លួន និងបំពេញតាមតម្រូវការទីផ្សារបានពេញលេញ។ ជាងនេះទៀត ដោយពួកគេស្ថិតនៅខាងចុងខ្សែសង្វាក់ ធ្វើឱ្យពួកគេមានជំហរទន់ខ្សោយក្នុងការចរចាមិនមានលទ្ធភាពលើកកម្ពស់គុណភាព និងយថាប្រភេទផលិតផល និងការអនុវត្តរបស់ខ្លួនក្នុងតម្លៃសមរម្យ ឬទទួលបានអត្ថប្រយោជន៍គ្រប់គ្រាន់ពីតម្លៃឧបត្ថម្ភធន ក៏ដូចជាតម្លៃដែលទទួលបាននៅទូទាំងខ្សែសង្វាក់ទាំងមូល។ ជាចុងក្រោយ ការលំបាកក្នុងការទំនាក់ទំនង និងការតស៊ូមតិ មិនអនុញ្ញាតឱ្យពួកគេមានឥទ្ធិពលគ្រប់គ្រាន់ក្នុងការជំរុញក្របខណ្ឌស្ថាប័ន ច្បាប់សារពើពន្ធ និងពាណិជ្ជកម្មដែលមានភាពអនុគ្រោះខ្លាំងនោះទេ។



កសិករដាំដំណាំស្រូវជាសមាជិកអង្គភាព PMUAC

ប្រអប់លេខ 1

## គុណភាព និងអង្គភាព៖ តើយើងកំពុងនិយាយអំពីអ្វី?

ប្រធានបទស្តីពី "អង្គភាពនៅក្នុងខ្សែសង្វាក់តម្លៃ និងការគ្រប់គ្រងគុណភាព" ទាមទារឱ្យមានការបញ្ជាក់យ៉ាងច្បាស់អំពីគោលគំនិតផ្សេងៗ ដែលប្រើក្នុងអំឡុងពេលនៃការអនុវត្តដកស្រង់បទពិសោធន៍។

- ខ្សែសង្វាក់តម្លៃ៖ សំណុំប្រតិបត្តិការផលិតកម្ម ដំណើរការ និងដឹកជញ្ជូនដែលត្រូវការ ដើម្បីផ្គត់ផ្គង់ផលិតផលទៅដល់អ្នកប្រើប្រាស់ចុងក្រោយ។ វាត្រូវបានអនុវត្តដោយភាគីពាក់ព័ន្ធជាច្រើន គួបផ្សំជាមួយនឹងយុទ្ធសាស្រ្តផ្ទាល់ខ្លួន។ ប្រតិបត្តិការទាំងនេះបង្កើតនូវគុណតម្លៃដែលបានចែករំលែកក្នុងចំណោមបណ្តាញតភ្ជាប់នៅក្នុងខ្សែសង្វាក់ ដោយផ្អែកលើទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្មរបស់ខ្លួន។
- អង្គភាព –បុគ្គលមួយក្រុមនៅក្នុងរចនាសម្ព័ន្ធដែលមានច្បាប់ និងប្រព័ន្ធទំនាក់ទំនងដែលសម្របសម្រួលលំហូរព័ត៌មាន ដើម្បីបំពេញតម្រូវការ និងគោលបំណងជាក់លាក់។
- គុណភាព – លក្ខណៈ គុណលក្ខណៈ តម្លៃផលិតផល ឬសេវាដែលកំណត់ដោយអ្នកប្រើប្រាស់ ឬអតិថិជន ដើម្បីបំពេញតម្រូវការ និងការរំពឹងទុករបស់ខ្លួន។ ដូច្នេះគុណភាពគឺជាផ្នត់គំនិតមួយដែលទាក់ទងនឹងតម្រូវការ និងពហុវិស័យ។ គុណភាពអាចរួមបញ្ចូលធាតុផ្សំផ្សេងៗដូចជា គុណភាពទូទៅ ដែលភាគច្រើនផ្អែកលើកម្រិតសុវត្ថិភាពសុខភាព និងអាហារូបត្ថម្ភ និងគុណភាពពិសេស ដែលផ្អែកលើលក្ខណៈរូបរាង មុខងារ (ភាពងាយស្រួល ការចែកចាយ។ល។) ក៏ដូចជាទិដ្ឋភាពសង្គម និងបរិស្ថាន។
- ការគ្រប់គ្រងគុណភាព៖ សំណុំស្តង់ដារ វិធាន និងដំណើរការអនុវត្ត និងប្រតិបត្តិ ដែលជាតុផ្សំទាំងពីរជំរុញដល់ការសម្រេចបាននូវលក្ខណៈផលិតផល ឬសេវា និងការវាស់វែង និងត្រួតពិនិត្យគុណភាពតាមការរំពឹងទុក។

# សកម្មភាពអង្កេតស្រាវជ្រាវ និងចំណុចបញ្ហា

## សកម្មភាពផ្សេងៗ និងសនិទានភាពនៃកិច្ចអន្តរាគមន៍ទូទៅ

សមាជិក Gi ធ្វើអន្តរាគមន៍ ឬបានធ្វើអន្តរាគមជាមួយអ្នកផលិត និងសិប្បករនៅក្នុងទីកជី និងវិស័យផ្សេងៗ ដែលប្រឈមមុខនឹងបញ្ហាចូលទៅកាន់ទីផ្សារទាំងនេះ៖

- ទីផ្សារក្នុងស្រុកនៅខេត្តសៀមរាប៖ ទីផ្សារស្ពួនបន្លែ គ្រឿងទេស អង្ករ (Agrisud, Gret), សាកវប្បកម្ម (Agrisud), បសុបក្សី (Gret), ការចិញ្ចឹមត្រី (APDRA) ភ្នំពេញ និងកំពង់ឆ្នាំង
- ទីផ្សារថ្នាក់ជាតិ៖ ធ្យូងអនាម័យ និងចង្ក្រានប្រណីត (Geres)
- ទីផ្សារអន្តរជាតិក្នុងតំបន់ព្រះវិហារ៖ អង្ករ (AVSF និង Iram)

ពួកគេបានអនុវត្តយុទ្ធសាស្ត្រ គោលការណ៍ និងឧបករណ៍ផ្សេងៗ ហើយបានបង្កើតបរិក្ខារទាំងនោះនៅក្នុងអំឡុងពេលនៃកិច្ចអន្តរាគមន៍របស់ខ្លួន ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមក្នុងការបង្កើនផលិតកម្ម និងការផ្គត់ផ្គង់កាន់តែប្រសើរ ការរៀបចំសហគមន៍អ្នកផលិត និង សិប្បករ ការរៀបចំរចនាសម្ព័ន្ធ និងការពិគ្រោះយោបល់នៅក្នុងខ្សែសង្វាក់តម្លៃ ការគាំទ្រការកែច្នៃក្នុងស្រុក ការគ្រប់គ្រងគុណភាពផលិតផល ការលើកកម្ពស់គុណភាពនិងយថាប្រភេទផលិតផល និងការលើកកម្ពស់ការយល់ដឹងក្នុងចំណោមតួអង្គនៅផ្នែកលំហូរខាងក្រោម និងស្ថាប័ន។

សមាជិក Gi នៅកម្ពុជា ចែករំលែកសនិទានភាពនៃកិច្ចអន្តរាគមន៍រួមមួយ៖ ពួកគេបានជ្រើសរើសយុទ្ធសាស្ត្រទទួលស្គាល់គុណភាព និងផ្សព្វផ្សាយតាមទីផ្សារ ឬតួអង្គនៅផ្នែកលំហូរខាងក្រោម និងអ្នកប្រើប្រាស់។ ស្លាកសញ្ញាគុណភាពផ្សេងៗ ត្រូវបានបង្កើតឡើងអំឡុងពេលអន្តរាគមន៍ ភាគច្រើនតាមរយៈម៉ាកផ្ទាល់ខ្លួនដោយផ្អែកលើការកំណត់យថាប្រភេទខាង ក្នុង និងការបញ្ជាក់របស់ភាគីទីបីដោយផ្អែកលើយថាប្រភេទខាងក្រៅ (ការផ្តល់វិញ្ញាបនបត្រសរីរាង្គ ពិព័រណ៍ពាណិជ្ជកម្ម)។ ស្លាកគុណភាពទាំងនេះត្រូវបានអនុវត្តដោយអង្គភាពអ្នក ផលិតផ្សេងៗ (សហគមន៍កសិកម្ម សហជីព សមាគម) ដែលត្រូវបានបង្កើតឡើងក្នុងដំណើរការអន្តរាគមន៍។ ទំនួលខុសត្រូវរបស់ពួកគេរួមមានការគាំទ្រផលិតកម្ម ការគ្រប់គ្រងគុណភាព និងការអភិវឌ្ឍអាជីវកម្ម។

**Agrisud៖** ចាប់តាំងពីឆ្នាំ 2016 មក Agrisud បានអនុវត្តគម្រោងប្រពលវប្បកម្ម និងពិពិធកម្មកសិអេកូឡូស៊ីនៃគម្រោងទីប្រជុំជនខេត្តសៀមរាប (IADA) ក្នុងគោលបំណងធ្វើប្រពលវប្បកម្មកសិអេកូឡូស៊ី និងពិពិធកម្មផលិតកម្មកសិកម្មក្នុងស្រុក អភិវឌ្ឍជម្រើសសេវាកសិកម្មជាច្រើន ដើម្បីបង្កើតកសិដ្ឋាន និងខ្សែសង្វាក់កសិកម្មជំនាញ និងឆ្ពោះទៅរកប្រព័ន្ធស្បៀងអាហារនៅក្នុងមូលដ្ឋាន។ គម្រោងនេះបានគាំទ្រដល់ការបង្កើតសហគមន៍កសិកម្មបៃតង (GF) ដែលទទួលខុសត្រូវក្នុងការប្រមូលទិញ កែច្នៃ និងចែកចាយកសិផលរបស់សមាជិក ក៏ដូចជាអនុវត្តសកម្មភាពទីផ្សារ ដាក់ស្លាកផលិតផល និងផ្សព្វផ្សាយជាពិសេសតាមរយៈម៉ាករបស់ខ្លួន។

**APDRA Pisciculture paysanne៖** ចាប់តាំងពីឆ្នាំ 2020 មក APRDA បានអនុវត្តគម្រោងអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃត្រី (DeFiP) នៅកម្ពុជា ដើម្បីកែលម្អឱ្យប្រសើរឡើងនូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងធ្វើពិពិធកម្មជីវភាពរស់នៅរបស់ប្រជាជននៅតាមជនបទ តាមរយៈការអភិវឌ្ឍកសិដ្ឋានចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ដើម្បីបម្រើតម្រូវការទីផ្សារក្នុងស្រុក។ នៅដំណាក់កាលនេះរបស់គម្រោង អ្នកផលិតមិនត្រូវបានប្រមូលផ្តុំគ្នាទៅជាអង្គភាពផ្លូវការទេ ប៉ុន្តែបានបង្កើតជាបណ្តាញតាមរយៈក្រុមក្រៅប្រព័ន្ធសម្រាប់វគ្គបណ្តុះបណ្តាល ការផ្លាស់ប្តូរទស្សនកិច្ច និងការពិភាក្សា។

**AVSF/Iram៖** ចាប់តាំងពីឆ្នាំ 2013 ដល់ឆ្នាំ 2017 AVSF និង Iram បានចូលរួមក្នុងការ អនុវត្តគម្រោងគាំទ្រពាណិជ្ជកម្មស្រូវអង្ករកម្ពុជា (SCCRP) ជាសកម្មភាពមួយក្នុងចំណោមសកម្មភាពនានាដែលជួយដល់ការអភិវឌ្ឍវិស័យស្រូវសរីរាង្គទ្រង់ទ្រាយធំនៅក្នុងខេត្តព្រះវិហារ។

គម្រោងនេះ បានគាំទ្រការបង្កើតសហភាពសហគមន៍កសិកម្មព្រះវិហារមានជ័យ (PMUAC) ជាសហភាពសហគមន៍កសិកម្មមួយដែលបានចុះបញ្ជីជាផ្លូវការដំបូងគេនៅកម្ពុជា។ សហជីពនេះទទួលខុសត្រូវក្នុងការគ្រប់គ្រងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ផ្តល់វិញ្ញាបនបត្រ ពង្រឹងសមត្ថភាពបច្ចេកទេសផលិតកម្មសរីរាង្គ និងសម្របសម្រួលការតភ្ជាប់ទាំងជាមួយទីផ្សារអន្តរជាតិ តាមរយៈការផ្តល់វិញ្ញាបនបត្រសរីរាង្គ និងពិព័រណ៍ពាណិជ្ជកម្ម និងទីផ្សារជាតិតាមរយៈម៉ាកផ្ទាល់ខ្លួនរបស់ខ្លួន។ AVSF បានរក្សាគាំទ្រសហជីព PMUAC រហូតមកដល់បច្ចុប្បន្ន។

**Geres៖** នៅចន្លោះឆ្នាំ 2003 ដល់ឆ្នាំ 2019 Geres បានគាំទ្រការផលិត និងចែកចាយចង្ក្រានប្រណីតនៅកម្ពុជា។ គម្រោង SEFED (គាំទ្រការបង្កើតខ្សែសង្វាក់ផ្គត់ផ្គង់ថ្មីៗប្រកបដោយនិន្នភាពនៅក្នុងវិស័យថាមពលក្នុងស្រុក) ដែលបានអនុវត្តចាប់ពីឆ្នាំ 2016 ដល់ឆ្នាំ 2019 ក្នុងគោលបំណងរួមបញ្ចូលគ្នារវាងផលិតកម្មក្នុងស្រុក និងសង្វាក់ផ្គត់ផ្គង់ចង្ក្រានប្រណីត រក្សាគុណភាពចង្ក្រាន និងមានការទទួលស្គាល់ពីទីផ្សារ ដោយផ្តល់ការគាំទ្រដល់សមាគមអ្នកផលិត និងចែកចាយចង្ក្រានក្នុងស្រុក

(*សមាគមអ្នកលើកកម្ពស់ចង្ក្រានប្រណីតនៅកម្ពុជា – CESPA*) ក៏ដូចជាបង្កើតស្លាកសញ្ញា ដើម្បីធានាលើកកម្ពស់គុណភាពចង្ក្រានប្រណីតនៅលើទីផ្សារ។

**Gret៖** ចាប់តាំងពីឆ្នាំ 2010 មក Gret បានអនុវត្តគម្រោងកសិកម្មពាក់កណ្ដាលប្រពលវប្បកម្មសម្រាប់កសិករលក្ខណៈគ្រួសារដោយប្រើប្រាស់សម្ភារកសិកម្មតិចតួច (APICI)។ គម្រោងនេះគាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធផលិតកម្ម និងទីផ្សារឱ្យកាន់តែមានប្រសិទ្ធភាពសម្រាប់កសិផល (ដំណាំស្រូវ ផ្លែឈើ និងបន្លែ មាន់) ដោយគាំទ្រដល់កសិអេកូឡូស៊ី ការចូលទៅកាន់ទីផ្សារ និងការរៀបចំរចនាសម្ព័ន្ធអង្គភាពកសិករអាជីព។ គម្រោងនេះបានគាំទ្រដល់ការបង្កើតសហគមន៍កសិកម្មសុវត្ថិភាពធម្មជាតិ (ECOFARM) ដែលទទួលខុសត្រូវលើការត្រួតពិនិត្យគុណភាពផ្ទៃក្នុងនូវផលិតផលសមាជិករបស់ខ្លួន តាមរយៈប្រព័ន្ធធានា គុណភាពដែលមានការចូលរួមពីភាគីពាក់ព័ន្ធ (PGS) ក៏ដូចជាការប្រមូលទិញ និងលក់ផលិតផលពីសមាជិករបស់ខ្លួន។

ព័ត៌មានសំខាន់ៗស្ដីពីអន្តរាគមន៍របស់សមាជិក Gi ត្រូវបានបង្ហាញនៅក្នុងសន្លឹកព័ត៌មានសង្ខេបនៅក្នុងឧបសម្ព័ន្ធ។

## បញ្ហាទាក់ទងនឹងអង្គភាព និងការគ្រប់គ្រងគុណភាព

សមាជិក Gi បានកំណត់បញ្ហាសំខាន់ៗដូចខាងក្រោមទាក់ទងនឹងការគាំទ្រអង្គភាពនៅក្នុងខ្សែសង្វាក់តម្លៃ និងការគ្រប់គ្រងគុណភាព។

**$ ការកសាងគុណភាព**

- តើនរណាជាអ្នកកំណត់គុណភាព៖ អ្នកប្រើប្រាស់ ឈ្មួញកណ្ដាល ឬអ្នកផលិត?
- តើគុណភាពមានលក្ខណៈដូចម្ដេច?
- តើប្រព័ន្ធផលិតកម្មត្រូវបានកែសម្រួល/ផ្លាស់ប្ដូរកម្រិតណាដើម្បីឱ្យស្របតាមគោលដៅគុណភាព?

**$ អង្គភាព ការគ្រប់គ្រងគុណភាព និងផ្នែកទីផ្សារ**

- តើមានការពាក់ព័ន្ធនឹងដំណើរការ និងដំណាក់កាលអ្វីខ្លះក្នុងការបង្កើតអង្គភាព?
- តើអង្គភាពគ្រប់គ្រងគុណភាពដោយរបៀបណា?
- តើអង្គភាពអភិវឌ្ឍទីផ្សារយ៉ាងដូចម្ដេច?
- តើមានលក្ខខណ្ឌអ្វីខ្លះដើម្បីទ្រទ្រង់និរន្តរភាពនៃអង្គភាព?

**$ ការកំណត់តួនាទីរបស់សមាជិក Gi**

- តើសមាជិក Gi មានតួនាទីអ្វីខ្លះនៅទូទាំងដំណើរការនេះ?
- តើដំណើរការផ្ទេរសិទ្ធិ និងកម្មសិទ្ធិអ្វីខ្លះ ត្រូវបានអនុវត្តតាមការគ្រប់គ្រងគុណភាពក្នុងស្រុក និងអង្គភាពពាក់ព័ន្ធ?
- តើភាគីផ្សេងទៀតដែលពាក់ព័ន្ធនឹងវិស័យអភិវឌ្ឍន៍ (អាជ្ញាធរសាធារណៈ សេវារបស់រដ្ឋាភិបាលវិមជ្ឈការសម្រាប់វិស័យកសិកម្មពាណិជ្ជកម្ម ម្ចាស់ជំនួយ ដៃគូអភិវឌ្ឍន៍បច្ចេកទេស។ល។) មានតួនាទីអ្វីខ្លះ និងចូលរួមយ៉ាងដូចម្ដេច?




ហ៊ុន សុឃិន សមាជិក CESPA

# ការកំណត់គុណភាព៖ រវាងការឆ្លើយតបនឹងទីផ្សារ និងលើកកម្ពស់ការអនុវត្តដែលមានស្រាប់

ជាទូទៅ គុណភាពកសិផល ឬសិប្បកម្ម ត្រូវបានកំណត់ដោយអ្នកប្រើប្រាស់ ឬអ្នកប្រើប្រាស់ចុងក្រោយ។ ជាការពិតណាស់យន្តការនៃការកំណត់គុណភាព គឺមានលក្ខណៈស្មុគស្មាញខ្លាំង ព្រោះវាពាក់ព័ន្ធនឹងភាគីផ្សេងទៀត រាប់ចាប់ពីអ្នកផលិតខ្លួនឯង ដែលមានតួនាទីដ៏សំខាន់ក្នុងការកសាងគុណភាព និងតម្រូវការ។ ផ្អែកតាមបទពិសោធន៍របស់សមាជិក Gi បានបង្ហាញពីរបៀបដែលអ្នកផលិតជាដៃគូរបស់ខ្លួន ជានាទូវតុល្យភាពជាក់លាក់ក្នុងការសម្របខ្លួនទៅនឹងតម្រូវការដែលមានស្រាប់ និងការបង្កើតឱ្យមានតម្រូវការតាមរយៈការទទួលស្គាល់ការអនុវត្តជាក់ស្តែងក្នុងការផលិតរបស់ខ្លួន។

> ប្រអប់លេខ2
>
> ### បញ្ហាទាក់ទងនឹងការកសាងគុណភាពផលិតផល
>
> - តើនរណាជាអ្នកកំណត់គុណភាព៖ អ្នកប្រើប្រាស់ ឈ្មួញកណ្តាល ឬអ្នកផលិត?
> - តើគុណភាពមានលក្ខណៈដូចម្តេច?
> - តើប្រព័ន្ធផលិតកម្មត្រូវបានកែសម្រួល/ផ្លាស់ប្តូរកម្រិតណាដើម្បីឱ្យស្របតាមគោលដៅគុណភាព?

សមាជិក Gi បានធ្វើការងារយ៉ាងច្រើន ដើម្បីពង្រឹងចំណេះដឹងរបស់អ្នកផលិតអំពីទីផ្សារ និងតម្រូវការជាក់លាក់របស់ខ្លួន ជាពិសេសកត្តាសំខាន់ៗដូចជា គុណភាពចំពោះសុខភាព គុណភាពសរីរាង្គ ការអនុលោមតាមវិញ្ញាបនបត្រភាគីទីបី កម្រិតបរិមាណនៃការផ្គត់ផ្គង់ ការធ្វើពិពិធកម្មផលិតផល ភាពញឹកញាប់នៃការដឹកជញ្ជូន និងក្របខណ្ឌពេលវេលា។ល។

ព័ត៌មាន និងចំណេះដឹងនេះ គឺមិនអាចខ្វះបានឡើយ ដើម្បីអាចឱ្យអ្នកផលិត អភិវឌ្ឍផលិតផលសម្រាប់ជាក់លាក់ និងឈានចូលទៅកាន់ទីផ្សារទាំងនេះ។ គម្រោងរបស់សមាជិក Gi បានជួយសម្រួលដល់ការកំណត់យ៉ាងល្អិតល្អន់នូវលក្ខណៈខ្សែសង្វាក់តម្លៃនីមួយៗផ្អែកតាមបរិបទជាក់ស្តែង។

បច្ចុប្បន្ន អន្តរាគមន៍របស់សមាជិក Gi អនុញ្ញាតឱ្យអ្នកផលិតដែលទទួលបានការគាំទ្រ កំណត់កាន់តែប្រសើរឡើងនូវតម្រូវការរបស់ភាគីពាក់ព័ន្ធនៅក្នុងខ្សែសង្វាក់លំហូរខាងក្រោម ដើម្បីតម្រង់ទិសជម្រើសផលិតកម្មរបស់ខ្លួនទៅតាមតម្រូវការ។ ចំណេះដឹងនេះត្រូវបានផ្តល់ជូនអ្នកផលិតដោយសមាជិក Gi ខ្លួនឯងតាមរយៈចំណេះដឹងដែលខ្លួនមានក្នុងវិស័យនេះ និង តាមរយៈការវិភាគ និងសិក្សាទីផ្សារ។ ចំណេះដឹងក៏ទទួលបានផងដែរតាមរយៈកិច្ចប្រជុំអន្តរវិជ្ជាជីវៈរួម ឬទូតាគីរវាងអ្នកផលិត ឈ្មួញកណ្តាល និងអ្នកទិញចុងក្រោយ។ កិច្ចប្រជុំប្រភេទនេះបានណែនាំដល់អ្នកទិញនូវព័ត៌មានស៊ីសង្វាក់គ្នាអំពីលក្ខណៈពិសេសនៃផលិតផលរបស់កសិករ ដែលរួមចំណែកជាធាតុផ្សំមួយនៃការចរចាពាណិជ្ជកម្ម ហើយក៏ធ្វើឱ្យអ្នកទិញមានការចាប់អារម្មណ៍ផងដែរ ដោយមើលឃើញថាលក្ខណៈពិសេសទាំងនេះជាកត្តាបែកចែងភាពខុសគ្នារបស់ផលិតផលនៅលើទីផ្សារ ធ្វើឱ្យពួកគេមានការចាប់អារម្មណ៍។

លក្ខខណ្ឌទាំងនេះមួយចំនួនអាចកំណត់ដោយអ្នកផលិតរួចហើយ ចំណែកខ្លះទៀតទាមទារឱ្យមានការកែប្រែនៅក្នុងប្រព័ន្ធផលិតកម្មរបស់ខ្លួន។ គោលបំណងនៃអន្តរាគមន៍របស់សមាជិក Gi គឺដើម្បីកសាងគុណភាពដោយណែនាំផលិតផលនវានុវត្តន៍ដែលស្របតាមប្រព័ន្ធផលិតកម្មដែលមានស្រាប់ ដើម្បីបំពេញតាមលក្ខខណ្ឌរបស់តួអង្គនៅផ្នែកលំហូរខាងក្រោម ដោយរក្សាបាននូវលក្ខណៈពិសេសនៃប្រព័ន្ធផលិតកម្មបច្ចុប្បន្ន និងពង្រឹងនិរន្តរភាពកាន់តែរឹងមាំថែមទៀត។

ជាឧទាហរណ៍ Geres និង CESPA បានណែនាំផលិតផលនវានុវត្តន៍មួយចំនួនស្របតាមការអនុវត្តដែលមានស្រាប់៖ ការរៀបចំល្បាយដីឥដ្ឋ បច្ចេកទេសចាក់ពុម្ពចង្ក្រាន ដំណើរការដុតសម្ងួតជាដើម។ Agrisud និងសហគមន៍កសិកម្មបៃតង បានស្នើឡើងនូវការដាំដុះដំណាំបន្លែ "បស្ចិមប្រទេស" មួយចំនួន (ឧទាហរណ៍ សាឡាត់) ជាធម្មតាមិនត្រូវបានផលិតដោយកសិករក្នុងស្រុកទេ ប៉ុន្តែបានបញ្ចូលទៅក្នុងកសិដ្ឋានដែលមានស្រាប់ ដោយសារការផលិតត្រូវការស្ទួនបន្លែដាំលើរាន ការធ្វើរោងម្លប់ និងបច្ចេកទេសដែលមានខ្យល់ចេញចូល។ Gret និង ECOFARM បានកំណត់យកការធ្វើពិពិធកម្មជាអប្បបរមាក្នុងចំណោមសមាជិករបស់ខ្លួន (ការផលិតបន្លែយ៉ាងតិចបីប្រភេទ) ជាធម្មតាផលិតដំណាំមួយមុខ ឬពីរមុខ និងហាមឃាត់ការប្រើប្រាស់សារធាតុគីមី បើទោះបីជានៅតែអាចប្រើបានក៏ដោយ។

កសិករដាំដំណាំស្រូវក្នុងខេត្តព្រះវិហារ អាចទទួលបានប្រយោជន៍ពីបរិស្ថានអំណោយផល (ការដាំដំណាំសរីរាង្គត្រូវបានអនុវត្តរួចហើយ និងមិនត្រូវការប្រព័ន្ធធារាសាស្ត្រ។ល។) ដើម្បីឆាប់បំពេញតាមលក្ខខណ្ឌយថាប្រភេទសរីរាង្គ ជាមួយនឹងការកែសម្រួលជម្រើសពូជ និង យន្តការប្រមូលផល ឱ្យស្របតាមលក្ខខណ្ឌគុណភាពរបស់អង្ករ (ភាពសុទ្ធរបស់ពូជ សំណើម អត្រាគ្រាប់អង្ករបាក់បែក)។

ប្រអប់លេខ3

## ឧទាហរណ៍នៃខ្សែសង្វាក់តម្លៃស្រូវអង្ករក្នុងខេត្តព្រះវិហារ៖ កិច្ចប្រជុំពហុភាគី ដើម្បីពង្រឹងចំណេះដឹងអំពីលក្ខខណ្ឌគុណភាព

នៅពេលចាប់ផ្តើមគម្រោង SCCRP ក្រុមការងារ AVSF-Iram បានដើរតួនាទីជាអ្នកសម្របសម្រួលការតភ្ជាប់សហគមន៍ផលិតចំនួន 8 ជាមួយនឹងអ្នកនាំចេញអង្ករចំនួន 4 ដែលជាអ្នកទិញសក្តានុពល ដើម្បីពិភាក្សាអំពីលក្ខខណ្ឌគុណភាពដែលរំពឹងទុក។ កិច្ចប្រជុំរួមត្រូវបានធ្វើឡើងដើម្បីបង្ហាញពីបរិបទផលិតកម្ម និងសក្តានុពល ក៏ដូចជាលក្ខខណ្ឌតម្រូវការ៖ តម្រូវការពូជស្រូវក្រអូបដែលវេទរសទៅនឹងរយៈពន្លឺ (ពូជស្រូវប្រកាន់រដូវ) (ប្រភេទពូជស្រូវ "ផ្កាម្លិះ") និងអង្ករស ការអនុលោមតាមស្តង់ដារសរីរាង្គអន្តរជាតិមួយចំនួន (ស្តង់ដារសរីរាង្គសហជីពអឺរ៉ុប – EOS និងស្តង់ដារសរីរាង្គ NOP របស់សហរដ្ឋអាមេរិក) ។ អ្នកទិញក៏បានកំណត់លក្ខណៈវិនិច្ឆ័យគុណភាពបន្ថែមជាបន្តបន្ទាប់ ដោយចាត់ថ្នាក់គុណភាព ឡូតិ៍ស្រូវនីមួយៗរបស់កសិករដែលបានវាយតម្លៃ ដើម្បីកំណត់តម្លៃ៖ ភាពសុទ្ធរបស់ពូជ កម្រិតសំណើម និងអត្រាគ្រាប់អង្ករដែលបាក់បែក។

កិច្ចប្រជុំទាំងនេះបានអនុញ្ញាតឱ្យអ្នកផលិតស្វែងយល់ពីការរំពឹងទុករបស់អ្នកទិញ និងអាចធ្វើការដាក់លក់។ បន្ទាប់ពីកិច្ចពិភាក្សាពេញអង្គ សហគមន៍បានជួបប្រជុំទ្វេភាគីជាមួយអ្នកទិញជាសក្តានុពលនីមួយៗ ដើម្បីពិភាក្សាអំពីលក្ខខណ្ឌនៃការដាក់លក់នីមួយៗ។ ជាលទ្ធផលនៃការបោះជំហានដ៏សំខាន់នេះ គឺការចុះហត្ថលេខាលើកិច្ចសន្យាផ្គត់ផ្គង់ដំបូងរវាងសហគមន៍ និងក្រុមហ៊ុន AMRU-Rice ។

ជាចុងក្រោយ កសិករជាសមាជិករបស់ Agrisud និង Green បានគាំទ្រដល់ការបង្កើតឧបករណ៍កែច្នៃដែលគ្រប់គ្រងដោយសមាជិកមួយចំនួនរបស់ GF និងសម្រាប់លក់ទៅទីផ្សារប្រេងរុក្ខជាតិ គ្រឿងទេសស្ងួត ទឹកផ្លែឈើ ភេសជ្ជៈ។ល។ ដោយបំបែកការអនុវត្តក្នុងស្រុក បច្ចេកទេសនវានុវត្តន៍ពាក់ព័ន្ធនឹងដំណើរការបណ្តុះបណ្តាលដ៏សំខាន់សម្រាប់អ្នកផលិតដែលមិនធ្លាប់ធ្វើការក្នុងអាជីវកម្មប្រភេទនេះពីមុនមក ប៉ុន្តែអនុញ្ញាតឱ្យមានការបញ្ចូលសកម្មភាពបន្ថែមដ៏មានប្រយោជន៍ទៅក្នុងកាលវិភាគសកម្មភាពរបស់គ្រួសារ។

ក្នុងករណីវិស័យកសិដ្ឋានចិញ្ចឹមត្រីថ្មី អ្នកផលិតមានការយល់ដឹងច្បាស់ពីការរំពឹងទុករបស់អ្នកប្រើប្រាស់ ប៉ុន្តែបានជួបឧបសគ្គរាំងស្ទះដោយសារតែកង្វះឯកសារយោងផ្នែកបច្ចេកទេស ដើម្បីបំពេញតាមតម្រូវការនេះ ទោះបីជាមានប្រព័ន្ធផលិតកម្មអាចដំណើរការទៅបានទាំងផ្នែកបច្ចេកទេស និងសេដ្ឋកិច្ចក៏ដោយ។ ដូច្នេះបញ្ហាប្រឈមដំបូងបង្អស់របស់គម្រោង គឺការបង្កើតឯកសារយោងផ្នែកបច្ចេកទេស។ ដើម្បីសម្រេចបានគោលដៅនេះ គម្រោងបានប្រកាន់យកវិធីសាស្រ្តដែលមានការចូលរួមពីកសិករចិញ្ចឹមត្រី ដើម្បីធ្វើតេស្តសាកល្បង និងសហការបង្កើតប្រព័ន្ធចិញ្ចឹមត្រីដែលសមស្របតាមបរិបទបច្ចេកទេស សង្គម និងសេដ្ឋកិច្ចដែលមានសមត្ថភាពផលិតត្រីប្រកបដោយគុណភាពតាមការរំពឹងទុករបស់ខ្លួន (សូមមើលប្រអប់ខាងក្រោម)។

លើសពីនេះ លក្ខណៈពិសេសនៃកសិដ្ឋានចិញ្ចឹមត្រីដែលគាំទ្រដោយ APDRA បើធៀបទៅនឹងវិស័យដែលគាំទ្រដោយសមាជិកផ្សេងទៀតរបស់ Gi គឺផលិតសម្រាប់បរិភោគខ្លួនឯងក្នុងបរិមាណដ៏ច្រើន។ កត្តានេះត្រូវបាន APDRA យកមកពិចារណា ទោះបីជាខ្លួននៅតែមានចក្ខុវិស័យ ក្នុងការអភិវឌ្ឍកសិដ្ឋានចិញ្ចឹមត្រីតាមបែបកសិអេកូឡូស៊ីជាលក្ខណៈគ្រួសារ សម្រាប់គោលបំណងពាណិជ្ជកម្មក៏ដោយ។ អង្គការបានធ្វើការអង្កេតស្វែងយល់ពីគោលបំណងរបស់អ្នកទទួលផល ដើម្បីផ្តល់ឱ្យពួកគេនូវការគាំទ្រដែលត្រូវការ ហើយជាលទ្ធផល បានកំណត់អត្តសញ្ញាណបួនប្រភេទ៖ អ្នកផ្គត់ផ្គង់ពូជកូនត្រីក្នុងស្រុក កសិករចិញ្ចឹមត្រីអាជីពដែលមានសក្តានុពល កសិករដែលចាត់ទុកការចិញ្ចឹមត្រីជាសកម្មភាពបន្ទាប់បន្សំទ្រទ្រង់ទ្រាយតូច និងកសិករដែលងាយរងគ្រោះ។

ឧទាហរណ៍នេះបង្ហាញពីការយកចិត្តទុកដាក់ជាពិសេសរបស់សមាជិក Gi លើភាពចាំបាច់ដែលត្រូវគិតគូរពីផលិតកម្មកសិកម្មសម្រាប់គ្រប់គោលបំណងទាំងអស់ ក៏ដូចជាដំណើរការប្រព័ន្ធផលិតកម្ម និងសកម្មភាពទាំងមូល ដើម្បីស្វែងយល់ឱ្យបានច្បាស់អំពីអន្តរកម្មរបស់កត្តាទាំងនេះជាមួយប្រព័ន្ធអេកូឡូស៊ី និងបរិបទសេដ្ឋកិច្ច-សង្គម ដើម្បីឆ្លុះបញ្ចាំងពីផ្នត់គំនិតរបស់កសិករ។ កត្តានេះអនុញ្ញាតឱ្យមានការតម្រង់ទិសការគាំទ្របានកាន់តែប្រសើរឡើងដល់អ្នក ផលិត ដោយសមាជិក Gi ដៃគូរបស់ខ្លួន និងអ្នកផលិត អាចរួមចំណែកយ៉ាងពេញលេញដល់ដំណើរឆ្ពោះទៅរកប្រព័ន្ធកសិអេកូឡូស៊ីនៅគ្រប់ទិដ្ឋភាពទាំងបរិស្ថាន សេដ្ឋកិច្ច និងសង្គម។ លទ្ធផលនៃកិច្ចអន្តរាគមន៍មួយចំនួនបង្ហាញពីសមត្ថភាព ក្នុងការលើកកម្ពស់ការអនុវត្តប្រព័ន្ធកសិអេកូឡូស៊ី ដោយមិនប៉ះពាល់ដល់គោលការណ៍ ដែលស្តែងឱ្យឃើញ តាមរយៈការកើនឡើងនូវចំនួនសហគមន៍ដែលជាសមាជិករបស់ PMUAC (ពី 5 ទៅ 25 សហគមន៍) និងបរិមាណស្រូវដ៏ច្រើនដែល PMUAC បានលក់ក្នុងមួយឆ្នាំ (ជាមធ្យម 9,600 តោន/ឆ្នាំ ក្នុងរយៈពេល 5 ឆ្នាំចុងក្រោយនេះ ស្ទើរតែស្មើនឹងមួយភាគបីនៃផលិតកម្មស្រូវសរីរាង្គរបស់កម្ពុជា) ក៏ដូចជាចង្ក្រានប្រណីតចំនួន 3 លានដែលបានលក់នៅចន្លោះឆ្នាំ 2004 និង 2013 ដោយមានការគាំទ្រពី Geres ។

ប្រអប់លេខ 4

## ឧទាហរណ៍នៃសកម្មភាពស្រាវជ្រាវដោយមានការចូលរួមពីភាគីពាក់ព័ន្ធលើប្រព័ន្ធកសិដ្ឋានចិញ្ចឹមត្រីជាមួយអ្នកផលិតនៅខេត្តសៀមរាប

កសិករចិញ្ចឹមត្រីអាចផលិតត្រីដែលមានគុណភាពតាមការរំពឹងទុកសម្រាប់បរិភោគក្នុងកម្មវិធីនានា ដូចជាពិធីមង្គលការជាដើម។ ក្នុងអំឡុងវដ្តផលិតកម្មមួយ គាត់ប្រមូលផលត្រីទីឡាព្យាបាន 65 គីឡូក្រាម ដែលមួយក្បាលៗមានទម្ងន់រហូតដល់ 600 ក្រាម នៅអំឡុងខែមីនា ជាខែដែលសម្បូរភ្ញៀវច្រើនក្នុងរដូវរៀបអាពាហ៍ពិពាហ៍។ គាត់អាចលក់វាក្នុងតម្លៃ 2.75 ដុល្លារ/គីឡូក្រាម ក្នុងកម្មវិធីមួយ។ ទិន្នន័យដែលប្រមូលបានក្នុងអំឡុងពេលនៃវដ្តនេះគឺមានតម្លៃជាពិសេសក្នុងការស្វែងយល់ថាតើមានកត្តាអ្វីខ្លះដែលឈានទៅដល់លទ្ធផលបែបនេះ។ គាត់ចេះអនុវត្តយុទ្ធសាស្ត្ររក្សាតុល្យភាពចំណី ដោយផ្លាស់ប្តូរពីចំណីដែលមានជាតិអាសូតខ្ពស់ក្នុងរដូវវស្សា ទៅជាចំណីដែលមានជាតិកាបូនខ្ពស់ និងកន្ទក់នៅពេលទឹកស្រក។ ការធ្វើបែបនេះបានការពារទឹកមិនឱ្យធ្លាក់ចុះគុណភាព និងការបំពុលដោយសារជាតុអាម៉ូញាក់ ដោយរក្សាបាននូវកម្រិតផលិតភាពតាមបែបធម្មជាតិបានយ៉ាងល្អ។ ខណៈដែលអត្រារស់មានកម្រិតទាបខ្លាំង (22%) គាត់ក៏ទំនងជាមិនអាចប្រមូលផលត្រី ដែលមានទម្ងន់ដូចៗគ្នាតាមការចង់បានជាមួយនឹងអត្រារស់ខ្ពស់នោះដែរ ដោយសារតែការទទួលបានទឹកប្រើប្រាស់តិចតួច និងកង្វះអុកស៊ីសែន។ កត្តានេះនាំទៅដល់ការផ្តល់អនុសាសន៍ឱ្យពិចារណាលើចំនួនស្តុកត្រី និងការរួមបញ្ចូលគ្នាជាមួយប៉ារ៉ាម៉ែត្រផ្សេងទៀតដូចជា ធនធានអាហារ ការទទួលបានទឹកប្រើប្រាស់ ឬទំហំត្រីគោលដៅ។ ពីវដ្តមួយទៅវដ្តមួយទៀត កសិកររូបនេះបានរៀនសូត្រពីកំហុសឆ្គងរបស់ខ្លួន និងកំពុងធ្វើការកែលម្អរបៀបចិញ្ចឹមត្រីជាជំហានៗ។



កសិករឈ្មោះ រេម សឿង (ឆ្វេង) ប្រមូលផលត្រីទីឡាព្យា

វិធីសាស្ត្ររួមនេះការពារមិនឱ្យមានការពឹងផ្អែកខ្លាំងពេកទៅលើផលិតផល ឬទីផ្សារតែមួយ ដើម្បីអាចឱ្យគ្រប់គ្រងហានិភ័យកាន់តែប្រសើរឡើង។ ជាឧទាហរណ៍ វិបត្តិនៃជំងឺកូវីដបានធ្វើឱ្យវិស័យទេសចរណ៍ក្នុងខេត្តសៀមរាប មានការធ្លាក់ចុះយ៉ាងខ្លាំង ក៏ដូចជាតម្រូវការផលិតផលអាហារផងដែរ។ ទន្ទឹមនឹងការថយចុះនូវហាងរបស់សហគមន៍កសិកម្មបែតងដ៏សំខាន់នេះ ក៏មានការធ្លាក់ចុះយ៉ាងខ្លាំងផងដែរនូវចំនួនសមាជិកភាពរបស់សហគមន៍ (ពីជាង 800 នាក់ក្នុងឆ្នាំ 2020 មកនៅក្រោម 500 គិតត្រឹមថ្ងៃនេះ)។ ទោះជាយ៉ាងនេះក្តី ការរក្សានូវហាងចម្រុះសម្រាប់អ្នកប្រើប្រាស់ក្នុងស្រុក (ការលក់ដោយផ្ទាល់នៅក្នុងស្រុក ការលក់ទៅឱ្យឈ្មួញប្រមូលទិញក្នុងស្រុក ដែលដើរតួនាទីជាតំណភ្ជាប់ទៅកាន់ទីផ្សារលក់ដុំនៃខេត្តសៀមរាប) បានអនុញ្ញាតឱ្យអាជីវកម្មរបស់សហគមន៍កសិកម្មបែតង និងសមាជិករបស់ខ្លួន រក្សាបានសមត្ថភាពបំពេញតាមតម្រូវការរបស់សណ្ឋាគារដែលបានចាប់ផ្តើមបើកដំណើរការអាជីវកម្មរបស់ខ្លួនឡើងវិញជាបណ្តើរៗ។

ជាចុងក្រោយ ការកសាងគុណភាពនេះបានលេចចេញជារូបរាងឡើង ជាមួយនឹងការបង្កើតយថាប្រភេទផ្ទៃក្នុងក្នុងអង្គភាព ដើម្បីណែនាំសមាជិករបស់ខ្លួន។ ដោយមិនគិតពីប្រភេទផលិតកម្ម ទីផ្សារគោលដៅ ការត្រួតពិនិត្យផ្ទៃក្នុង និងប្រព័ន្ធបញ្ជាក់គុណភាពនេះ ត្រូវបានកំណត់ជាផ្លូវការ។ ការគាំទ្រដែលផ្តល់ដោយសមាជិករបស់ Gi គឺជាគន្លឹះ ទាំងនៅក្នុងលក្ខខណ្ឌនៃខ្លឹមសារ និងនៅក្នុងដំណើរការនៃការអភិវឌ្ឍ ភាពជាម្ចាស់ និងសុពលភាព។

ប្រអប់លេខ5

## ឧទាហរណ៍នៃការបញ្ជាក់យថាប្រភេទខាងក្នុងរបស់ ECOFARM សម្រាប់បន្លែសុខភាព

- ប្រភេទនៃការផលិត៖ ផលិតបន្លែស្លឹក ឬផ្លែឈើយ៉ាងតិចបីប្រភេទ
- ការជ្រើសរើសពូជ៖ គ្រាប់ពូជក្នុងស្រុក/ពូជដែលបានបង្កាត់នៅទីវាល/ពូជកូនកាត់ដែលផ្តល់ដោយអ្នកផ្គត់ផ្គង់សម្ភារកសិកម្ម (F1)។ F1 គឺជាពូជកូនកាត់ ហើយមិនអាចយកមកប្រើឡើងវិញសម្រាប់ជំនាន់ក្រោយទេ។ ប្រភេទ GMOs ត្រូវបានហាមឃាត់។
- ការការពារឡូតិ៍៖ ឡូត៍/កសិដ្ឋានដែលបានបង្កើតឡើងសម្រាប់ការដាំបន្លែសុវត្ថិភាព ត្រូវស្ថិតនៅដាច់ដោយឡែកពីឡូត៍ដែលប្រើសារធាតុគីមី
- ការគ្រប់គ្រងជីជាតិដី៖ ជីធម្មជាតិ (ជីកំប៉ុសរឹង លាមកសត្វ ជីជីវម៉ាសតាមសមាមាត្រ 1.5-2 គ.ក្រ/ម²) អាស្រ័យលើការលូតលាស់របស់ដំណាំ។
- ការគ្រប់គ្រងសត្វល្អិតចង្រៃ៖ ប្រើថ្នាំកសិកម្មក្នុងស្រុកដែលផលិតតាមបែបធម្មជាតិតែប៉ុណ្ណោះ។ បន្តបាញ់ថ្នាំកសិកម្មបែបធម្មជាតិរៀងរាល់ 3-5 ថ្ងៃម្តង ប្រើវិធានការចម្រុះគ្រប់គ្រងសត្វល្អិត (IPM)
- វិធីសាស្រ្តដាំដុះ៖ ដំណាំរួមផ្សំ និងដំណាំឆ្លាស់
- ការគ្រប់គ្រងដំណាំ៖ បញ្ឈប់ការបាញ់ថ្នាំកសិកម្មធម្មជាតិយ៉ាងតិច 7 ថ្ងៃមុនពេលប្រមូលផល ហើយឈប់ប្រើជីកំប៉ុសរាវយ៉ាងតិច 7 ថ្ងៃមុនពេលប្រមូលផល។
- គុណភាពរំពឹងទុក៖ បន្លែចម្រុះ ស្រស់ រូបរាងល្អ ផ្គត់ផ្គង់ជាប្រចាំ

**ផ្អែកតាមបទពិសោធន៍នៃការធ្វើអន្តរាគមន៍របស់សមាជិក ៣ បង្ហាញថាលក្ខខណ្ឌតម្រូវការ និងលក្ខណៈគុណភាពសម្រាប់ការដាក់លក់នៅលើទីផ្សារ ត្រូវបានយល់ក្នុងចំណោមក្រុមអ្នកផលិត ដែលជាធម្មតានាំទៅដល់ការបង្កើតអង្គភាពដែលមានរចនាសម្ព័ន្ធច្បាស់លាស់។**

# អង្គភាពជាចេនាសម្ព័ន្ធដ៏សំខាន់សម្រាប់ការគ្រប់គ្រងគុណភាព និងចូលទៅកាន់ទីផ្សារ

ជាទូទៅ ការបញ្ចូលក្រុមអ្នកផលិត និងសិប្បករ ទៅក្នុងអង្គភាពមួយ គឺជាវិធីសាស្ត្រមួយដែលបានប្រើដោយភាគីពាក់ព័ន្ធនឹងវិស័យ អភិវឌ្ឍន៍ ដោយមើលឃើញថានោះគឺជាឱកាសមួយ ដើម្បីគាំទ្រ អ្នកទទួលផលមួយចំនួនធំ អាចឱ្យពួកគេប្រមូលផ្តុំកត្តាផលិតកម្ម និង/ឬពង្រឹងតួនាទី និងការតស៊ូមតិរបស់ខ្លួននៅក្នុងខ្សែសង្វាក់តម្លៃ និងដែនដីដែលពួកគេចូលរួម។ ផ្អែកតាមបទពិសោធន៍របស់ សមាជិក Gi បង្ហាញពីតម្លៃបន្ថែមនៃការបង្កើតអង្គភាពអ្នកផលិត ដើម្បីធ្វើសមាហរណកម្មខ្សែសង្វាក់តម្លៃ និងអាចគ្រប់គ្រងគុណភាពនៅពេលដែលអ្នកផលិតបានកំណត់គោលដៅរួមច្បាស់លាស់។

ប្រអប់លេខ6

**បញ្ហាទាក់ទងនឹងអង្គភាព ការគ្រប់គ្រងគុណភាព និងការអភិវឌ្ឍនអាជីវកម្ម**

- តើមានដំណើរការ និងជំហានអ្វីខ្លះក្នុងការបង្កើតអង្គភាព ?
- តើអង្គភាពគ្រប់គ្រងគុណភាពដោយរបៀបណា ?
- តើអង្គភាពអភិវឌ្ឍទីផ្សារយ៉ាងដូចម្តេច ?
- តើលក្ខខណ្ឌនិរន្តរភាពរបស់អង្គភាព មានអ្វីខ្លះ ?

## ការបង្កើតអង្គភាពដែលមានគោលដៅរួម និងមុខងារដែលបានកំណត់

អង្គភាពត្រូវបានបង្កើតឡើងជាផ្នែកមួយនៃកិច្ចអន្តរាគមន៍របស់សមាជិក Gi ជាលទ្ធផលនៃការកំណត់តម្រូវការរួមរបស់ក្រុមអ្នកផលិត ដើម្បីសម្រេចបានគុណភាពដែលបានកំណត់។ ចរិតលក្ខណៈ និងមុខងាររបស់អង្គភាព អាស្រ័យលើកម្រិតនៃការរៀបចំអង្គភាពអ្នកផលិតដែលមានរួចជាស្រាប់ ប្រភេទស្លាកគុណភាពគោលដៅ (វិធីសាស្ត្រខាងក្នុង ការធ្វើវិញ្ញាបនកម្មខាងក្រៅ) ប្រព័ន្ធត្រួតពិនិត្យគុណភាពមូលដ្ឋាន និងវិធីសាស្ត្រទីផ្សារ (ជាលក្ខណៈបុគ្គល ឬសមូហភាព)។

លក្ខណៈស្របច្បាប់នៃអង្គភាពទាំងនេះ គឺអាស្រ័យលើការកំណត់គោលបំណងរួម និងមុខងារច្បាស់លាស់ និងដំណើរការចូលរួមជាបន្តបន្ទាប់ក្នុងទម្រង់ដែលបានកំណត់។ ដំណើរការនេះប្រព្រឹត្តទៅជាបន្ត ដោយអង្គភាពត្រូវសម្របទៅតាមការវិវត្តនៃយុទ្ធសាស្ត្ររបស់ខ្លួន។ ឧទាហរណ៍ ក្រុមកសិករបៃតងត្រូវបានបង្កើតឡើងក្នុងឆ្នាំ 2018 ជាសមាគមមួយដែលតាមរយៈនេះ អនុញ្ញាតឱ្យខ្លួនផ្សព្វផ្សាយផលិតផលរបស់សមាជិកខ្លួនដែលជាអ្នកលក់ផលិតផលពីសួនបន្លែរបស់ខ្លួននៅលើទីផ្សារជាលក្ខណៈបុគ្គល និងរៀបចំការត្រួតពិនិត្យគុណភាព។ សមាគមនេះក៏ពឹងផ្អែកលើអង្គភាពមូលដ្ឋានដែលបង្កើតឡើងរួចជាស្រាប់នៅក្នុងសហគមន៍ ដោយអនុគ្រោះលើទម្រង់នៃការត្រួតពិនិត្យ និងគ្រប់គ្រងសង្គមមួយចំនួន។ បច្ចុប្បន្ន សហគមន៍កសិកម្មបៃតង មានសមាជិកចំនួន 419 នាក់ ដែលបានធ្វើសកម្មភាពបោះជំហានចូលទៅក្នុងទីផ្សារដោយផ្ទាល់កាន់តែច្រើនឡើងៗ ហើយសមាគមកំពុងពិចារណាប្រែក្លាយទៅជាសហគ្រាសសង្គម។

សមាជិក ECOFARM បានដើរនាទីតាមមាគ៌ាស្រដៀងគ្នា៖ ដោយមានតម្រូវការក្នុងការបង្កើតស្តង់ដារសមូហភាពសម្រាប់ផលិតផលដែលមានសុវត្ថិភាព និងតាមការចង់របស់អ្នកផលិតដែលគាំទ្រដោយគម្រោង APICI ក៏បានសម្របសម្រួលបង្កើតក្រុម ECOFARM នៅឆ្នាំ 2015។ បន្ទាប់មកកសិករជាំជុះមានបំណងធ្វើពិពិធកម្មយុទ្ធសាស្ត្ររបស់ខ្លួនតាមរយៈការលក់ជាសមូហភាព ដើម្បីបង្កើនបរិមាណលក់ និងទទួលបានទីផ្សារថ្មី រហូតឈានដល់ការចុះបញ្ជី ECOFARM ជាផ្លូវការក្នុងទ្រង់ទ្រាយជាសហគមន៍កសិកម្មនៅឆ្នាំ 2019។ ដំណើរការនេះធ្វើឡើងជាច្រើនដំណាក់កាល៖ ការបង្ហាញច្បាប់ស្តីពីសហគមន៍កសិកម្មដល់សមាជិក ការធ្វើសេចក្តីព្រាងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ AC ការកោះប្រជុំមហាសន្និបាតលើកដំបូង ដើម្បីធ្វើសេចក្តីសម្រេចរៀបចំឯកសារចុះបញ្ជីស្របច្បាប់។ ការវិវត្តនេះរាប់បញ្ចូលទាំងការ អនុលោមតាមលក្ខខណ្ឌគុណភាព ដោយបានកាត់បន្ថយចំនួនអ្នកផលិតដែលពាក់ព័ន្ធ។ អ្នកផលិត 60 នាក់ ក្នុងចំណោមអ្នកផលិតចំនួន 313 នាក់ដែលបានកំណត់អត្តសញ្ញាណនៅពេលចាប់ផ្តើមគម្រោង បានបង្កើត ECOFARM នៅឆ្នាំ 2015 ហើយបច្ចុប្បន្ន មានចំនួន 125 នាក់ ក្នុងនោះ 71 នាក់ជាអ្នកដាំបន្លែ។

ស្រដៀងគ្នាដែរ អ្នកផលិតចង្ក្រានប្រណីតដែលគាំទ្រដោយ Geres ត្រូវផ្លាស់ប្តូរអង្គភាពរបស់ខ្លួន នៅពេលដែលយុទ្ធសាស្ត្រផ្តល់សំណងផ្អែកលើគុណភាពរបស់ខ្លួន បានផ្លាស់ប្តូរពីប្រព័ន្ធទូទាត់សេវាបរិស្ថាន (ឥណទានកាបូន) ទៅជាការកែច្នៃផលិតផលឱ្យខុសប្លែកពីគេនៅលើ ទីផ្សារផ្តល់តម្លៃបុព្វលាភបន្ថែម

លើគុណភាព។ ជាការពិតណាស់ អស់រយៈពេលជិតដប់ឆ្នាំមកហើយ (2004-2013) ឥណទានកាបូនដែលផលិតបាន អនុញ្ញាតឱ្យអ្នកផលិត និងអ្នកចែកចាយ អាចរ៉ាប់រងថ្លៃដើមមួយភាគធំលើការផលិត និងការត្រួតពិនិត្យគុណភាពរបស់ខ្លួន ហើយអាចឱ្យពួកគេលក់ចង្ក្រានប្រណីតដែលមានស្លាករបស់ខ្លួនក្នុងតម្លៃឧបត្ថម្ភធនជាមួយនឹងអត្រាប្រាក់ចំណេញសមរម្យ។ ពួកគេត្រូវបានប្រមូលផ្តុំជាសមាគមមួយ (អ្នកផលិតរហូតដល់ 52 នាក់ និងអ្នកចែកចាយ 113 នាក់) ដើម្បីចាប់យកតម្លៃបន្ថែមពីឥណទានកាបូន។ នៅពេលដែលអស់ឥណទានកាបូន មានការងាកទៅរកការវាយតម្លៃគុណភាពនៅលើទីផ្សារ ដែលនាំឱ្យមានការផ្លាស់ប្តូរគំរូដែលសមាជិកស្ទើរតែទាំងអស់មិនបានរំពឹងទុកជាមុន និងមិនយល់ពេលគឺ នៅតែមានការយល់ឃើញថាស្លាកផលិតផល (ដែលត្រូវការជាចាំបាច់ដើម្បីទទួលបានឥណទានកាបូន) គឺជាឧបសគ្គមួយដដែល ព្រោះគេមិនយល់ថាស្លាកនេះជាមធ្យោបាយមួយនៃការបែកចែកភាពខុសគ្នារបស់ផលិតផលនៅលើទីផ្សារនោះទេ។ អ្នកផលិត និងអ្នកចែកចាយមិនមានមូលដ្ឋានរួម ក្នុងការបញ្ចូលចំណាយបន្ថែមលើការគ្រប់គ្រង គុណភាពទៅក្នុងតម្លៃលក់ ឬទៅក្នុងការអភិវឌ្ឍពាណិជ្ជកម្មនោះទេ។ លើសពីនេះទៀត ពួកគេហាក់ដូចជាមិនបានទាញយកចំណែកពីការវិវត្តនៃបរិយាកាសខ្សែសង្វាក់តម្លៃ ដែលកាន់តែមានការប្រកួតប្រជែងខ្លាំងនោះទេ (សូមមើលរូបខាងក្រោម)។ ដូច្នេះសមាគម CESPA ថ្មីបានកែសម្រួលសកម្មភាពរបស់ខ្លួនឡើងវិញ ដោយផ្តោតលើអ្នកផលិតមួយចំនួនតូចតែប៉ុណ្ណោះ (25 នាក់ក្នុងឆ្នាំ 2023) ដែលមានបំណងកំណត់គោលដៅទីផ្សារផ្តល់តម្លៃ បុព្វលាភបន្ថែមលើគុណភាព។




**រូបទី 1: ការប្រែប្រួលសំខាន់ៗនូវបរិបទខ្សែសង្វាក់តម្លៃចង្ក្រានប្រណីតរវាងយុគសម័យហិរញ្ញប្បទានកាបូន និងរយៈពេលអនុវត្តគម្រោង SEFED (ប្រភព: Geres)**

ការបង្កើត PMUAC បានផ្តួចផ្តើមឡើងដោយសហគមន៍កសិកម្មដែលមានស្រាប់នៅក្នុងដំណើរការចូលរួមមួយបន្ទាប់ពីកិច្ចប្រជុំសាកល្បងលើកដំបូង។

លក្ខខណ្ឌនៃការបញ្ជាក់យថាប្រភេទសរីរាង្គ (សូមមើលប្រអប់ខាងក្រោម)។

ប្រអប់លេខ 7

## ដំណើរការបង្កើត PMUAC (វិស័យស្រូវអង្ករ)

ក្នុងឆ្នាំ 2013 ការត្រួតពិនិត្យអនុលោមភាពនៃផលិតផលសរីរាង្គកម្រិតដំបូង ត្រូវបានធ្វើឡើងដោយសមាគមកសិកម្មសរីរាង្គកម្ពុជា (COrAA) និងផ្តល់មូលនិធិដោយគម្រោង SCCRP ។ បញ្ហានិរន្តរភាពបានលេចឡើងភ្លាមៗ។ Iram បានធ្វើការកត់សម្គាល់ស្វែងរកសេណារីយ៉ូដើម្បីរៀបចំ និងទទួលយកមុខងារត្រួតពិនិត្យ និងផ្តល់វិញ្ញាបនបត្រជាអចិន្ត្រៃយ៍។ ខ្លួនក៏បានផលិតឧបករណ៍ Excel ដើម្បីបង្កើតគំរូសេណារីយ៉ូថ្លៃដើម និងបរិមាណតាមមាត្រដ្ឋានខុសៗគ្នា។ ឧបករណ៍នេះបានក្លាយជាមូលដ្ឋានមួយសម្រាប់សិក្ខាសាលាពិគ្រោះយោបល់ដែលបានប្រារព្ធធ្វើឡើងអំឡុងខែមីនា ឆ្នាំ 2015 ជាមួយនឹងសហគមន៍កសិកម្មទាំងប្រាំបីដែលពាក់ព័ន្ធ និងអ្នកទិញរបស់ខ្លួន។ សេណារីយ៉ូខុសៗគ្នាត្រូវបានធ្វើការបង្ហាញ និងពិភាក្សា ជាពិសេសមុខងារត្រួតពិនិត្យ និងគ្រប់គ្រងនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង៖

- រៀបចំផ្ទៃក្នុងនៅកម្រិតសហគមន៍កសិកម្ម (AC)៖ ជ្រើសរើសបុគ្គលិកនៅកម្រិតសហគមន៍ (តាមរដូវកាល ឬពេញមួយឆ្នាំ/ពេញម៉ោង ឬក្រៅម៉ោង)។
- រៀបចំផ្ទៃក្នុងនៅកម្រិតអន្តរសហគមន៍៖ ប្រមូលផ្តុំធនធានក្នុងការជ្រើសរើសបុគ្គលិកសម្រាប់សហគមន៍មួយចំនួន (អាចធ្វើឡើងតាមរយៈសហជីពផ្លូវការរបស់សហគមន៍ ឬតាមកិច្ចសន្យាក្រៅម៉ោងសម្រាប់សហគមន៍នីមួយៗ និងកិច្ចព្រមព្រៀងបែងចែកពេលវេលាទៅវិញទៅមក)។
- ប្រើប្រាស់សេវាខាងក្រៅ៖ ជួលអ្នកផ្តល់សេវាតាមកិច្ចសន្យាការងារ (ដូចបានធ្វើរួចជាមួយ COrAA ក្នុងឆ្នាំ 2013)។

បន្ទាប់ពីការឆ្លុះបញ្ចាំងជាច្រើនដំណាក់កាលរួចមក ពួកគេមានអារម្មណ៍ថាជម្រើសទីមួយមិនអាចធ្វើទៅបាននៅកម្រិតសហគមន៍កសិកម្មនោះទេ ដោយសារវាមានទំហំតូច និងមានជម្រើសដំណោះស្រាយក្នុងការប្រមូលផ្តុំធនធានរវាងសហគមន៍កសិកម្ម ដោយជ្រើសរើសបុគ្គលិកអចិន្ត្រៃយ៍។ គោលការណ៍នៃការបង្កើតសហភាពសហគមន៍កសិកម្ម ត្រូវបានសម្រេចនៅពេលនោះ រួចឆ្លងការអនុម័តពីមហាសន្និបាតដែលធ្វើឡើងនៅសហគមន៍កសិកម្មនីមួយៗក្នុងចំណោមសហគមន៍កសិកម្មទាំង 8 ។ គួរកត់សម្គាល់ថាការសម្រេចចិត្តបង្កើតរចនាសម្ព័ន្ធនេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងកំណត់មុខងារឱ្យបានច្បាស់លាស់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការដែលបានកំណត់យ៉ាងច្បាស់។ បច្ចុប្បន្ន PMUAC មានសហគមន៍កសិកម្មចំនួន 25 ដែលក្នុងនោះមានសមាជិកគ្រួសារចំនួន 5,403 នាក់។

ផ្អែកតាមហេតុផលតែមួយក្នុងការបង្កើតអង្គភាព ដោយផ្អែកលើតម្រូវការដែលបានកំណត់ កសិករចិញ្ចឹមត្រីដែលគាំទ្រដោយ APDRA មិនទាន់បានចាប់ផ្តើមគិតអំពីតម្លៃនៃការបង្កើតអង្គភាពក្នុងគោលបំណងគ្រប់គ្រងពាណិជ្ជកម្ម ឬគុណភាពនៅឡើយទេ ព្រោះបរិមាណ និងគុណភាពដែលផលិតរហូតមកដល់ពេលនេះ មិនមានតុល្យភាពគ្រប់គ្រាន់ ក្នុងការកំណត់ឈ្មួញកណ្តាលគោលដៅជាសមូហភាពនោះទេ។ ទោះជាយ៉ាងណា ដោយមានការកែលម្អនូវវដ្តផលិតកម្មនាពេលថ្មីៗនេះ វាពិតជានឹងរួមចំណែកដល់ការពិភាក្សាក្នុងចំណោមកសិករចិញ្ចឹមត្រី និងក្នុងការបង្កើតអង្គភាព។

បទពិសោធន៍ទាំងនេះ បានក្រើនរំលឹកថា ការបង្កើត និងថែរក្សាអង្គភាពមួយ អាចមាននិរន្តរភាពបានលុះត្រាតែជាដំបូងត្រូវមានការជំរុញលើកទឹកចិត្តដល់ពួកគេពីសំណាក់អ្នកផលិត រួមទាំងហានិភ័យដែលអង្គភាព នឹងត្រូវពឹងផ្អែកទាំងស្រុងតែលើអង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រពួកគេ ហើយនឹងដួលរលំនៅគម្រោងត្រូវបានបញ្ចប់។ លើសពីនេះ ផ្អែកតាមបទពិសោធន៍របស់សមាជិក Gi បានបង្ហាញថា ការជ្រើសរើសគុណភាព និងការបង្កើតសមូហភាព មិនមែនជាដំណើរការឆបគ្នាទេ។ ជាលទ្ធផល ចំនួនសមាជិករបស់អង្គភាពទាំងនេះ អាចនឹងត្រូវបានកាត់បន្ថយ បើធៀបទៅនឹងពេលចាប់ផ្តើមគម្រោង។ តាមរយៈបទពិសោធន៍ទាំងនេះ យើងអាចកំណត់បាននូវបញ្ហាប្រឈម និងលក្ខខណ្ឌដែលនៅពីក្រោយការបង្កើត លក្ខណៈគតិយុត្ត និងការថែរក្សាអង្គភាពអ្នកផលិតឱ្យបានគង់វង្ស។

ផ្អែកតាមបទពិសោធន៍នៃការធ្វើអន្តរាគមន៍របស់សមាជិក Gi បានបង្ហាញពីភាពចាំបាច់ក្នុងការបង្កើតអង្គភាពអ្នកផលិត ដើម្បីកំណត់គុណភាពជាផ្លូវការតាមវិធីជាក់លាក់មួយ ដោយធ្វើការត្រួតពិនិត្យគុណភាពដែលពាក់ព័ន្ធ និងពង្រឹងសមត្ថភាពផលិតកម្មរបស់កសិករ។

អង្គភាព ECOFARM និងសហគមន៍កសិកម្មបៃតង បានជ្រើសរើសប្រព័ន្ធត្រួតពិនិត្យទៅវិញទៅមករវាងអ្នករួមអាជីព។ ប្រព័ន្ធទាំងនេះអនុញ្ញាតឱ្យអ្នកផលិតទទួលបានភាពម្ចាស់ការពិតប្រាកដបញ្ហាគុណភាព ត្រូវបានសម្របតាមបរិបទផលិតកម្ម និងមានតម្លៃសមរម្យសម្រាប់អង្គភាពអ្នកផលិតគ្រប់ទ្រង់ទ្រាយទាំងអស់។ ECOFARM បានប្រកាន់យកវិធីសាស្ត្រចូលរួមពេញលេញ ដោយជ្រើសរើសអនុវត្តប្រព័ន្ធធានាដែលមានការចូលរួម (PGS)។

ប្រអប់លេខ៥

## និយមន័យអំពីប្រព័ន្ធធានាដែលមានការចូលរួម (PGS)

វិញ្ញាបនបត្រ PGS ដែលមានការចូលរួម និងមិនគិតថ្លៃ គឺផ្អែកតាមការត្រួតពិនិត្យទៅវិញទៅមករវាងអ្នករួមអាជីព។ ការលើកកម្ពស់បណ្តាញភាគីពាក់ព័ន្ធនៅក្នុងដែនកសិកម្មនេះ គឺស្របតាមវិធីសាស្ត្រជាជំហានៗ។ PGS គឺជាប្រព័ន្ធធានាគុណភាពដែលផ្អែកលើប្រព័ន្ធផ្តល់វិញ្ញាបនបត្រសម្រាប់អ្នកផលិតយោងទៅតាមសកម្មភាពចូលរួមរបស់ភាគីពាក់ព័ន្ធ និងផ្អែកលើការជឿទុកចិត្ត បណ្តាញសង្គម និងការផ្លាស់ប្តូរចំណេះដឹង។ ចំពោះ ECOFARM៖

- ស្តង់ដារគុណភាព PGS ត្រូវបានបង្កើតឡើងដោយអ្នកផលិតនៅក្នុងសហគមន៍ខ្លួនឯង ដើម្បីធានាបំពេញតម្រូវការរបស់ខ្លួន ហើយអាចអនុវត្តស្តង់ដារនោះបាន។
- PGS ទាមទារឱ្យមានការបង្កើតគណៈកម្មាធិការផ្ទៃក្នុងមួយ ដើម្បីពិនិត្យផ្ទៀងផ្ទាត់នៅនឹងកន្លែងឱ្យប្រាកដថាផលិតផលរបស់ខ្លួនមានគុណភាពល្អ និងមានសុវត្ថិភាពចំពោះអ្នកប្រើប្រាស់ ស្របតាមសំណុំលក្ខណៈវិនិច្ឆ័យ។
- ប្រព័ន្ធផ្ទៃក្នុងនេះចំណាយថវិកាតិចតួច បើធៀបទៅនឹងការអន្តរាគមន៍របស់ភាគីទីបី ព្រោះភាគច្រើនទាមទារឱ្យគណៈកម្មាធិការផ្ទៃក្នុងចំណាយពេលលើការចុះត្រួតពិនិត្យដល់កន្លែង និងចេញវិញ្ញាបនបត្រប្រចាំឆ្នាំ ហើយមិនតម្រូវឱ្យបង់ថ្លៃវិញ្ញាបនបត្រខាងក្រៅទេ។




ក្រុមអ្នកផលិតមកពីសហគមន៍ ECOFARM ធ្វើការរៀបចំបន្លែសុវត្ថិភាព (លាងសម្អាត បែងចែកតាមប្រភេទ) មុននឹងដាក់លក់ - ខេត្តសៀមរាប ©Gret

ដំណាក់កាលសំខាន់នៃប្រព័ន្ធ PGS ត្រូវបានពិពណ៌នានៅក្នុងរូបភាពខាងក្រោម។ វាមានការចូលរួមពីភាគីពាក់ព័ន្ធជាច្រើន (អ្នកអនុវត្តគម្រោង)៖ តំណាងក្រុមសហគមន៍ (GRs) ទីប្រឹក្សាផ្នែកកសិអេកូឡូស៊ី គណៈកម្មាធិការគ្រប់គ្រងសហគមន៍ (MC, សមាជិកក្រុមប្រឹក្សាភិបាល ECOFARM) និងគណៈកម្មាធិការវិញ្ញាបនកម្ម (CC, ចាស់ព្រឹទ្ធាចារ្យនៅក្នុងភូមិឃុំ តំណាងមន្ទីរកសិកម្ម និងអ្នកប្រើប្រាស់)។




**រូបទី 2៖ ដំណើរការធានាគុណភាពនៃប្រព័ន្ធ PGS របស់ ECOFARM (ប្រភព៖ Gret)**

ដោយសារទីផ្សារក្នុងស្រុកគឺជាគោលដៅមួយរបស់ ECOFARM ដូច្នេះការអនុវត្តគឺពាក់ព័ន្ធនឹងប្រព័ន្ធ PGS ដោយសារវាមានទំនាក់ទំនងជាមួយនឹងភាគីពាក់ព័ន្ធក្នុងស្រុកទាំងអស់ ដើម្បីជំរុញឱ្យមានទំនុកចិត្តទៅលើគុណភាព និងអង្គភាពពីអ្នកទាំងនោះ។ ប្រព័ន្ធ PGS បានជួយពង្រឹងសមត្ថភាពរបស់អ្នកផលិត ក្នុងការផលិត និងស្វែងរកទីផ្សារផលិតផលសុវត្ថិភាពក្នុងស្រុក។បច្ចុប្បន្ន សហគមន៍មានសមត្ថភាពលក់បន្លែបាន 7 តោនក្នុងមួយខែ។ លើសពីនេះទៀត PGS គឺជាកន្លែងប្រមូលផ្តុំ និងជាមជ្ឈមណ្ឌលនវានុវត្តន៍នៅជុំវិញតំបន់នៃខេត្តសៀមរាប៖ ក្នុងអំឡុងពេលអនុវត្តគម្រោង មានអ្នកចូលរួមជាង 900 នាក់ (អ្នកផលិត តំណាងសហគមន៍ សិស្សានុសិស្ស អាជ្ញាធររដ្ឋាភិបាល) បានចុះទស្សនកិច្ចមកកាន់ទីតាំងរបស់ ECOFARM ជាពិសេស ដើម្បីស្វែងយល់ពីប្រព័ន្ធ PGS ។ ការចាប់ដៃគូ សហការជាមួយមន្ទីរកសិកម្មខេត្តក្នុងក្របខណ្ឌគម្រោង APICI បានរួមចំណែកយ៉ាងធំធេងដល់ការទទួលស្គាល់ប្រព័ន្ធ PGS នេះ។

ក្នុងករណី Green Farmers ការត្រួតពិនិត្យផ្ទៃក្នុងត្រូវបានអនុវត្តរវាងអ្នកផលិតនិងអ្នកផលិតដូចគ្នា ពោលគឺ "កសិករចំណាន" តាមរយៈការចុះទៅកាន់កសិដ្ឋាន រួមទាំងការពិនិត្យតាមដានបន្ថែម



សួនដាំបន្លែលើរានរៀបចំដោយ ECOFARM

ប្រចាំខែរបស់ការិយាល័យ GF ។ ប្រព័ន្ធនេះក៏ជាវិធីសាស្ត្រចំណាយអស់តិចផងដែរ។ ទោះជាយ៉ាងណា ប្រព័ន្ធត្រួតពិនិត្យ និងយថាប្រភេទសម្រាប់វិធីសាស្ត្រនេះ គឺមានការប្រែប្រួល។ ជាការពិត សហគមន៍កសិកម្មបៃតង យល់ឃើញថាការត្រួតពិនិត្យទៅវិញទៅមករវាងអ្នករួមអាជីពនេះ គឺជាជំហានដំបូងក្នុងការពង្រឹងសមត្ថភាពឆ្ពោះទៅរកការធ្វើវិញ្ញាបនកម្មខាងក្រៅ (GMP – ការអនុវត្តការផលិតល្អ, CS – ស្តង់ដារកម្ពុជា HACCP, ISO) ដែលខ្លួនជឿថាជាតម្រូវការចាំបាច់ ដើម្បីពង្រឹងភាពជឿជាក់ក្នុងការអនុវត្ត។ GF មានគោលបំណងឈានចូលទៅក្នុងទីផ្សារនាំចេញផលិតផលមួយចំនួនដែលកែច្នៃដោយក្រុមរបស់ខ្លួន (ភេសជ្ជៈ)។ ប្រព័ន្ធត្រួតពិនិត្យទៅវិញទៅមករវាងអ្នករួមអាជីពនេះ ប្រព្រឹត្តទៅជាលក្ខណៈទ្រង់ទ្រាយធំដែលគ្របដណ្តប់លើ កសិដ្ឋានជាលក្ខណៈគ្រួសារជាង 1,000 កន្លែង។

ប្រព័ន្ធត្រួតពិនិត្យទៅវិញទៅមករវាងអ្នករួមអាជីព បានលើកទឹកចិត្តឱ្យមានការចូលរួមរបស់យុវជន ដែលជាទូទៅចេះអក្សរច្រើនដើម្បីចុះពិនិត្យតាមដាន ជាពិសេស ដើម្បីចងក្រង ឯកសារស្តីពីគុណភាព និងការអនុវត្តនៅក្នុងសៀវភៅកំណត់ហេតុតាមដាន។ បន្ថែមលើប្រព័ន្ធត្រួតពិនិត្យ ការពិភាក្សាជាទៀងទាត់រវាងអ្នកផលិតបង្កើនការចែករំលែកបទពិសោធន៍ និងការអភិវឌ្ឍជំនាញ។ ជាចុងក្រោយ សកម្មភាពកសាងសមត្ថភាពរបស់សមាជិក Gi vis-à-vis តំណាងក្រុម (ECOFARM) ឬកសិករចំណាន (កសិករបៃតង) បានជួយឱ្យពួកគេមានសិទ្ធិស្របច្បាប់ក្នុងចំណោមអ្នករួមអាជីពដូចគ្នា។ ទោះជាយ៉ាងណា ប្រព័ន្ធទាំងនេះមានហានិភ័យខ្ពស់ដោយដាក់បន្ទុកការងារច្រើនហួសកម្រិតមកលើអ្នកតំណាងក្រុម (ECOFARM) ឬសហគមន៍កសិកម្មបៃតងនិងមានការផ្តល់រង្វាន់លើកទឹកចិត្ត ប្រសិនបើសំណងនៅតែមានកម្រិតតិចតួច។

ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ CESPA ក៏ផ្អែកលើការពិនិត្យទៅវិញទៅមករវាងអ្នករួមអាជីព រួមជាមួយនឹងការធ្វើតេស្តប្រសិទ្ធភាពថាមពលនៅមន្ទីរពិសោធន៍ (មន្ទីរពិសោធន៍ថាមពល ជីវម៉ាស ITC) លើសំណាកគ្រួសារដែលជ្រើសរើសដោយចៃដន្យ។ ការបង្កើត និងការសម្របសម្រួលជាមួយមន្ទីរពិសោធន៍ នៅតែទាមទារឱ្យមានរចនាសម្ព័ន្ធឈ្នួញកណ្តាលភាគីទីបី (Geres រហូតដល់ឆ្នាំ 2019 បច្ចុប្បន្នអង្គការ SNV)។

ជាចុងក្រោយ PMUAC បានបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដោយផ្អែកលើការត្រួតពិនិត្យជាបន្តបន្ទាប់របស់អធិការ (អ្នកផលិត) នៅកម្រិតសហគមន៍កសិកម្មនីមួយៗ និងអ្នកត្រួតពិនិត្យផ្ទៃក្នុងដែលជ្រើសរើសដោយសហជីព ដើម្បីបំពេញតាមលក្ខខណ្ឌនៃការផ្តល់វិញ្ញាបនបត្រសរីរាង្គពីភាគីទីបីរបស់សហជីពអឺរ៉ុប និងសហរដ្ឋអាមេរិក (សូមមើលរូបខាងក្រោម)។ លក្ខណៈទ្រង់ទ្រាយធំដែលសម្រេចបានដោយខ្សែសង្វាក់ផ្គត់ផ្គង់ស្រូវអង្ករខេត្តព្រះវិហារ អនុញ្ញាតឱ្យមានសេដ្ឋកិច្ចមាត្រដ្ឋាន និងគ្របដណ្តប់លើការចំណាយរបស់ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនេះ (រួមទាំងប្រាក់បៀវត្សរ៍របស់អ្នកត្រួតពិនិត្យ និងការបណ្តុះបណ្តាលបន្ត) និងការធ្វើវិញ្ញាបនកម្មពីភាគីទីបី។




រូបទី 3៖ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងដំណើរការផ្តល់វិញ្ញាបនបត្រសរីរាង្គរបស់ PMUAC (ប្រភព៖ AVSF និង Iram)

មុខងារត្រួតពិនិត្យគុណភាពនេះ គឺជាសសរស្តម្ភគ្រឹះមួយដែលគាំទ្រដល់ការបង្កើតសហជីព និងអនុញ្ញាតឱ្យកាត់បន្ថយការចំណាយលើវិញ្ញាបនបត្របានយ៉ាងច្រើន។ លើសពីនេះ នៅពេលបញ្ចប់គម្រោង គេរំពឹងទុកថានឹងមានការផ្ទេរតួនាទីគ្រប់គ្រង និងត្រួតពិនិត្យផ្ទៃក្នុងទាំងអស់ទៅឱ្យ PMUAC ដើម្បីជានាឱ្យមានការអភិវឌ្ឍយ៉ាងឆាប់រហ័សនូវសមត្ថភាពផ្ទៃក្នុងរបស់ខ្លួន។ អង្គភាពទាំងអស់ដែលគាំទ្រដោយសមាជិក Gi បានបង្កើតប្រព័ន្ធត្រួតពិនិត្យគុណភាពផ្ទៃក្នុង ដែលសម្របទៅនឹងទំហំនៃកិច្ចអន្តរាគមន៍របស់ខ្លួន និងទីផ្សារគោលដៅដែលកំណត់ដោយអង្គភាព។

## អន្តរាគមន៍ជាយុទ្ធសាស្ត្រសំខាន់សម្រាប់ការធ្វើពាណិជ្ជកម្ម

ផ្អែកតាមបទពិសោធន៍នៃការធ្វើអន្តរាគមន៍របស់សមាជិក Gi ក្រៅពីបញ្ហានៃការគ្រប់គ្រងគុណភាព បានបង្ហាញពីតម្លៃក្នុងការបង្កើតអង្គភាពអ្នកផលិត ដើម្បីបង្កើតឱកាសពាណិជ្ជកម្មភាគច្រើនតាមរយៈការអនុវត្តលក់Groupe initiatives ដើម្បី "ធានាឱ្យមាន" ទីផ្សារ និងការជួយគាំទ្រ។ តាមរយៈអង្គភាពនេះ អ្នកផលិតអាចផ្គត់ផ្គង់ផលិតផលតាមបរិមាណគុណភាព និងសំណើពីអ្នកទិញដែលពួកគេម្នាក់ៗមិនអាចបំពេញ ឬពិបាកក្នុងការបំពេញតាមតម្រូវការទាំងនេះ។

ការលក់ជាលក្ខណៈបុគ្គល ធ្វើឡើងជាចម្បងទៅកាន់ទីផ្សារក្នុងស្រុក (នៅក្នុងភូមិ ឬលក់ទៅឱ្យអ្នកជិតខាង) និងក្នុងបរិមាណតិចតួចទៅដល់ឈ្មួញកណ្តាលនៅថ្នាក់ឃុំ ឬទីផ្សារលក់ដុំ។ ជាឧទាហរណ៍អំពីនិន្នាការនេះ គឺអ្នកចិញ្ចឹមត្រីដែលគាំទ្រដោយ APDRA។ ការលក់ទៅឱ្យឈ្មួញកណ្តាល និងឈ្មួញលក់ដុំក្នុងស្រុក ក៏ដូចជាទៅដល់អតិថិជន "ធំៗ" (សណ្ឋាគារ ភោជនីយដ្ឋាន) ឬអ្នកនាំចេញ ជាធម្មតាធ្វើឡើងជាសមូហភាព (ឧ. ECOFARM និងសហគមន៍កសិកម្មបៃតង)។

ឈ្មួញលក់ដុំចង់កាត់បន្ថយថ្លៃដឹកជញ្ជូនដោយបង្កើនប្រសិទ្ធភាពការដឹកជញ្ជូន និងកាត់បន្ថយការចំណាយលើការលើកដាក់ផលិតផល។ ពួកគេតែងប្រមូលទិញផលិតផលមួយចំនួនក្នុងបរិមាណច្រើន។ ពួកគេមានកម្រិតលក្ខខណ្ឌជាក់លាក់មួយចំនួនទាក់ទងនឹងការជ្រើសរើសអ្នកផ្គត់ផ្គង់ ពោលគឺគុណភាព ភាពទៀងទាត់នៃការផ្គត់ផ្គង់ សេវា (ជាពិសេសការប្រគល់ទំនិញ)។ លក្ខណៈវិនិច្ឆ័យសំខាន់ៗដែលត្រូវបំពេញដោយឈ្មួញប្រមូលទិញ ឬឈ្មួញកណ្តាលដែលមានបំណងផ្គត់ផ្គង់ដល់អ្នកលក់ដុំ រួមមានភាពសម្បូរបែបនៃផលិតផល និងសេវាដែលដាក់លក់ (ភាពងាយស្រួលនៃការបញ្ជាទិញ ការដឹកជញ្ជូន)។ ប្រភេទលក្ខណៈវិនិច្ឆ័យដូចគ្នានេះក៏អនុវត្តចំពោះប្រភេទសណ្ឋាគារ និងភោជនីយដ្ឋានធំៗផងដែរ ដែលគ្រប់គ្រងការផ្គត់ផ្គង់តាមរយៈការបញ្ជាទិញពីអ្នកផ្គត់ផ្គង់មួយចំនួនតូច ដើម្បីធានាការដឹកជញ្ជូនផលិតផល។

ចំពោះផលិតផលរបស់អង្គភាព ពោលគឺ ECOFARM និងសហគមន៍កសិកម្មបៃតង ដែលកំណត់យកក្រុងក្នុងខេត្តសៀមរាបជាតំបន់គោលដៅ អ្នកផលិត-ឈ្មួញប្រមូលទិញ បានប្រមូលទិញពីអ្នករួមអាជីព រួចលក់បន្តទៅឱ្យឈ្មួញប្រមូលទិញ និងឈ្មួញលក់ដុំ។ ដូច្នេះអង្គភាពទាំងពីរមានបណ្តាញទីផ្សារស្រដៀងគ្នា (សូមមើលរូបខាងក្រោម)។






រូបទី 4៖ បណ្តាញទីផ្សារ ECOFARM (ខាងលើ) និងសហគមន៍កសិកម្មបៃតង (ខាងក្រោម) សម្រាប់តំបន់ក្រុងក្នុងខេត្តសៀមរាប (ប្រភព៖ Gret និង ARTE-FACT)

អ្នកផលិត-ឈ្មួញប្រមូលទិញទាំងនេះ ជាធម្មតាមានបទពិសោធន៍ផ្នែកពាណិជ្ជកម្ម ឬសហគ្រិនភាព ក៏ដូចជាមានទំនាក់ទំនង និងបណ្តាញជាមួយតួអង្គនៅផ្នែកលំហូរខាងក្រោម។ ពួកគេក៏ទទួលខុសត្រូវក្នុងការរៀបចំផែនការផលិតកម្មរបស់សមាជិកអង្គភាពផងដែរ។ ការអនុវត្តផែនការផលិតកម្មនៅក្នុងអង្គភាពទាំងនេះគឺមានសារៈសំខាន់ណាស់ក្នុងការបំពេញតម្រូវការទាំងបរិមាណ និងផលិតផលបន្លែផ្សេងៗ។ ចំណែកកសិករដាំដុះដែលធ្លាប់ផលិតដោយមិនគិតពីប្រភេទបន្លែដែលអ្នកទិញចង់បាននោះឥឡូវនេះពួកគេមានព័ត៌មានពីឈ្មួញប្រមូលទិញ ហើយអាចរៀបចំផែនការដោយខ្លួនឯង ដើម្បីកំណត់វដ្តដែលត្រូវអនុវត្ត។ ចំណេះដឹងគួបផ្សំជាមួយការរៀបចំនេះបានអនុញ្ញាតឱ្យសមាជិកសហគមន៍កសិកម្មបៃតង ផ្គត់ផ្គង់ដល់អតិថិជនធំៗរបស់ខ្លួនជាឧទាហរណ៍ (សណ្ឋាគារ ភោជនីយដ្ឋាន សាលាសណ្ឋាគារ) ជាមួយនឹងបន្លែ "របស់អឺរ៉ុប" ។

ចំពោះកសិករផលិតស្រូវនៅ PMUAC ការប្រមូលទិញធ្វើឡើងនៅកម្រិតសហគមន៍កសិកម្មនីមួយៗ ដែលជាសមាជិករបស់ PMUAC៖ អ្នកផលិតអាចដឹកជញ្ជូនកសិផលរបស់ខ្លួនមកកាន់កន្លែងស្តុកទុករបស់សហគមន៍របស់ខ្លួន ឬសហគមន៍ខ្លះផ្តល់សេវាប្រមូលកសិផលដល់កន្លែង។ ការដាក់បញ្ចូលទៅក្នុងសហជីពមិនបានផ្លាស់ប្តូរវិធីសាស្ត្រនៃការប្រមូលកសិផល ឬលក់ចេញនោះទេ ដោយសារសហគមន៍នៅតែជាអង្គភាពពាណិជ្ជកម្មដែលមានកិច្ចសន្យាលក់ជាមួយអ្នកទិញ។ ទោះជាយ៉ាងណា សហជីពដើរតួនាទីគាំទ្រដល់ការរៀបចំផែនការ ដើម្បីធានាថាផ្ទៃដីសាបព្រោះស្របទៅតាមបរិមាណពូជស្រូវខុសៗគ្នាដែលរំពឹងទុក។

លើសពីនេះទៀត ការណែនាំលក់ជាសមូហភាព គឺដោយសារតែមានបញ្ហាពន្យារពេលរបស់អ្នកទិញក្នុងការទូទាត់ប្រាក់ទៅដល់អ្នកផលិត។ ការទូទាត់ប្រាក់ជាធម្មតាមានការយឺតយ៉ាវជាច្រើនថ្ងៃ ឬច្រើនសប្តាហ៍ ធៀបជាមួយនឹងថ្ងៃប្រគល់ផលិតផល អាស្រ័យលើការប្រព្រឹត្តរបស់អ្នកទិញ។ ជាឧទាហរណ៍ វាអាចពាក់ព័ន្ធនឹងពេលវេលាដឹកជញ្ជូន ការត្រួតពិនិត្យគុណភាព និងការថ្លឹងស្រូវអង្ករដោយអ្នកទិញរបស់សហគមន៍ PMUAC ឬការរៀបចំការទូទាត់ប្រចាំខែតាមការណែនាំរបស់អ្នកលក់ដុំដែលទិញពីសហគមន៍កសិកម្មបៃតង។ អង្គភាពអាចដើរតួជាទីជាអ្នកផ្តល់ឥណទានដល់សមាជិករបស់ខ្លួន ដើម្បីជួយសម្រួលដល់ការគ្រប់គ្រងសាច់ប្រាក់របស់ខ្លួន ដូចករណីរបស់ PMUAC ដែរ អាស្រ័យលើស្ថានភាពជាក់ស្តែង។

ការរួមចំណែកដ៏សំខាន់ផ្សេងទៀតរបស់អង្គភាព គឺការអភិវឌ្ឍពាណិជ្ជកម្ម ជាពិសេសហាងលក់ដុំដែលអ្នកផលិតម្នាក់ៗមិនអាចជ្រៀតចូលបាន។ មុខងារអភិវឌ្ឍន៍អាជីវកម្ម ត្រូវបានរៀបចំឡើងជាលក្ខណៈផ្ទៃក្នុង និងប្រកបដោយវិជ្ជាជីវៈនៅក្នុងក្របខណ្ឌ PMUAC ។ កត្តាដ៏សំខាន់ក្នុងការអភិវឌ្ឍអាជីវកម្មរបស់ PMUAC រួមមានធនធានមនុស្សដែលមានគុណភាពខ្ពស់ រួមជាមួយនឹងការបណ្តុះបណ្តាលជាបន្តបន្ទាប់ ការប្តេជ្ញាចិត្តខ្ពស់ និងភាពស្មោះត្រង់។ កត្តានេះបានបង្កើនចំនួនកិច្ចសន្យាទិញ ចំនួនអ្នកទិញចម្រុះ (អ្នកនាំចេញអង្ករចំនួន 5) បានបង្កើតតម្លៃបុព្វលាភបន្ថែមផ្អែកលើមូលដ្ឋានសរីរាង្គ និងបង្កើតម៉ាករួមអង្ករផ្កាម្លិះពិសេសសម្រាប់ទីផ្សារក្នុងស្រុក។ ការផ្តល់ហិរញ្ញប្បទានលើការអភិវឌ្ឍ និងថែទាំគុណភាពអង្ករ (ការគាំទ្រផ្នែកបច្ចេកទេស ការត្រួតពិនិត្យគុណភាព) ក៏ដូចជាអង្គភាពនានា (សហគមន៍ PMUAC) អាចធ្វើទៅបានដោយបង្កើតផលិតផលខុសប្លែកពីគេនៅលើទីផ្សារ រួមទាំងតម្លៃបុព្វលាភបន្ថែមលើគុណភាព និងតម្លៃបុព្វលាភបន្ថែមផ្អែកលើមូលដ្ឋានសរីរាង្គ។ អ្នកផលិតបានជ្រើសរើសបែងចែកប្រាក់ចំណូលដែលរកបានពីតម្លៃបុព្វលាភបន្ថែមជាបីផ្នែក គឺ 75% សម្រាប់អ្នកផលិត 12.5% សម្រាប់សហគមន៍ និង 12.5% សម្រាប់សហជីព។ សេដ្ឋកិច្ចមាត្រដ្ឋានគឺជាគោលដៅដែលបានកំណត់ (បណ្តុំធនធាន

មនុស្សដ៏ច្រើន) ដើម្បីធានាបាននូវនិរន្តរភាពហិរញ្ញប្បទាននេះតាមរយៈទីផ្សារ។ ការចំណាយលើមុខងាររបស់ PMUAC (ជាពិសេសការត្រួតពិនិត្យផ្ទៃក្នុង - និយោជិត 12 រូប ។ល។) គ្របដណ្តប់ទាំងស្រុងដោយប្រើចំណែកតម្លៃបុព្វលាភបន្ថែមផ្អែកលើមូលដ្ឋានសវិរាង្គពីការលក់អង្ករ (និងដកតម្លៃបុព្វលាភបន្ថែមបន្តិចបន្តួចពីការតាំងពិព័រណ៍)។

សហគមន៍កសិកម្មបៃតងក៏មានគោលបំណងបង្កើតមុខងារអភិវឌ្ឍន៍អាជីវកម្មជាលក្ខណៈផ្ទៃក្នុងផងដែរ ហើយបច្ចុប្បន្នមុខងារនេះនៅតែអនុវត្តដោយ Agrisud ។ ជម្រើសយុទ្ធសាស្ត្រពាណិជ្ជកម្ម គឺផ្តោតជាអាទិភាពលើទីផ្សារធំៗ (សណ្ឋាគារ ភោជនីយដ្ឋាន) ដែលអាចរកប្រាក់ចំណេញបានច្រើន និងអាចរ៉ាប់រងការចំណាយលើការគ្រប់គ្រងគុណភាព និងអង្គភាពបានកាន់តែល្អប្រសើរ។ លើសពីនេះទៀត តាមរយៈសកម្មភាពរបស់ខ្លួន សមាជិកក្រុម Gi បានផ្តោតគោលដៅលើ ប្រព័ន្ធស្បៀងអាហារទាំងមូល ជាពិសេសតាមរយៈការយល់ដឹងរបស់អ្នកប្រើប្រាស់ (យុទ្ធនាការ ពិព័រណ៍។ល។)។ ឧទាហរណ៍ អ្នកផលិតរបស់ ECOFARM និងសហគមន៍កសិកម្មបៃតង លក់ផលិតផលដោយផ្ទាល់នៅ "ផ្សារចុងសប្តាហ៍" រៀងរាល់ថ្ងៃសៅរ៍ក្នុងខេត្តសៀមរាប ហើយផ្សារនេះបង្កើតឡើងដោយមានការគាំទ្រពី Gret និង Agrisud ។ ពួកគេក៏លក់ផលិតផលដោយផ្ទាល់តាមរយៈការបញ្ជាទិញរបស់អ្នកប្រើប្រាស់តាមអ៊ីនធឺណិត នៅលើទំព័រហ្វេសប៊ុករបស់ខ្លួនផងដែរ។ ដូចនេះ ការទំនាក់ទំនងជាមួយអតិថិជនដោយផ្ទាល់នេះ គឺជា ឱកាសមួយសម្រាប់អង្គភាពទាំងពីរក្នុងការលើកកម្ពស់ការយល់ដឹងអំពីម៉ាកក៏ដូចជាកេរ្តិ៍ឈ្មោះរបស់ខ្លួន។ ពួកគេអាចប្រាស្រ័យទាក់ទងដោយផ្ទាល់ ដើម្បីបង្ហាញពីតម្រូវការចំពោះគុណភាព ឆ្លើយសំណួរ និងបង្កើតភាពជិតស្និទ្ធ។

ទន្ទឹមនឹងនេះដែរ សហគមន៍កសិកម្មបៃតង បង្កើនការយល់ដឹងក្នុងចំណោមអ្នកមានអាជីពដែលឆ្ងាយពីខ្សែសង្វាក់លំហូរខាងក្រោម ដូចជា សណ្ឋាគារ ភោជនីយដ្ឋាន និងសាលាសណ្ឋាគារ។ សួនបន្លែរួមត្រូវបានបង្កើតឡើងសម្រាប់សិស្សានុសិស្ស ហើយផលិតផលពីសមាជិកសហគមន៍កសិកម្មបៃតង ត្រូវបានប្រើប្រាស់ជាប្រចាំនៅក្នុងថ្នាក់បង្រៀនធ្វើម្ហូប។



ផ្សារចុងសប្តាហ៍ខេត្តសៀមរាប

ជាចុងក្រោយ នាពេលថ្មីៗនេះគម្រោង IADA បានបំពេញបន្ថែមកិច្ចអន្តរាគមន៍របស់ខ្លួននៅកម្រិតប្រព័ន្ធស្បៀងអាហារជាមួយនឹងវិធីសាស្ត្រនៅនឹងមូលដ្ឋាន ដោយមានការគាំទ្រចំពោះក្រុងដែលសកម្មភាពត្រូវបានអនុវត្តក្នុងការកំណត់យុទ្ធសាស្ត្រអមជាមួយនឹងការអភិវឌ្ឍប្រព័ន្ធស្បៀងអាហារប្រកបដោយនិរន្តរភាព (ផែនការសកម្មភាពកសិអេកូឡូស៊ីដែលមានការចូលរួម)។ គម្រោងក៏បានផ្តួចផ្តើមការអនុវត្តស្តង់ដារគុណភាព និងដំណើរការធ្វើវិញ្ញាបនកម្មដែលបានកំណត់សម្រាប់ផលិតផលក្នុងស្រុក ដែលដាក់លក់នៅទីផ្សារចុងសប្តាហ៍ខេត្តសៀមរាប ដោយសហការជាមួយមន្ទីរពាណិជ្ជកម្មខេត្ត និងគម្រោងផ្សេងទៀត (គម្រោង APICI របស់ Gret គម្រោង AIMS របស់ IFAD)។ ការបញ្ជាក់យថាប្រភេទត្រូវបានរៀបចំរួចហើយ ក៏ដូចជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធត្រួតពិនិត្យ (ការធ្វើវិញ្ញាបនកម្ម) លើការអនុលោមតាមយថាប្រភេទទាំងនេះ។ គណៈកម្មាធិការគ្រប់គ្រងស្លាកផលិតផលក៏ត្រូវបានបង្កើតឡើងផងដែរ។

រូបទី 5៖ និមិត្តសញ្ញាវិញ្ញាបនបត្រកសិផលសុវត្ថិភាពខេត្តសៀមរាប (ប្រភព៖ Agrisud)

ផ្អែកតាមបទពិសោធន៍ទាំងនេះបានបង្ហាញថា ការបង្កើតអង្គភាពគឺមានសារៈសំខាន់ណាស់ ដើម្បីសម្រេចបានបរិមាណ និងធ្វើពិពិធកម្មផលិតកម្ម ដែលជាតម្រូវការរួមសម្រាប់វិស័យទាំងអស់។

## តួនាទីគាំទ្រជាបន្តចំពោះសមាជិក Gi

វិធីសាស្ត្ររបស់សមាជិក Gi គឺផ្អែកលើគោលការណ៍ភាពជាដៃគូ និងសាមគ្គីភាព ជាមួយអង្គភាពនានានៅតំបន់ភាគខាងត្បូង។ ផ្អែកតាមតថភាពនេះ និងឧបសគ្គដែលបានជួបប្រទះបានបង្ហាញថា នៅដំណាក់កាលណាមួយនៃការអភិវឌ្ឍខ្សែសង្វាក់តម្លៃអង្គភាពអាចនឹងត្រូវដើរតួនាទីជាភាគីពាក់ព័ន្ធក្នុងវិស័យនេះ ហើយពេលខ្លះ ផ្លាស់ប្តូរភាគីពាក់ព័ន្ធក្នុងស្រុក ជាពិសេសអ្នកផលិតនិងអង្គភាពរបស់ខ្លួន។ យោងតាមបទពិសោធន៍របស់ Gi បានបង្ហាញពីសារៈសំខាន់នៃការផ្ទេរចំណេះដឹងបន្តិចម្តងៗ និងដំណើរការកសាងសមត្ថភាពក្នុងចំណោមដៃគូរបស់ខ្លួន ដើម្បីធានាបាននូវនិរន្តរភាពនៃសកម្មភាព និងអង្គភាពរបស់ខ្លួន។

ប្រអប់លេខ១

### បញ្ហាទាក់ទងនឹងការកំណត់តួនាទីរបស់សមាជិក Gi និងភាគីពាក់ព័ន្ធអភិវឌ្ឍន៍ផ្សេងទៀត។

- តើសមាជិក Gi មានតួនាទីអ្វីខ្លះក្នុងដំណើរការនេះ?
- តើត្រូវដាក់ចេញដំណើរការអ្វីខ្លះ ដើម្បីជួយសម្រួលដល់ការផ្ទេរសមិទ្ធផល និងភាពម្ចាស់ការលើការគ្រប់គ្រងគុណភាព និងអង្គភាពពីភាគីពាក់ព័ន្ធក្នុងស្រុក?
- តើភាគីពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យអភិវឌ្ឍន៍ (អាជ្ញាធរសាធារណៈ សេវារបស់រដ្ឋាភិបាលវិមជ្ឈការលើវិស័យកសិកម្ម ពាណិជ្ជកម្ម ម្ចាស់ជំនួយ ដៃគូអភិវឌ្ឍន៍បច្ចេកទេស។ល។) មានតួនាទីអ្វីខ្លះ និងចូលរួមយ៉ាងដូចម្តេច?

ផ្អែកតាមបទពិសោធន៍របស់សមាជិក Gi បានបង្ហាញពីតម្រូវការនូវការជួយគាំទ្ររយៈពេលវែងចំពោះអ្នកផលិតខ្នាតតូច ដើម្បីចូលរួមក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ និងឱ្យមានការទទួលស្គាល់លក្ខណៈពិសេសរបស់ខ្លួន ទន្ទឹមនឹងការអភិវឌ្ឍ និងផ្លាស់ប្តូរវិធីសាស្ត្រផលិតកម្ម អភិវឌ្ឍការគ្រប់គ្រងគុណភាព និងពង្រឹងសមត្ថភាពពាណិជ្ជកម្មរបស់ខ្លួន ដើម្បីទទួលបាននូវអត្ថប្រយោជន៍។ ការជួយគាំទ្រភាគច្រើនដែលផ្តល់ដោយសមាជិករបស់ Gi បានផ្តោតជាចម្បងលើការគាំទ្រក្នុងការផលិត (ការកសាងក្របខណ្ឌឯកសារយោងទូទៅ ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់អ្នកផលិត) ដោយពង្រីកការគាំទ្របន្តិចម្តងៗលើការគ្រប់គ្រងអង្គភាព និងការអភិវឌ្ឍអាជីវកម្ម។

នៅពេលចាប់ផ្តើមអន្តរាគមន៍ សមាជិក Gi ជាទូទៅបានអនុវត្តការងារផ្តល់ជំនួយបច្ចេកទេសមួយចំនួនធំដូចជា ការបណ្តុះបណ្តាល ការបង្កើតចលនាក្រុមអ្នកផលិត និងការផ្តល់ ប្រឹក្សា។ សមាជិក Gi ក៏បានផ្តល់ការគាំទ្រផ្នែកវិធីសាស្ត្រដល់ការតម្រង់ទិស និងការអនុវត្តរបស់អង្គភាព និងសមាជិករបស់ខ្លួនឱ្យបានត្រឹមត្រូវ និងប្រកបដោយសត្យានុម័តផងដែរ ពោលគឺការវិភាគស្ថានភាព និងការប្រមូលផ្តុំតម្រូវការ ការស្រាវជ្រាវដែលមានការចូលរួម (APDRA) ការងាររំកិល (AVSF និង Iram) វិធីសាស្ត្រ PGS (Gret។ ) សមាជិកមួយចំនួនបានរួមចំណែកចំណេះដឹងបច្ចេកទេសប្រកបដោយភាពច្នៃប្រឌិតខ្ពស់ដល់អ្នកផលិតដែលមិនចេះ ដូចជា សិប្បកម្មបិតស្រាដែលផ្តួចផ្តើមដោយ Agrisud ជាដើម។ ជាចុងក្រោយ Geres បានអនុវត្តដោយផ្ទាល់នូវការត្រួតពិនិត្យដ៏ស្មុគស្មាញ និងការវិវត្តនៃដំណើរការផលិតចង្ក្រានប្រណីត ដើម្បីកំណត់បរិមាណនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលគួរជៀសវាង។

សមាជិក Gi គឺជាកាតាលីករជំរុញដល់នវានុវត្តភាពផ្នែកបច្ចេកទេស សេដ្ឋកិច្ច និងការរៀបចំអង្គភាព។

លើសពីនេះ សមាជិក Gi មួយចំនួន បានអនុវត្តសកម្មភាពក្នុងភាពជាដៃគូជាមួយភាគីពាក់ព័ន្ធក្នុងស្រុកដូចជា អង្គភាព Trailblazer Cambodia (TCO) ប្រចាំ APDRA និងវិទ្យាស្ថានស្រាវជ្រាវសម្រាប់ការអភិវឌ្ឍន៍កម្ពុជា (CIRD) សម្រាប់ Gret and Geres ដែលអនុញ្ញាតឱ្យមានការផ្លាស់ប្តូរជំនាញ និង ចំណេះដឹង ដើម្បីលើកកម្ពស់និរន្តរភាពក្នុងមូលដ្ឋាន។

សមាជិក Gi ក៏បានសម្របសម្រួលការបង្កើតភាពជាដៃគូរវាងភាគីពាក់ព័ន្ធក្នុងខ្សែសង្វាក់តម្លៃ និងភាគីពាក់ព័ន្ធក្នុងស្រុកផងដែរ។ AVSF, Iram និង Agrisud បានដើរតួនាទីជាចំណុចស្នូលនៃការទំនាក់ទំនងរវាង PMUAC និងសហគមន៍កសិកម្មបៃតង ជាមួយអ្នកនាំចេញអង្ករ និងសណ្ឋាគារ ភោជនីយដ្ឋាន និងសាលាសណ្ឋាគារ។ ស្ថាប័នទាំងនេះមានតួនាទីដ៏សំខាន់ក្នុងការធានានូវឱកាស។ សមាជិក Gi គឺជាកម្លាំងចលករដែលនៅពីក្រោយការអភិវឌ្ឍឱកាសអាជីវកម្ម ដែលមិនធ្លាប់មានពីមុនមកក្នុងតួនាទីផ្នែកសេដ្ឋកិច្ចនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់។ ទាក់ទងនឹងភាពជាដៃគូនៅនឹងមូលដ្ឋានពួកគេបានជំរុញការចាក់ឫសគល់នៃអន្តរាគមន៍របស់ខ្លួននៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍មូលដ្ឋាន និងអាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធ (សេវាកសិកម្ម និងពាណិជ្ជកម្មបែបវិមជ្ឈការ) ក្នុងការអនុវត្ត ឬត្រួតពិនិត្យសកម្មភាព។ ជាឧទាហរណ៍ មន្ត្រីមកពីមន្ទីរកសិកម្មខេត្តសៀមរាប គឺជាផ្នែកមួយនៃក្រុមគម្រោង Gret ហើយបានចូលរួមនៅក្នុង PGS។ ជាទូទៅ អង្គភាពទទួលបានប្រយោជន៍ពីការគាំទ្រផ្នែកនយោបាយ ដែលអនុញ្ញាតឱ្យពួកគេធ្វើប្រតិបត្តិការក្នុងបរិយាកាសអាជីវកម្មកាន់តែមានសុវត្ថិភាព។ ជាចុងក្រោយសមាជិក Gi បានដើរតួនាទីជាមជ្ឈមណ្ឌលទំនាក់ទំនងរវាងម្ចាស់ជំនួយ និងអ្នកទទួលផលចុងក្រោយ ដែលអនុញ្ញាតឱ្យពួកគេទទួលបានមូលនិធិពីជំនួយអភិវឌ្ឍន៍អន្តរជាតិ។

បញ្ហាប្រឈមដែលសមាជិក Gi ជួបប្រទះ គឺការផ្ទេរចំណេះដឹង និងជំនាញទៅកាន់អង្គភាពអ្នកផលិត។ គំរូអាជីវកម្មអាចរាំង ដល់ការបញ្ចូលមុខងារគាំទ្រ។ ជាឧទាហរណ៍ ប្រព័ន្ធគ្រប់គ្រង ចង្រ្កានប្រណិតតែងទទួលបានការគាំទ្រ (ទាំងស្រុង ឬមួយផ្នែក) ពី Geres (បច្ចុប្បន្នអង្គការ SNV) ព្រោះត្រូវចំណាយថវិកាអស់ច្រើន និងមានតម្រូវការផ្នែកបច្ចេកទេស។ ដូចគ្នាដែរ គំរូអាជីវកម្មរបស់សហគមន៍កសិកម្មបៃតង មិនទាន់អនុញ្ញាតឱ្យមានការជ្រើសរើសផ្ទៃក្នុងនូវបុគ្គលិក Agrisud ចំនួនពីររូបដែលទទួលបន្ទុកផ្នែកគ្រប់គ្រង និងទីផ្សារនោះទេ។ ម្យ៉ាងវិញទៀត ជំនាញបច្ចេកទេសត្រូវបាន PMUAC ធ្វើសមាហរណកម្មយ៉ាងពេញលេញ ក៏ដូចជាការផ្តល់ហិរញ្ញប្បទានរបស់ខ្លួន ដោយសារតែការសម្រេចបាននូវសេដ្ឋកិច្ចមាត្រដ្ឋាន។

ជាចុងក្រោយ សមាជិកនៃក្រុម Gi មានបំណងផ្តល់ឱ្យអ្នកផលិត និងអង្គភាពនានានូវសេរីភាពក្នុងការជ្រើសរើសគោលនយោបាយរបស់ខ្លួន។ បច្ចុប្បន្ន អង្គភាពមានយុទ្ធសាស្ត្រច្បាស់លាស់ដែលអនុញ្ញាតឱ្យពួកគេពឹងទុកជាមុននូវដំណាក់កាលរីកចម្រើនរបស់ខ្លួន រួមទាំងភាពគ្រប់គ្រាន់ផ្នែកហិរញ្ញវត្ថុ។

# អនុសាសន៍

លំហាត់ដកស្រង់បទពិសោធន៍ បាននាំឱ្យមានការចែករំលែកនូវអនុសាសន៍ចម្រុះវិស័យមួយចំនួនពីសំណាក់សមាជិក Gi ដើម្បីគាំទ្រដល់អង្គភាព និងការគ្រប់គ្រងគុណភាពរបស់ខ្លួន។

## $ ការកសាង និងគ្រប់គ្រងគុណភាព

- អភិវឌ្ឍសមត្ថភាពរបស់អ្នកផលិតក្នុងការវិភាគតម្រូវការទីផ្សារ និងការប្រែប្រួលតម្លៃ ដោយធ្វើការសហការរវាងអ្នកផលិតដើម្បីបង្កើនភាពស៊ីមេទ្រីគ្នារវាងកាលវិភាគកសិកម្ម និងជម្រើសផលិតកម្ម។
- ដោយមើលឃើញពីការខ្វះខាតឯកសារយោងផ្នែកបច្ចេកទេស បានលើកទឹកចិត្តឱ្យកសិករចេះបង្កើតថ្មី និងសាកល្បងបច្ចេកទេសថ្មីៗដើម្បីកំណត់ពីឱកាសនៃភាពជោគជ័យ។
- ការផ្លាស់ប្តូរគំរូត្រូវអែមមកជាមួយការលើកកម្ពស់ការយល់ដឹង និងការធ្វើការបង្ហាញ។
- កែសម្រួលនវានុវត្តន៍ និងការអនុវត្តឱ្យមានលក្ខណៈសមស្របតាមបរិបទជាក់លាក់របស់អ្នកផលិតនីមួយៗ (ប្រភេទដី បរិមាណទឹក) បើនិយាយពីផ្នែកបច្ចេកទេស និង (ពេលវេលា លទ្ធភាពថវិកា) បើនិយាយពីផ្នែកសេដ្ឋកិច្ចសង្គម។ សូមកុំផ្តល់ដំណោះស្រាយដែលមានលក្ខណៈស្តង់ដារ។
- ពង្រឹងការធ្វើផែនការយុទ្ធនាការ/វដ្ត ដើម្បីផ្គត់ផ្គង់តម្រូវការរបស់អ្នកទិញក្នុងក្របខណ្ឌផលិតផល បរិមាណ និងភាពញឹកញាប់។ សូមគិតពីយុទ្ធសាស្ត្រទីផ្សារមុនពេលប្រមូលផល។
- បញ្ចូលការចំណាយលើការគ្រប់គ្រងគុណភាពទៅក្នុងតម្លៃលក់ ក៏ដូចជាការចំណាយលើមុខងារទាំងឡាយដែលត្រូវរក្សាទុកលើសពីរយៈពេលគម្រោង ហើយបញ្ចូលទៅក្នុងខ្សែសង្វាក់តម្លៃ។

## $ ផ្នែកទីផ្សារ

- បង្កើតរចនាសម្ព័ន្ធទីផ្សារគ្រប់គ្រងដោយអ្នកផលិត ក្នុងតួជាទីជាអ្នកប្រមូលទិញ និងលក់ដុំ ដើម្បីផ្គត់ផ្គង់ទៅដល់ទីផ្សារនៅទីប្រជុំជន ភោជនីយដ្ឋាន និងសណ្ឋាគារ។
- ចំពោះខ្សែសង្វាក់ផ្គត់ផ្គង់ខ្លី ជានាំឱ្យមានទំនាក់ទំនងផ្ទាល់រវាងអ្នកផលិត និងអ្នកប្រើប្រាស់ ដើម្បីកសាងទំនុកចិត្តលើគុណភាពផលិតផល និងស្តង់ដារគុណភាពស្របតាមសមត្ថភាពរបស់កសិករ និងតម្រូវការរបស់អតិថិជន។
- បង្កើតឧបករណ៍ទំនាក់ទំនង និងផ្នែកកស្តុការ ដើម្បីពង្រឹងសមត្ថភាពក្នុងការផ្សារភ្ជាប់រវាងការផ្គត់ផ្គង់ និងតម្រូវការ (ឧ.អ៊ីនធឺណិត/ថ្នាលប្រព័ន្ធសារ SMS)

## $ ការគ្រប់គ្រងអង្គភាព

- ការកំណត់គោលដៅគុណភាពគឺជាកត្តាលីករមួយដែលជំរុញដល់ការបង្រួបបង្រួមអ្នកផលិត និងបង្កើតអង្គភាព ដោយមិនប្រើវិធីផ្សេងទៀតនោះទេ។ អនុញ្ញាតឱ្យអ្នកផលិតមានស្វ័យភាព និងគាំទ្រដល់ពួកគេក្នុងការកំណត់គោលដៅ និងមុខងាររបស់អង្គភាពឱ្យបានច្បាស់។ ការបង្កើតរចនាសម្ព័ន្ធមិនមែនជាគោលដៅដោយផ្ទាល់នោះទេ ប៉ុន្តែត្រូវបំពេញតាមតម្រូវការមុខងារ។
- កសាងសមត្ថភាពរបស់អ្នកផលិត និងបុគ្គលិកឱ្យក្លាយជាដៃគូគ្រប់ជ្រុងជ្រោយ។
- បង្កើតអង្គភាពកសិករតំណាងដែលរឹងមាំ មានរចនាសម្ព័ន្ធល្អ ហើយអាចការពារផលប្រយោជន៍របស់ខ្លួន។

**$ ការកំណត់តួនាទីរបស់សមាជិក ៤ ក្នុងដំណើរការអភិវឌ្ឍ**

- ជៀសវាងការផ្លាស់ប្តូរតួនាទី (បើអាចធ្វើទៅបាន) ដែលត្រូវរក្សាទុករហូតទាល់តែផុតអាណត្តិគម្រោង។ កសាងសមត្ថភាពធនធានមនុស្សតាំងពីពេលចាប់ផ្តើមអន្តរាគមន៍ដំបូង និងរំពឹងទុកជាមុននូវការផ្ទេរភារកិច្ចទទួលខុសត្រូវ និងមុខងារទៅដល់អង្គភាព។
- ចាប់ផ្តើមភាពជាដៃគូជាមួយអាជ្ញាធរមូលដ្ឋាន និងភាគីពាក់ព័ន្ធក្នុងវិស័យអភិវឌ្ឍន៍ (មជ្ឈមណ្ឌលស្រាវជ្រាវ អង្គការមិនមែនរដ្ឋាភិបាល។ល។) ដើម្បីលើកកម្ពស់ខ្សែសង្វាក់តម្លៃគុណភាពក្រោមការដឹកនាំរបស់អង្គភាពអ្នកផលិត និងធ្វើការអភិវឌ្ឍស្ថាប័នលើវិស័យកសិអេកូឡូស៊ីនៅកម្រិតតំបន់ (យុទ្ធសាស្រ្តការអនុវត្តក្នុងការធ្វើវិញ្ញាបនកម្មសមូហភាព)។
- មានភាពបត់បែនក្នុងការគាំទ្រអង្គភាព (ទទួលស្គាល់ថាការអភិវឌ្ឍស្ថាប័នគឺជាដំណើរការមួយដែលទាមទារឱ្យមានភាពម្ចាស់ការ) និងកៀរគរធនធានមនុស្ស និងជំនួយបច្ចេកទេសតាមការចាំបាច់។



កសិករដាំបន្លែរបស់អង្គការសហគមន៍កសិកម្មបៃតង

# ការគាំទ្រដំណើរឆ្ពោះទៅរកកសិដ្ឋានកសិអេកូឡូស៊ីជាលក្ខណៈគ្រួសារនៅទីប្រជុំជន តាមរយៈជម្រើសសេវាជាច្រើន

## ព័ត៌មានសាវតាអំពីករណីសិក្សា

- *ការធ្វើប្រពលវប្បកម្មកសិអេកូឡូស៊ី និងការធ្វើពិពិធកម្មគម្រោងកសិកម្មនៅទីប្រជុំជនខេត្តសៀមរាប (IADA) : i)* បន្តបង្កើនការធ្វើប្រពលវប្បកម្មកសិអេកូឡូស៊ី និងការធ្វើពិពិធកម្មកសិកម្មក្នុងស្រុក ii) អភិវឌ្ឍជម្រើសសេវាកសិកម្មជាច្រើនលើជំនាញកសិកម្ម និងខ្សែសង្វាក់កសិកម្ម iii) គាំទ្រការងាកទៅរកប្រព័ន្ធស្បៀងអាហារក្នុងមូលដ្ឋាន។
- រយៈពេលអនុវត្ត៖ ដំណាក់កាលទី 1 (2016-2019) ដំណាក់កាលទី 2 (2019-2022) ដំណាក់កាលទី 3 (2022-2025)
- ម្ចាស់ជំនួយធំៗ៖ AFD និង CD92; ទីតាំង៖ ខេត្តសៀមរាប

## ការបង្ហាញខ្សែសង្វាក់ដ៏មានតម្លៃ និងអង្គភាពដែលភ្ជាប់មកជាមួយ

- ភាគីពាក់ព័ន្ធ៖ កសិដ្ឋានលក្ខណៈគ្រួសារខ្នាតតូច (អ្នកទទួលផលគម្រោង) ឈ្មួញប្រមូលទិញក្នុងភូមិ អ្នកលក់ដុំ និងអ្នកលក់រាយ។
- ផលិតកម្ម៖ បន្លែ និងគ្រឿងទេសច្រើនប្រភេទដែលផលិតនៅលើរានសួនបន្លែ ឬទីវាល ផ្លែឈើ ផលិតផលកែច្នៃដោយក្រុមកសិករ (តែរុក្ខជាតិ គ្រឿងទេសស្ងួត ភេសជ្ជៈ ស្រា)។
- ហាងលក់ទំនិញ៖ ផ្សារក្នុងក្រុងសៀមរាប ផ្សារទំនើប ភោជនីយដ្ឋាន សណ្ឋាគារ។
- អង្គភាព៖ សហគមន៍កសិកម្មបៃតង (GF)។ ទទួលខុសត្រូវក្នុងការប្រមូលទិញ កែច្នៃ និងចែកចាយកសិផលរបស់សមាជិក ក៏ដូចជាសកម្មភាពទីផ្សារ ការដាក់ស្លាកផលិតផល និងផ្សព្វផ្សាយលក់។ សមាគមត្រូវបានបង្កើតឡើងក្នុងឆ្នាំ 2018 បច្ចុប្បន្នមានសមាជិកចំនួន 419 នាក់នៅក្នុងភូមិចំនួន 34 និងមានបុគ្គលិកចំនួន 12 នាក់ ក្នុងនោះ 2 នាក់ទទួលបានការឧបត្ថម្ភពី Agrisud ហើយជាចុងក្រោយនឹងត្រូវដាក់បញ្ចូលក្នុងរចនាសម្ព័ន្ធ GF ទាំងស្រុង។

## ការកំណត់លក្ខណៈគុណភាពដែលត្រូវការ និងបញ្ហាសំខាន់ៗចំពោះអ្នកផលិត

### គុណភាពដែលត្រូវការ

- ផលិតផលសុវត្ថិភាពក្នុងស្រុក
- បរិមាណជាអប្បបរមាដែលត្រូវការ
- ការធ្វើពិពិធកម្មផលិតផល
- ការផ្គត់ផ្គង់ទៀងទាត់ (ប្រចាំថ្ងៃ) សេវាដឹកជញ្ជូន
- តម្រូវការវិញ្ញាបនបត្រអនាម័យសម្រាប់ផលិតផលកែច្នៃ (GMP)

### បញ្ហាសំខាន់ៗ

- កសិដ្ឋានលក្ខណៈគ្រួសារខ្នាតតូចមិនអាចផ្គត់ផ្គង់តាមបរិមាណដែលត្រូវការ មិនមានភាពទៀងទាត់ និងមិនមានផលិតផលចម្រុះតាមតម្រូវការចំពោះបុគ្គលម្នាក់ៗនោះទេ។
- មានតម្រូវការក្នុងការកសាងសមត្ថភាពបច្ចេកទេស។
- ពិបាកក្នុងការរក្សាបានផលិតកម្មជាប្រចាំពេញមួយឆ្នាំ៖ ទឹកស្រកនៅរដូវប្រាំង ទឹកជំនន់នៅរដូវវស្សា។
- ការប្រកួតប្រជែងក្នុងការដាំដំណាំស្រូវ (កម្លាំងពលកម្ម និងសាច់ប្រាក់)។
- ចំណេះដឹងតិចតួចអំពីតម្រូវការគុណភាពដើម្បីបំពេញតាមតម្រូវការក្នុងស្រុក និងនីតិវិធីនៃការទិញ។
- បញ្ហាលំហូរសាច់ប្រាក់។
- ការប្រកួតប្រជែងជាមួយនឹងការនាំចូលបន្លែពីប្រទេសជិតខាង។

## សនិទានភាពនៃកិច្ចអន្តរាគមន៍របស់សមាជិក GI

វិធីសាស្ត្ររបស់ Agrisud គឺជាដំបូងដើម្បីពង្រឹងសមត្ថភាពផលិតកម្មសួនទីផ្សាររបស់កសិដ្ឋានលក្ខណៈគ្រួសារៈ ការអនុវត្តផ្នែកកសិអេកូឡូស៊ី និងការបណ្ដុះបណ្ដាលក្រោយការប្រមូលផល ការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការរៀបចំផែនការយុទ្ធនាការ។ វាពឹងផ្អែកលើប្រព័ន្ធអ្នកផលិត "កសិករចំណាន" ដើម្បីត្រួតពិនិត្យ និងផ្តល់ការណែនាំកសិកម្ម ក៏ដូចជាការបង្កើត និងពង្រឹងអង្គភាពវិជ្ជាជីវៈ និងសង្គម រួមទាំងក្រុមកែច្នៃកសិចំណីអាហារចំនួនប្រាំ (ប្រេងរុក្ខជាតិ គ្រឿងទេសស្ងួត ទឹកផ្លែឈើ ទឹកផ្លែឈើ។ល។)។ បន្ទាប់មកគម្រោងក៏បានបង្កើតសមាគមកសិករបៃតង ដើម្បីជួយឱ្យកសិដ្ឋានលក្ខណៈគ្រួសារក្នុងមូលដ្ឋានបំពេញតាមតម្រូវការទីផ្សារ ជាពិសេសបរិមាណជាអប្បបរមា ភាពទៀងទាត់ និងបន្លែចម្រុះដែលចង់បាន។ ជម្រើសយុទ្ធសាស្ត្រពាណិជ្ជកម្ម គឺផ្តោតអាទិភាពលើទីផ្សារធំៗ (សណ្ឋាគារ ភោជនីយដ្ឋាន) ដែលអាចរកប្រាក់ចំណេញបានច្រើន និងអាចរ៉ាប់រងការចំណាយលើការគ្រប់គ្រងគុណភាព និងអង្គភាពបានកាន់តែប្រសើរ។ សមាគមបានធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ខ្លួន (ការធ្វើពិពិធកម្ម ការអភិវឌ្ឍក្រៅរដូវ ការបង្កើតផ្ទះកញ្ចក់ និងរានដាំដុះ) និងដើម្បីកែលម្អ បណ្ដាញទីផ្សារ (សិក្ខាសាលាអន្តរវិជ្ជាជីវៈ ការបង្រួមខ្សែសង្វាក់ ការធ្វើមជ្ឈការ និងផែនការផ្គត់ផ្គង់របស់ GF) ។ ទន្ទឹមនឹងនេះដែរ GF បង្កើនការយល់ដឹងក្នុងចំណោមតួអង្គដែលនៅខាងចុងផ្នែកលំហូរខាងក្រោមក្នុងក្រុងសៀមរាប (សណ្ឋាគារ ភោជនីយដ្ឋាន និងសាលារៀន) និងអ្នកប្រើប្រាស់ លើបញ្ហាផលិតកម្មប្រកបដោយនិរន្តរភាព (យុទ្ធនាការទំនាក់ទំនង ពិព័រណ៍ពាណិជ្ជកម្ម។ល។)។ តាមរយៈនេះ យើងអាចបែងចែកភាពខុសគ្នារវាងផលិតផលនៅលើទីផ្សារក្នុងស្រុក (ជាពិសេសទីផ្សារប្រចាំសប្តាហ៍ ការផ្សព្វផ្សាយផលិតផលនៅលើបណ្តាញសង្គម ការអភិវឌ្ឍម៉ាកផ្ទាល់ខ្លួន)។

ចំពោះការគ្រប់គ្រងគុណភាព GF បានជួយគាំទ្រដល់ការកំណត់រួមគ្នានូវលក្ខណៈវិនិច្ឆ័យផ្ទៃក្នុងសម្រាប់ការអនុវត្ត និងគុណភាពដែលស្របទៅនឹងប្រព័ន្ធផលិតកម្មរបស់អ្នកផលិត និងឧបសគ្គនានា។ ការត្រួតពិនិត្យផ្ទៃធ្វើឡើងដោយសមាជិកសហគមន៍កសិកម្មបៃតង (ការចុះទៅជួបកសិករផ្ទាល់ ការធ្វើសៀវភៅកំណត់ហេតុ) ជាមួយនឹងការតាមដានប្រចាំខែពីការិយាល័យ GF ។ ការត្រួតពិនិត្យផ្ទៃក្នុងនេះក៏ត្រូវបានគេមើលឃើញថាជាជំហានដំបូងឆ្ពោះទៅរកការធ្វើវិញ្ញាបនកម្មខាងក្រៅ (GMP – ការអនុវត្តការផលិតល្អ, CS – ស្តង់ដារកម្ពុជា HACCP, ISO) ដែលជាតម្រូវការចាំបាច់ ដើម្បីពង្រឹងភាពជឿជាក់ក្នុងការអនុវត្តរបស់ GF ។

## តួនាទីរបស់សមាជិក GI អំឡុងពេលដំណើរការអភិវឌ្ឍន៍

Agrisud ផ្តល់ការគាំទ្រដល់ GF លើផ្នែកផលិតកម្ម (ការអនុវត្តកសិអេកូឡូស៊ី ដំណើរការកែច្នៃ ការកំណត់ស្តង់ដារ) និងសមាសធាតុរបស់អង្គភាព (ការបង្កើតការត្រួតពិនិត្យផ្ទៃក្នុង អភិបាលកិច្ច GF)។ ស្ថាប័ននេះបានគាំទ្រយ៉ាងខ្លាំងដល់ GF ក្នុងការអភិវឌ្ឍអាជីវកម្មជាពិសេសតាមរយៈការសម្របសម្រួលទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈ (សាលាសណ្ឋាគារ)។ ជាចុងក្រោយ Agrisud ចូលរួមចំណែកក្នុងការសន្ទនានយោបាយ និងបច្ចេកទេសជាមួយអាជ្ញាធរខេត្ត ក្នុងការអនុវត្តដោយប្រើស្លាកសមូហភាព។ លើសពីនេះ ស្ថាប័នបន្តផ្តល់ជំនួយហិរញ្ញវត្ថុដល់ GF រួមទាំងការបញ្ជូនបុគ្គលិកពីរូបឱ្យកាន់តួនាទីជានាយក និងតំណាងផ្នែកលក់។

## លទ្ធផលគម្រោង និងផលប៉ះពាល់

- គាំទ្រដល់កសិដ្ឋានលក្ខណៈគ្រួសារចំនួន 1,970 ស្មើនឹង 90% នៃផលិតកម្មកសិកម្មដែលមាននៅលើទីផ្សារ។
- ចូលទៅកាន់ទីផ្សារបុព្វលាភ (60% នៃហាងរបស់ GF)៖ ការធ្វើពិពិធកម្មផលិតកម្ម (រួមទាំងបន្លែ "បស្ចិមប្រទេស" ការបង្កើនសមត្ថភាពដឹកជញ្ជូន អង្គភាពផ្នែកភស្តុភារ)។
- សមត្ថភាពបច្ចេកទេស និងការគ្រប់គ្រងល្អដែលត្រូវបានបង្កើតឡើងនៅក្នុង GF ធនធានមនុស្សមានស្ថេរភាពមួយផ្នែក។
- បង្កើនចំណេះដឹងរបស់ភាគីពាក់ព័ន្ធនៅផ្នែកលំហូរខាងក្រោម អំពីផលិតកម្មក្នុងស្រុកដែលមានស្រាប់ គុណភាពផលិតផលរបស់ GF ផលប៉ះពាល់នៃការផ្គត់ផ្គង់ក្នុងស្រុកលើការអភិវឌ្ឍក្នុងមូលដ្ឋាន និងប្រព័ន្ធស្បៀងអាហារប្រកបដោយនិរន្តរភាព។




កសិករចំណាននៅជ្រៃ ពិនិត្យតាមដានជាមួយអ្នកទទួលផល នៅឆ្នាំ 2023

## កត្តាអនុគ្រោះ និងកត្តាដែនកំណត់នៃកិច្ចអន្តរាគមន៍

| កត្តាអនុគ្រោះ | កត្តាដែនកំណត់ |
|---|---|
| **ចំពោះការគ្រប់គ្រងគុណភាព** | |
| • ផលិតកម្មសម្របតាមប្រព័ន្ធបច្ចុប្បន្ន មិនត្រូវការការផ្លាស់ប្តូរជាដុំកំភួនទេ។<br>• ការបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងស្របទៅនឹងប្រព័ន្ធផលិតកម្មរបស់កសិករ និងទទួលស្គាល់ដោយតួអង្គនៅផ្នែកលំហូរខាងក្រោម។<br>• ការផ្លាស់ប្តូរព័ត៌មានជាទៀងទាត់រវាងអ្នកផលិត ដើម្បីចែករំលែកបទពិសោធន៍។<br>• កិច្ចប្រជុំអន្តរវិជ្ជាជីវៈពីរដងក្នុងមួយឆ្នាំ ដើម្បីលើកកម្ពស់ការចែករំលែកព័ត៌មានពីអ្នកប្រមូលទិញ ទាក់ទងនឹងគុណភាព និងបរិមាណដែលរំពឹងទុក។<br>• ការចូលរួមរបស់យុវជន (ដែលចេះអក្សរ) ដើម្បីចងក្រងឯកសារត្រួតពិនិត្យគុណភាព។<br>• យុទ្ធនាការទំនាក់ទំនងតាមរយៈពិព័រណ៍ ផ្ទះបើកចំហសម្រាប់ការចូលទស្សនាបណ្តាញសង្គម គេហទំព័រ។ល។ | • មានការដាក់កំហិតខ្លាំងលើការបែងចែកពេលវេលាធ្វើការដើម្បីផលិតបន្លែសុវត្ថិភាព និង/ឬបន្លែសរីរាង្គ បើធៀបទៅនឹងវិធីសាស្ត្រធម្មតា។<br>• ខ្វះពូជដែលមានគុណភាព។<br>• ហានិភ័យនៃបន្ទុកការងារខ្ពស់មកលើកសិករចំណាន (ប្រហែល 30 នាក់ ដែលត្រូវចុះពិនិត្យតាមដាន)<br>• ចំណាយប្រតិបត្តិការនៅតែរ៉ាប់រងដោយ Agrisud (បុគ្គលិកចំនួនពីររូប)។<br>• ទីផ្សារផលិតផលកែច្នៃទាមទារឱ្យមានលក្ខណៈស្តង់ដារដើម្បីឈានចូលទីផ្សារបាន។<br>• ផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ៖ ផលរំខានដល់ហាងលក់កសិផលមួយចំនួននៅលើទីផ្សារប្រចាំសប្តាហ៍ និងប្រតិបត្តិករទេសចរណ៍។ |

### ចំពោះការគ្រប់គ្រងអង្គភាព

- ផលប្រយោជន៍សេដ្ឋកិច្ចរបស់អ្នកផលិត ក្នុងការចូលរួមជាមួយអង្គភាព (កន្លែងលក់ដែលមានសុវត្ថិភាព និងអាចរកបានប្រាក់ចំណេញ)។
- អង្គភាពមូលដ្ឋានបង្កើតឡើងនៅក្នុងសហគមន៍ដែលមានស្រាប់ (ការគ្រប់គ្រងសង្គម និងបទប្បញ្ញត្តិ)។
- កសិករចំណានមានការបណ្តុះបណ្តាល និងបទពិសោធន៍ក្នុងតួនាទីជាអ្នកដឹកនាំ។
- ស្ថិរភាពហិរញ្ញវត្ថុសម្រាប់រ៉ាប់រងការចំណាយរបស់បុគ្គលិក 10 រូបក្នុងចំណោមបុគ្គលិក 12 រូបរបស់ GF។
- បុគ្គលិក GF ធ្លាប់មានបទពិសោធន៍ផ្នែកទីផ្សារ និងពាណិជ្ជកម្ម។
- មានការសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរពាណិជ្ជកម្មខេត្ត និងគម្រោង APICI ។
- ចំណាយតិចលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (សំណាងសម្រាប់កសិករចំណាន)។
- ការសាងសង់ហាងលក់ផលិតផលក្នុងស្រុករួមគ្នាជាមួយអង្គភាពផ្សេងទៀត (Gret, CIRD ។ល។)

- ជាចុងក្រោយ រចនាសម្ព័ន្ធសមាគមនេះមិនបានផ្សារភ្ជាប់ជាមួយនឹងសកម្មភាព និងការអភិវឌ្ឍឱ្យបានយូរអង្វែង។ ការបង្កើតសហគ្រាស (សង្គម) នឹងធ្វើអាជីវកម្មប្រកបដោយវិជ្ជាជីវៈ និងសម្រួលដល់ការអភិវឌ្ឍរបស់ខ្លួន។
- ផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ៖ កសិករបៃតងបានឃើញមានការរំសាយកសិដ្ឋានជាសមាជិកក្នុងចំនួនយ៉ាងច្រើនពោលគឺ ពីជាង 800 ក្នុងឆ្នាំ 2020 មកនៅក្រោម 419 កសិដ្ឋាន គិតហូតមកទល់បច្ចុប្បន្ន។

## មេរៀន និងអនុសាសន៍សំខាន់ៗ

- ការកែលម្អខ្សែសង្វាក់ផ្គត់ផ្គង់សម្រាប់សណ្ឋាគារ និងភោជនីយដ្ឋាន ឬការបង្កើនចំណែកផលិតផលក្នុងស្រុកនៅក្នុងការផ្គត់ផ្គង់ទាំងនេះ គឺជាមធ្យោបាយមួយ ដើម្បីលើកកម្ពស់កម្រិតជីវភាពរបស់អ្នកផលិត មិនមែនគោលដៅតែមួយមុខនោះទេ។
- រៀបចំរចនាសម្ព័ន្ធទីផ្សារ គាំទ្រការវិនិយោគដែលចាំបាច់ក្នុងការបង្កើតទីផ្សារ និងសម្របសម្រួលការបង្កើតពេងកែច្នៃ ដើម្បីធានានិរន្តរភាពនៃសង្វាក់កសិកម្ម។
- ត្រូវបង្កើតអង្គភាពកសិករតំណាងដែលរឹងមាំ និងមានរចនាសម្ព័ន្ធល្អ ហើយអាចការពារផលប្រយោជន៍របស់ខ្លួន។
- ធានាឱ្យមានទំនាក់ទំនងដោយផ្ទាល់រវាងអ្នកផលិត និងអ្នកប្រើប្រាស់ ដើម្បីកសាងការជឿជាក់លើគុណភាពនៃផលិតផល និងស្តង់ដារគុណភាព សម្របតាមសមត្ថភាពកសិករ និងតម្រូវការរបស់អតិថិជន។
- អភិវឌ្ឍសមត្ថភាពរបស់អ្នកផលិតក្នុងការវិភាគតម្រូវការទីផ្សារ ការប្រែប្រួលតម្លៃ និងធ្វើការពិគ្រោះយោបល់ជាមួយអ្នកផលិត ដើម្បីកែលម្អកាលវិភាគកសិកម្ម និងជម្រើសផលិតកម្មឱ្យបានសមរម្យ។
- បង្កើតរចនាសម្ព័ន្ធទីផ្សារ ដែលមានតួនាទីជាអ្នកលក់ដុំ និងផ្គត់ផ្គង់ភោជនីយដ្ឋាន និងសណ្ឋាគារ ដូចជាសហគមន៍កសិកម្មបៃតង។
- បង្កើតឧបករណ៍ទំនាក់ទំនង និងភស្តុភារ ដើម្បីកែលម្អសមត្ថភាពក្នុងការផ្សារភ្ជាប់រវាងការផ្គត់ផ្គង់ និងតម្រូវការ (ឧទាហរណ៍ អ៊ីនធឺណិត/ថ្នាលប្រព័ន្ធសារ SMS) ដូចដែលកសិករបៃតងបានធ្វើ។

# ការអភិវឌ្ឍប្រព័ន្ធកសិដ្ឋានចិញ្ចឹមត្រីខ្នាតតូចក្នុងបរិស្ថានស្មុគស្មាញ ដើម្បីបំពេញតម្រូវការក្នុងស្រុក

## ព័ត៌មានសាវតាអំពីករណីសិក្សា

- គម្រោងអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃកសិដ្ឋានចិញ្ចឹមត្រី (DeFiP)៖ ដើម្បីកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងធ្វើពិពិធកម្មជីវភាពរស់នៅរបស់ប្រជាជននៅតាមជនបទ តាមរយៈការអភិវឌ្ឍកសិដ្ឋានចិញ្ចឹមត្រីកសិអេកូឡូស៊ីលក្ខណៈគ្រួសារសម្រាប់ទីផ្សារក្នុងស្រុក។
- រយៈពេលអនុវត្ត៖ ដំណាក់កាលទី 1 (2020-2022), ដំណាក់កាលទី 2 (2022-2025)
- ម្ចាស់ជំនួយធំៗ៖ AFD; ទីតាំង៖ ខេត្តសៀមរាប និងខេត្តកំពង់ធំ
- ដៃគូអនុវត្តក្នុងស្រុក៖ អង្គភាព Trailblazer Cambodia (TCO)

## ការបង្ហាញអំពីខ្សែសង្វាក់តម្លៃ

- ភាគីពាក់ព័ន្ធ៖ កសិដ្ឋានលក្ខណៈគ្រួសារ (អ្នកទទួលផលគម្រោង) ឈ្មួញកណ្ដាល
- ផលិតកម្ម៖ សកម្មភាពបន្ទាប់បន្សំ ការដាំដុះ (រាប់សិបប្រភេទ) និងការចិញ្ចឹម (ត្រីទីឡាព្យា) ប្រព័ន្ធកសិដ្ឋានចិញ្ចឹមត្រីសំខាន់ៗចំនួនបី (ស្រះទឹក បែក្នុងស្រះទឹក និងការចិញ្ចឹមត្រីដោយផ្ដល់ចំណីកន្ទក់)
- ហាងលក់ទំនិញ៖ ជាចម្បងសម្រាប់ការបរិភោគផ្ទាល់ខ្លួន លក់ដោយផ្ទាល់នៅលើទីផ្សារក្នុងស្រុក (ភូមិ) និងឈ្មួញកណ្ដាលប៉ុន្តែមិនសូវញឹកញាប់ទេ។
- អង្គភាព៖ មិនមានអង្គភាពផ្លូវការទេ ការបង្កើតបណ្ដាញចំនួនប្រាំមួយក្រុមដែលមានកសិករចិញ្ចឹមត្រីពី 10 ទៅ 40 នាក់ សម្រាប់បណ្ដុះបណ្ដាល ផ្លាស់ប្ដូរទស្សនកិច្ច និងពិភាក្សាគ្នា។

## ការកំណត់លក្ខណៈគុណភាពដែលត្រូវការ និងបញ្ហាសំខាន់ៗចំពោះអ្នកផលិត

### គុណភាពដែលត្រូវការ

- ប្រភេទត្រីចម្រុះទៅតាមចំណង់ចំណូលចិត្ត និងទីផ្សារ។
- ទំហំល្អបំផុតតាមការតម្រូវរបស់ឈ្មួញកណ្ដាល យោងទៅតាមប្រភេទត្រី តម្រូវការខ្លះៗរបស់អ្នកភូមិ។
- បរិមាណច្រើនតាមសំណើរបស់ឈ្មួញកណ្ដាល និងជាទៀងទាត់តាមការកំណត់។
- យល់ឃើញថាមានគុណភាពប្រសើរជាងមុនក្នុងអំឡុងខែមីនាដល់ខែមិថុនា នៅពេលដែលការចិញ្ចឹមត្រីមិនសូវមានការប្រកួតប្រជែងជាមួយវិស័យជលផល។

### បញ្ហាសំខាន់ៗ

- តម្លៃជាប់ពាក់ព័ន្ធយ៉ាងខ្លាំងជាមួយនឹងគុណភាពត្រីដែលប្រមូលផលបាន។
- កង្វះឯកសារយោងផ្នែកបច្ចេកទេស និងហិរញ្ញប្បទាន ដើម្បីពង្រឹងផលិតកម្មលើផ្ទៃដីតូចៗ៖ ហានិភ័យខ្ពស់ និងកម្រិតប្រាក់ចំណេញទាប។
- ហានិភ័យទាក់ទងនឹងការប្រែប្រួលភ្លៀងធ្លាក់តាមរដូវកាលដែលពិបាកព្យាករ៖
  - ▸ រដូវវស្សា៖ ទឹកលិចស្រះ ត្រីរួចចេញពីស្រះ និងមានសត្វស៊ីសាច់សត្វដទៃទៀតចូលមកក្នុងស្រះ
  - ▸ រដូវប្រាំង៖ កង្វះទឹក និងហានិភ័យនៃការបំពុល
- កង្វះលទ្ធភាពចូលទៅកាន់ទីផ្សារ៖ ពិបាកក្នុងការបំពេញតម្រូវការ (ទំហំ បរិមាណ)
- ចំណូលចិត្តរបស់អ្នកប្រើប្រាស់ដែលចូលចិត្តត្រីព្រៃជាងផលិតផលត្រីដែលមិនសូវមានរសជាតិឆ្ងាញ់ (ប៉ុន្តែមានការធ្លាក់ចុះ)

## សនិទានភាពនៃកិច្ចអន្តរាគមន៍របស់សមាជិក Gi

គម្រោងនេះបានជ្រើសយកវិធីសាស្ត្រដែលមានការចូលរួមជាមួយកសិករចិញ្ចឹមត្រី ដើម្បីធ្វើតេស្តសាកល្បង និងសហការបង្កើតប្រព័ន្ធកសិដ្ឋានចិញ្ចឹមត្រីស្របតាមបរិបទបច្ចេកទេស សង្គម និងសេដ្ឋកិច្ចរបស់ខ្លួន ដែលមានសមត្ថភាពផលិតត្រីដែលមានគុណភាពតាមការរំពឹងទុករបស់ខ្លួន។ គោលដៅចម្បង គឺផ្ដោតលើការស្វែងយល់អំពីកសិករ និងជម្រើសរបស់កសិករ ពិភាក្សាអំពីបញ្ហាប្រឈមរបស់កសិករ ដើម្បីរួមគ្នាស្វែងរកដំណោះស្រាយដែលសមស្រប និងធ្វើការពិសោធន៍ដើម្បីឆ្លើយតបនឹងបញ្ហារបស់ខ្លួន។ APDRA សហការជាមួយវិទ្យាស្ថានស្រាវជ្រាវ CIRAD ដើម្បីគាំទ្រដល់ការស្រាវជ្រាវវិទ្យាសាស្ត្រជាផ្នែកមួយនៃដំណើរការ។ គម្រោងនេះបានជ្រើសរើសគាំទ្រអ្នកផលិតដើម្បីកែលម្អស្រះទឹកដែលបានជីកមុនគម្រោងឱ្យប្រសើរឡើង ក្នុងគោលបំណងកាត់បន្ថយការចំណាយលើការវិនិយោគ។ ការគាំទ្រផ្នែកហិរញ្ញវត្ថុមានដែនកំណត់ត្រឹមការចំណាយលើការទិញពូជកូនត្រី នៅឆ្នាំដំបូងដែលចូលរួមនៅក្នុងគម្រោងនេះ។ ជាចុងក្រោយនឹងអនុវត្តវិធីសាស្ត្រដែលមិនមានការឧបត្ថម្ភមូលនិធិ។ ដំណើរការនេះពឹងផ្អែកលើបណ្ដាញកសិករ ដើម្បីបង្កើតសក្ដានុពលសង្គម។ ក្រុមកសិករតូចៗត្រូវបានបង្កើតឡើងតាមវិស័យ។

## តួនាទីរបស់សមាជិក Gi អំឡុងពេលដំណើរការអភិវឌ្ឍន៍

APDRA គាំទ្រកសិករចិញ្ចឹមត្រីទាំងផ្នែកបច្ចេកទេស និងក្នុងរង្វង់អង្គភាពរបស់ខ្លួននៅក្នុងដំណើរការអភិវឌ្ឍន៍អាជីវកម្មរបស់ខ្លួនទាំងមូល។ ទាំងនេះពាក់ព័ន្ធនឹងការត្រួតពិនិត្យវាយតម្លៃយ៉ាងល្អិតល្អន់ ការសិក្សាស៊ីជម្រៅ កិច្ចប្រជុំដែលមានការចូលរួមពីភាគីពាក់ព័ន្ធ និងការវាយតម្លៃបែបវិទ្យាសាស្ត្រលើផលិតផលនវានុវត្តន៍។ APDRA មិនដើរតួនាទីជំនួសកសិករទេ ប៉ុន្តែផ្តល់ការគាំទ្រដល់គំនិតផ្តួចផ្តើមរបស់កសិករ។ នេះបង្ហាញពីការផ្តល់ហិរញ្ញប្បទានតូចៗ ជានានូវសេរីភាពនៃការជ្រើសរើសជម្រើសរបស់កសិករ និងភាពឯករាជ្យរបស់ក្រុមកសិករ។ APDRA មិនមែនជាអង្គភាពពាណិជ្ជកម្មនៅក្នុងខ្សែសង្វាក់តម្លៃទេ ហើយក៏មិនទទួលខុសត្រូវដោយផ្ទាល់លើការគ្រប់គ្រងឬអភិវឌ្ឍអាជីវកម្មក្នុងនាមកសិករដែរ។

## លទ្ធផលគម្រោង និងផលប៉ះពាល់

- លទ្ធផលដំបូងក្នុងឆ្នាំ 2022 មិនល្អប្រសើរខ្លាំង (ទិន្នផល ទម្ងន់ អត្រារស់) ប្រសើរឡើងនៅឆ្នាំ 2023 (30% នៃវដ្តអាចរកបានប្រាក់ចំណេញសុទ្ធលើសពី 100 ដុល្លារអាមេរិក10% នៃវដ្តអាចរកបានប្រាក់ចំណេញសុទ្ធលើសពី 200 ដុល្លារអាមេរិក)។
- ផ្តោតលើសកម្មភាពស្រាវជ្រាវ និងកំណត់មាគ៌ាបច្ចេកទេសដែលជោគជ័យ។
- កែលម្អការគ្រប់គ្រងវដ្តផលិតកម្មរបស់សិករចិញ្ចឹមត្រី។
- គុណភាព និងបរិមាណ នៅតែមិនមានស្ថិរភាពគ្រប់គ្រាន់សម្រាប់កសិករក្នុងការធ្វើការរួមគ្នា ដើម្បីស្វែងរកឈ្មួញកណ្តាលគោលដៅ។

## កត្តាអនុគ្រោះ និងកត្តាដែនកំណត់នៃកិច្ចអន្តរាគមន៍

**ចំពោះការគ្រប់គ្រងគុណភាព**

### កត្តាអនុគ្រោះ

- វិធីសាស្ត្រដែលមានការចូលរួមពីភាគីពាក់ព័ន្ធ និងសហការជាមួយកសិករចិញ្ចឹមត្រី ក្នុងការរៀបចំឯកសារយោងសម្រាប់ពួកគេ ការត្រួតពិនិត្យវាយតម្លៃល្អប្រសើរ។
- ការប្រើប្រាស់ពូជត្រីដែលកសិករចិញ្ចឹមត្រីធ្លាប់ស្គាល់។
- ការស្តារស្រះដែលមានស្រាប់ អនុញ្ញាតឱ្យការអនុវត្តអន្តរាគមន៍ជាក់លាក់ប្រកបដោយប្រសិទ្ធភាព (ការចំណាយតិចលើការវិនិយោគ)។
- ការបង្កើតបណ្តាញកសិករៈ ជាគន្លឹះក្នុងការផ្ទេរផលិតផលនវានុវត្តន៍ និងការដោះស្រាយបញ្ហា។

### កត្តាដែនកំណត់

- សកម្មភាពបន្ទាប់បន្សំដែលមានហានិភ័យចំពោះអ្នកផលិតផ្តោតគោលដៅលើអ្នកផលិតដែលទទួលបានការលើកទឹកចិត្ត។
- វិធីសាស្ត្រស្រាវជ្រាវតាមរយៈសកម្មភាពដែលមានការចូលរួមពីភាគីពាក់ព័ន្ធ នឹងមានលទ្ធផលចម្រុះនៅពេលចាប់ផ្តើមដំណើរការ។
- ការងារចិញ្ចឹមត្រីជោគជ័យកន្លងមក។
- ការវាស់ស្ទង់មហិច្ឆតាអាស្រ័យលើបរិបទអាកាសធាតុ (ទឹកជំនន់ និងគ្រោះរាំងស្ងួត) និងការប្រកួតប្រជែងជាមួយត្រីព្រៃ។

## មេរៀន និងអនុសាសន៍សំខាន់ៗ

- ចាំបាច់ត្រូវកែសម្រួលការអនុវត្តឱ្យមានលក្ខណៈសមស្របទៅតាមបរិបទជាក់ស្តែងរបស់អ្នកផលិតនីមួយៗ (ប្រភេទដី បរិមាណទឹក) បើនិយាយពីផ្នែកបច្ចេកទេស និង (ពេលវេលា ថវិកាដែលមាន)បើនិយាយពីលក្ខខណ្ឌសេដ្ឋកិច្ចសង្គម។ មិនស្វែងរកដំណោះស្រាយដែលមានលក្ខណៈស្តង់ដារនោះទេ។
- រៀបចំផែនការមុនពេលចាប់ផ្តើមវដ្តៈ កំណត់លទ្ធផលចុងក្រោយដែលចង់បាន ទាក់ទងនឹងពូជត្រី ទម្ងន់ត្រីនីមួយៗ និងពេលវេលា។
- ទទួលបានពូជកូនត្រីពីប្រភពដែលអាចទុកចិត្តបាន និងគោរពតាមការអនុវត្តល្អៗក្នុងការជ្រើសរើស ដឹកជញ្ជូន ដាក់ក្នុងស្រះ និងបន្សាំកូនត្រីជាមួយនឹងបរិយាកាសថ្មី។
- កំណត់ និងព្យាករទុកជាមុនហានិភ័យអាកាសធាតុ (ទឹកជំនន់ និងកង្វះទឹកក្នុងរដូវប្រាំង) ដោយបង្កើតផែនការគ្រប់គ្រង (ទំនប់ ស្រះច្រើន)។
- គិតគូរពីយុទ្ធសាស្រ្តទីផ្សារ ទាក់ទងអ្នកទិញមុនពេលប្រមូលផល។
- ក្នុងបរិបទកង្វះឯកសារយោងផ្នែកបច្ចេកទេស លើកទឹកចិត្តកសិករឱ្យចេះច្នៃបង្កើត និងសាកល្បងបច្ចេកទេសថ្មីៗ ដើម្បីកំណត់ពីឱកាសជោគជ័យ។



លោកស្រី ថៃ ឡាំ កសិករចិញ្ចឹមត្រី កំពុងឱ្យចំណីត្រី

# ការអភិវឌ្ឍខ្សែសង្វាក់តម្លៃអង្ករសរីរាង្គ ជាមួយសហភាពសហគមន៍ព្រះវិហារមានជ័យ

## ព័ត៌មានសាវតាអំពីករណីសិក្សា

- សកម្មភាពអភិវឌ្ឍខ្សែសង្វាក់តម្លៃអង្ករសរីរាង្គទ្រង់ទ្រាយធំនៅក្នុងខេត្តព្រះវិហារ (ធ្វើឡើងក្នុងក្របខណ្ឌគម្រោងគាំទ្រពាណិជ្ជកម្មអង្ករកម្ពុជា – SCCRP) ។ ការតាមដានគម្រោងរួមគ្នារវាង AVSF-Ethiquable និងបេសកកម្មខ្លីៗក្នុងក្របខណ្ឌគម្រោង ASPIRE។
- រយៈពេលអនុវត្ត៖ 2013-2017 (SCCRP), 2017-2023 (AVSF-Ethiquable), 2018-2021 (ASPIRE)
- ម្ចាស់ជំនួយធំៗ៖ AFD, IFAD, Ethquable; ទីតាំង៖ ខេត្តព្រះវិហារ

## ការបង្ហាញខ្សែសង្វាក់តម្លៃ និងអង្គភាពដែលភ្ជាប់មកជាមួយ

- ភាគីពាក់ព័ន្ធ៖ កសិដ្ឋានលក្ខណៈគ្រួសារ សហគមន៍កសិកម្ម និងសហភាពសហគមន៍ (អ្នកទទួលផលគម្រោង) រោងម៉ាស៊ីនកិនស្រូវ អ្នកលក់ដុំ និងអ្នកលក់រាយ អ្នកនាំចេញ។
- ផលិតកម្ម៖ ពូជអង្ករផ្កាម្លិះសរីរាង្គចំនួនបីប្រភេទ និងអង្ករសរីរាង្គមួយប្រភេទដែលមានការបញ្ជាក់ត្រឹមត្រូវ។
- ហាងលក់ទំនិញ៖ ទីផ្សារនាំចេញអាមេរិកខាងជើង និងអឺរ៉ុប (វិញ្ញាបនបត្រ NOP និង EOS)។
- អង្គភាព៖ សហភាពសហគមន៍កសិកម្មព្រះវិហារមានជ័យ (PMUAC)។ ទទួលខុសត្រូវការគ្រប់គ្រងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ទទួលវិញ្ញាបនបត្រ ពង្រឹងសមត្ថភាពបច្ចេកទេសសម្រាប់ផលិតកម្មសរីរាង្គ និងសម្របសម្រួលការតភ្ជាប់ជាមួយទីផ្សារ។ ចុះបញ្ជីនៅឆ្នាំ 2016 សហភាពនេះមានសហគមន៍កសិកម្មចំនួន 25 ជាសមាជិក (5.403 គ្រួសារ) និងបុគ្គលិកចំនួន 12 នាក់ ។

## ការកំណត់លក្ខណៈគុណភាពដែលត្រូវការ និងបញ្ហាសំខាន់ៗចំពោះអ្នកផលិត

| គុណភាពដែលត្រូវការ | បញ្ហាសំខាន់ៗ |
|---|---|
| • វិញ្ញាបនបត្រសរីរាង្គ (NOP, EOS)<br>• ប្រភេទពូជសុទ្ធ<br>• កម្រិតសំណើម<br>• អត្រាគ្រាប់បាក់បែក<br>• វិញ្ញាបនបត្រ SPP ពិរព័រណ៍ពាណិជ្ជកម្ម (បរិមាណតូច និងអ្នកទិញតែមួយ) | • ធានា និងរក្សាបាននូវវិញ្ញាបនបត្រ "កសិកម្មសរីរាង្គ"<br>• កង្វះកម្លាំងពលកម្ម និងមានការលំបាកក្នុងការទទួលបានគ្រឿងយន្តសម្រាប់ប្រមូលកសិផល ធ្វើឱ្យការប្រមូលទិន្នផលមិនបានល្អ៖ អត្រាគ្រាប់បាក់បែកខ្ពស់ និងសំណើមមិនល្អ<br>• កង្វះកម្លាំងពលកម្ម និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ បង្ខំឱ្យកសិករធ្វើការសាបព្រោះដោយផ្ទាល់ជាជាងបន្តរៀបចំថ្នាល/ស្ទូង ៖ បញ្ហាបន្ថែមជាមួយស្មៅ<br>• ធ្វើពិពិធកម្មអ្នកទិញ ដើម្បីជៀសវាងស្ថានភាពផ្តាច់មុខ |

## សនិទានភាពនៃកិច្ចអន្តរាគមន៍របស់សមាជិក Gi

នៅកម្រិតបច្ចេកទេស ជំនួយដំបូងពី AVSF និង Iram រួមមានការរួមបញ្ចូលគ្នានូវការអនុវត្តផលិតកម្មស្រូវសរីរាង្គរបស់សហគមន៍ដែលមានស្រាប់នៅក្នុងគម្រោងនេះ ទីមួយតាមរយៈកិច្ចសន្យាជាមួយសមាគមកសិកម្មសរីរាង្គកម្ពុជា (COrAA) បន្ទាប់មកការរៀបចំផ្ទៃក្នុងនូវជំនាញផ្នែកយថាប្រភេទ និងត្រួតពិនិត្យសរីរាង្គនៅក្នុង PMUAC ។ ខាងផ្នែកពាណិជ្ជកម្ម រួមមានយុទ្ធសាស្ត្របង្កើតកិច្ចសន្យាផ្គត់ផ្គង់ប្រចាំឆ្នាំរវាងសហគមន៍ និងអ្នកទិញ ហើយពឹងផ្អែកលើស្តង់ដារ និងស្លាកសញ្ញាខាងក្រៅ ជាពិសេស វិញ្ញាបនបត្រសរីរាង្គ (NOP និង EOS) ប៉ុន្តែក៏មានការបង្កើតម៉ាកសមូហភាពផងដែរ ដែលនឹងអនុញ្ញាតឱ្យមានតម្លៃតបស្នងពីគុណភាពនៃអង្ករផ្កាម្លិះខេត្តព្រះវិហារ។ ការកំណត់ និងថែរក្សាគុណភាពតម្រូវឱ្យមានការ បង្កើតរចនាសម្ព័ន្ធគ្រប់គ្រង និងផ្សព្វផ្សាយជាសមូហភាព ពោលគឺសហភាពសហគមន៍ (PMUAC) ដោយរក្សាសិទ្ធិទីផ្សារ (កិច្ចសន្យាជាមួយរោងម៉ាស៊ីនកិនស្រូវ) សម្រាប់សហគមន៍កសិកម្ម។ បច្ចុប្បន្ន PMUAC ទទួលបានវិញ្ញាបនបត្រសរីរាង្គ និង SPP ។

ការផ្តល់ហិរញ្ញប្បទានក្នុងការអភិវឌ្ឍ និងថែរក្សាគុណភាពអង្ករ (ការគាំទ្រផ្នែកបច្ចេកទេស ការត្រួតពិនិត្យគុណភាព) ក៏ដូចជាអង្គភាពនានា (សហគមន៍កសិកម្ម PMUAC) អាចធ្វើទៅបានដោយការបែងចែកភាពខុសគ្នារបស់ផលិតផលនៅលើទីផ្សារ ដោយបញ្ចូលតម្លៃបុព្វលាភបន្ថែមលើគុណភាព ហើយជាពិសេស តម្លៃបុព្វលាភបន្ថែមផ្អែកលើមូលដ្ឋានសរីរាង្គ។ អនុវត្តសេដ្ឋកិច្ចមាត្រដ្ឋាន (បណ្តុំធនធានមនុស្សដ៏ច្រើន) ដើម្បីធានាបាននូវនិរន្តរភាពហិរញ្ញប្បទាននេះតាមរយៈទីផ្សារ។ ការចំណាយលើមុខងាររបស់ PMUAC (ជាពិសេសការត្រួតពិនិត្យផ្ទៃក្នុង បុគ្គលិកចំនួន 12 នាក់ ។ល។) ត្រូវបានរ៉ាប់រងទាំងស្រុងដោយប្រើចំណែកតម្លៃបុព្វលាភបន្ថែមផ្អែកលើមូលដ្ឋានសរីរាង្គ (និងដកបុព្វលាភពីការតាំងពិព័រណ៍) ពីការលក់អង្ករ។ ជាចុងក្រោយ គម្រោងនេះបានប្រកាន់យកតួនាទីផ្តល់ជំនួយបច្ចេកទេស ដោយគាំទ្រដល់ការប្រព្រឹត្តទៅរបស់អង្គភាព (មហាសន្និបាត ការប្រជុំ។ល។) ហើយទុកឱ្យកសិករជាអ្នកសម្រេចដោយខ្លួនឯង។

## តួនាទីរបស់សមាជិក Gi អំឡុងពេលដំណើរការអភិវឌ្ឍន៍

Iram និង AVSF បានដើរតួនាទីដ៏សំខាន់ជាអ្នកសម្របសម្រួល និងទីប្រឹក្សា/គ្រូបង្គោលក្នុងដំណើរការទាំងមូល ដោយមិនធ្លាប់ពាក់ព័ន្ធនឹងខ្សែសង្វាក់ផ្គត់ផ្គង់ឡើយ។ ក្រុម AVSF និង Iram បានដើរតួនាទីជាអ្នកសម្របសម្រួលការបង្កើតទំនាក់ទំនងរវាងសហគមន៍កសិកម្ម និងអ្នកទិញជាសក្តានុពល (សម្របសម្រួលកិច្ចប្រជុំពេញអង្គ និងទ្វេភាគី) រួមទាំងគាំទ្រការបង្កើតកិច្ចសន្យាទិញដំបូងផងដែរ។ ក្រៅពីគម្រោង SCCRP ដំបូង AVSF បានបន្តផ្តល់ការគាំទ្រ និងណែនាំដល់ PMUAC នៅពេលដែលជួបប្រទះការលំបាកមួយចំនួន និងជួយដល់សហជីពក្នុងការអភិវឌ្ឍខ្លួន ជាពិសេសការត្រួតពិនិត្យផ្ទៃក្នុង និងទិដ្ឋភាពពាណិជ្ជកម្ម។ ស្ថាប័ននេះអនុញ្ញាតឱ្យមានការគាំទ្រដល់ការច្នៃបង្កើតផលិតផលថ្មីៗ ដូចជាការលក់អង្ករសរីរាង្គ និងវេចខ្ចប់ដោយសហគមន៍កសិកម្មខ្លួនឯង ការបន្ថែមពេលវេលាធ្វើការរបស់និយោជិតដែលអាចរកបាននៅក្រៅរដូវកាល និងលើកកម្ពស់ដំណាំផ្សេងទៀតដែលដាំដុះដោយកសិករជាសមាជិក (ឧ. សណ្តែកដី)។

## លទ្ធផលគម្រោង និងផលប៉ះពាល់

- PMUAC៖ សហភាពសហគមន៍កសិកម្មដំបូងគេដែលបានចុះបញ្ជីនៅកម្ពុជា មានសហគមន៍កសិកម្មជាសមាជិកពី 5 ទៅ 25 ក្នុងរយៈពេល 10 ឆ្នាំ។
- អង្ករជាមធ្យមចំនួន 9,600 តោន ត្រូវបានលក់ជារៀងរាល់ឆ្នាំ ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ។
- គុណភាពកាន់តែប្រសើរឡើង ដោយមានជំនួយពី PMUAC ក្នុងការប្រមូលម៉ាស៊ីនច្រូត។
- ការធ្វើពិពិធកម្មអ្នកទិញ (អ្នកនាំចេញអង្ករចំនួ5)។
- ការអភិវឌ្ឍផ្ទៃក្នុង PMUAC នូវសមត្ថភាពបច្ចេកទេស និងការគ្រប់គ្រងល្អ ធនធានមនុស្សមានស្ថិរភាព។
- កម្រិតតម្លៃបុព្វលាភបន្ថែមផ្អែកលើមូលដ្ឋានសរីរាង្គដែលរកបាន មានចំនួនគ្រប់គ្រាន់ដើម្បីលើកកម្ពស់ប្រាក់ចំណូលរបស់អ្នកផលិត និងផ្តល់ហិរញ្ញប្បទានសហគមន៍កសិកម្ម និង PMUAC រួមទាំងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

## កត្តាអនុគ្រោះ និងកត្តាដែនកំណត់នៃកិច្ចអន្តរាគមន៍

### ចំពោះការគ្រប់គ្រងគុណភាព

**កត្តាអនុគ្រោះ**

- វិញ្ញាបនបត្រសរីរាង្គពីការអនុវត្តសរីរាង្គដែលមានស្រាប់នៅក្នុងខេត្ត។
- លក្ខណៈទ្រង់ទ្រាយធំសម្រេចបានដោយខ្សែសង្វាក់ផ្គត់ផ្គង់អង្ករខេត្តព្រះវិហារ អនុញ្ញាតឱ្យមានសេដ្ឋកិច្ចមាត្រដ្ឋាន និងការស្រង់ដើម។
- រយៈពេលអភិវឌ្ឍន៍ដើម្បីនាំចេញអង្ករ៖ ការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ក្រុមហ៊ុនសហគ្រាសកម្ពុជា ( ឧ. AMRU Rice ) ដើម្បីស្វែងរកទីផ្សារដែលមានសមត្ថភាពស្រូបយកអង្ករសរីរាង្គជាច្រើនពាន់តោន។

**កត្តាដែនកំណត់**

- អត្រាគ្រាប់បាក់បែកនៅតែមានកម្រិតខ្ពស់សម្រាប់កសិករដាំស្រូវមួយចំនួន។
- កម្លាំងពលកម្មតិចតួច និងថ្លៃកម្លាំងពលកម្មក្នុងស្រុកខ្ពស់ ( នៅពេលប្រមូលផល លើកដាក់ក្នុងរថយន្ត )។
- ការលំបាកផ្នែកហិរញ្ញវត្ថុសម្រាប់អ្នកផលិតមួយចំនួន ដើម្បីទទួលបានប្រយោជន៍ពីម៉ាស៊ីនច្រូតក្នុងអំឡុងពេលប្រមូលផល។

### ចំពោះការគ្រប់គ្រងអង្គភាព

**កត្តាអនុគ្រោះ**

- មុខងារត្រួតពិនិត្យគុណភាព គឺជាសសរស្តម្ភគ្រឹះក្នុងការបង្កើតសហជីព និងអនុញ្ញាតឱ្យកាត់បន្ថយការចំណាយលើវិញ្ញាបនបត្របានយ៉ាងច្រើន។
- ការរំពឹងទុកជាមុននៅពេលបញ្ចប់គម្រោង៖ ការផ្ទេរតួនាទីគ្រប់គ្រង និងត្រួតពិនិត្យផ្ទៃក្នុងទៅ PMUAC ដើម្បីបង្កើតសមត្ថភាពផ្ទៃក្នុង ឱ្យបានឆាប់រហ័ស។
- ភាពស្មោះត្រង់របស់នាយកសហគមន៍កសិកម្ម ការប្តេជ្ញាចិត្តមុតមាំ និងភាពស្មោះស្ម័គ្ររបស់ក្រុមប្រតិបត្តិការវ័យក្មេងរបស់ PMUAC ។
- ការរក្សាការគាំទ្របច្ចេកទេសរយៈពេលវែងរបស់ AVSF

**កត្តាដែនកំណត់**

- អង្ករផ្កាម្លិះមួយចំនួនមិនត្រូវបានលក់ជាអង្ករសរីរាង្គទេដោយសារខ្វះទីផ្សារ ដូច្នេះត្រូវលក់ដូចធម្មតា។
- សេវា PMUAC ត្រូវធ្វើការពង្រឹង៖ ការផលិតគ្រាប់ពូជសរីរាង្គ ការផ្គត់ផ្គង់ជីសរីរាង្គ។
- ការកសាងសមត្ថភាពក្នុងផ្នែកគ្រប់គ្រង និងរដ្ឋបាលនៅក្នុង ACs ដែលបានជ្រើសរើស។

## មេរៀន និងអនុសាសន៍សំខាន់ៗ

- ផ្តល់ឱ្យអ្នកផលិតនូវស្វ័យភាព ជាមួយនឹងការគាំទ្រក្នុងការកំណត់គោលបំណង និងមុខងារអង្គភាពរបស់ខ្លួនឱ្យបានច្បាស់ មិនមែនជាគោលដៅដោយផ្ទាល់នោះទេ។
- ជៀសវាងការផ្លាស់ប្តូរតួនាទីដែលត្រូវរក្សាទុកនៅពេលផុតអាណត្តិគម្រោង និងរំពឹងទុកជាមុនការផ្ទេរតួនាទី និងមុខងារទៅឱ្យអង្គភាព។

# គាំទ្រការបង្កើតខ្សែសង្វាក់ផ្គត់ផ្គង់ដំបូងឱ្យដំណើរការប្រកបដោយនិរន្តរភាពនៅក្នុងវិស័យថាមពលក្នុងស្រុក

## ព័ត៌មានសាវតារអំពីករណីសិក្សា

- 2003-2013៖ គាំទ្រការផលិត និងចែកចាយផ្ទះកែច្នៃនៅក្នុងប្រទេសកម្ពុជា។
- គម្រោង SEFED (គាំទ្រការបង្កើតខ្សែសង្វាក់ផ្គត់ផ្គង់ដំបូងឱ្យដំណើរការប្រកបដោយនិរន្តរភាពនៅក្នុងវិស័យថាមពលក្នុងស្រុក)៖ គាំទ្រការបង្កើត និងលើកទឹកចិត្តដល់ភាគីពាក់ព័ន្ធក្នុងស្រុកដែលចូលរួមក្នុងការផលិត និងចែកចាយចង្ក្រានប្រណីត និងជីវឥន្ធនៈប្រកបដោយនិរន្តរភាព។
- រយៈពេលអនុវត្ត៖ 2016-2019; ម្ចាស់ជំនួយធំ៖ AFD
- ទីតាំង៖ ខេត្តកំពង់ឆ្នាំង
- ដៃគូអនុវត្តក្នុងស្រុក៖ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CIRD)

## ការបង្ហាញខ្សែសង្វាក់តម្លៃ និងអង្គភាពដែលភ្ជាប់មកជាមួយ

- ភាគីពាក់ព័ន្ធ (អ្នកទទួលផលគម្រោង)៖ អ្នកផលិត និងអ្នកចែកចាយចង្ក្រាន
- ផលិតកម្ម៖ គំរូចង្ក្រានប្រណីតពីបីទៅប្រាំ
- ហាងលក់ទំនិញ៖ ទីផ្សារអ្នកប្រើប្រាស់ក្នុងខេត្តកំពង់ឆ្នាំង ខេត្តផ្សេងៗ និងរាជធានីភ្នំពេញ
- អង្គភាព៖ សមាគមអ្នកលើកកម្ពស់ចង្ក្រានប្រណីតនៅកម្ពុជា (CESPA) ដែលមានគោលបំណងលើកកម្ពស់សមាជិករបស់ខ្លួន (អ្នកផលិត និងអ្នកចែកចាយ) ដែលទទួលបន្ទុកការគ្រប់គ្រងគុណភាព និងអភិវឌ្ឍន៍ទីផ្សារ។ បង្កើតឡើងក្នុងឆ្នាំ 2004 និងចុះបញ្ជីជាសមាគមអន្តរវិជ្ជាជីវៈក្នុងឆ្នាំ 2017 សមាគមមានសមាជិកអ្នកផលិតចំនួន 25 ក្នុងឆ្នាំ 2023 ។

## ការកំណត់លក្ខណៈគុណភាពដែលត្រូវការ និងបញ្ហាសំខាន់ៗចំពោះអ្នកផលិត

### គុណភាពដែលត្រូវការ

- តម្លៃជាប្រាក់ (ឬនិរន្តរភាព/ថ្លៃដើម)៖ ជាកត្តាដ៏ចម្បងបំផុតចំពោះអ្នកទិញ
- ចង្ក្រានសន្សំសំចៃប្រេង កាត់បន្ថយការចំណាយ
- បំភាយផ្សែងតិច
- ចម្អិនអាហារឆាប់រហ័ស
- មានភាពងាយស្រួល និងសុវត្ថិភាព
- ការរចនា "បែបទំនើប" (ទំហំ សម្ភារ)

### បញ្ហាសំខាន់ៗ

- កង្វះជាងជំនាញ កង្វះការបណ្តុះបណ្តាលគ្រប់គ្រាន់
- ភាពមិនទៀងទាត់នៃគុណភាពវត្ថុធាតុដើម (ជាពិសេសដីឥដ្ឋ)
- ការកើនឡើងនូវតម្លៃវត្ថុធាតុដើម
- តម្រូវការខ្ពស់អាចបណ្តាលឱ្យអ្នកផលិតមួយចំនួនមានការធ្វេសប្រហែសពីគុណភាព ដើម្បីបំពេញតាមបរិមាណដែលបានបញ្ជាទិញ។
- ការថែរក្សាគុណភាព និងការផ្តល់ហិរញ្ញប្បទានលើការត្រួតពិនិត្យគុណភាព

## សនិទានភាពនៃកិច្ចអន្តរាគមន៍របស់សមាជិក Gi

ចាប់ពីឆ្នាំ 2004 រហូតដល់ឆ្នាំ 2013 ការផលិត និងចែកចាយចង្ក្រានប្រណីត ទទួលបានការគាំទ្រហិរញ្ញប្បទានកាបូន ពោលគឺកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ទទួលបានឥណទានកាបូន ដើម្បីផ្តល់ហិរញ្ញប្បទានដល់ការផលិត លក់ក្នុងតម្លៃជានាអប្បបរមា ការត្រួតពិនិត្យគុណភាព និងការចែកចាយចង្ក្រានប្រណីត នៅពេលលក់នៅលើទីផ្សារតាមគោលការណ៍ស្ម័គ្រចិត្ត។ បន្ទាប់ពីបញ្ចប់ឥណទានកាបូន និងក្នុងរយៈពេលបីឆ្នាំក្រោយពេលគម្រោងបានដកចេញ (2013-2016) យុទ្ធសាស្ត្រដែលបានអនុម័តដោយ Geres ក្នុងអំឡុងពេលអនុវត្តគម្រោង SEFED គឺអនុវត្តស្លាកលើកកម្ពស់គុណភាពចង្ក្រានប្រណីតនៅលើទីផ្សារ។ តម្លៃនេះត្រូវបានធ្វើសេរីភាវូបនីយកម្ម ដែលមានតម្លៃខ្ពស់ជាងចង្ក្រានធម្មតា ក្នុងគោលបំណងលើកកម្ពស់តម្លៃស្តង់ដារគុណភាពរបស់ខ្លួន។

ការផ្តល់ហិរញ្ញប្បទានដល់ការអភិវឌ្ឍ និងថែរក្សាគុណភាពចង្ក្រានប្រណីត ជាដំបូងធ្វើឡើងដោយបង់ថ្លៃសេវាចូលក្នុងមូលនិធិទាយជ្ជទានបរិស្ថាន (ឥណទានកាបូន) បន្ទាប់មកដោយការបែងចែកភាពខុសគ្នារបស់ផលិតផលនៅលើទីផ្សារជាមួយនឹងតម្លៃបុព្វលាភបន្ថែមលើគុណភាព។ ក្នុងករណីទាំងពីរនេះ ការកំណត់ និងរក្សាឱ្យមានគុណភាព តម្រូវឱ្យមានការបង្កើតរចនាសម្ព័ន្ធគ្រប់គ្រង និងផ្សព្វផ្សាយជាសមូហភាព (CESPA) ដែលអនុញ្ញាតឱ្យអ្នកផលិត និងអ្នកចែកចាយលក់ជាលក្ខណៈបុគ្គល។

## តួនាទីរបស់សមាជិក Gi អំឡុងពេលដំណើរការអភិវឌ្ឍន៍

ចាប់ពីឆ្នាំ 2004 រហូតដល់ឆ្នាំ 2013 Geres បានជានាការគ្រប់គ្រងគុណភាពផ្ទះ និងការអនុវត្តផ្នែកទីផ្សារដោយផ្ទាល់។ នៅពេលចាប់ផ្តើមគម្រោង SEFED ក្នុងឆ្នាំ 2015 Geres បានចាប់ដៃគូសហការជាមួយសមាគមកម្ពុជា CIRD ដើម្បីគាំទ្រដល់សមាគមនេះនៅក្នុងដំណើរការផ្ទេរកម្មសិទ្ធិរបស់អង្គភាពដំបូងគេដែលបានបង្កើតឡើង ពោលគឺ ICoProDac ទៅឱ្យ CESPA ចាប់ពីឆ្នាំ 2017 មក។ CIRD និង Geres បានផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងការរៀបចំអង្គភាពដល់ CESPA ។ នៅឆ្នាំ 2019 Geres បានបញ្ឈប់ការគាំទ្រផ្ទាល់របស់ខ្លួនទាំងស្រុងលើវិស័យនេះ ហើយ CESPA ដែលគ្រប់គ្រងដោយ SNV នៅតែបន្តដំណើរការរហូតដល់បច្ចុប្បន្ន។

## លទ្ធផលគម្រោង និងផលប៉ះពាល់

- ឆ្នាំ 2004-2013៖ ចង្ក្រានប្រណីតជាង 3 លានគ្រឿង ត្រូវបានលក់ មានសមាជិកប្រហែល 300 នាក់ (អ្នកផលិត និងអ្នកចែកចាយ) នៅក្នុងអង្គភាពនេះ។
- ឆ្នាំ 2013-2016៖ តម្លៃមានការប្រកួតប្រជែងជាងមុន ហើយគុណភាពចង្ក្រានបានធ្លាក់ចុះ។
- ចាប់តាំងពីឆ្នាំ 2016 ផលិតផលិតផលចម្រុះដែលសម្របយ៉ាងល្អទៅនឹងបរិបទវប្បធម៌ ពិសេសការអនុវត្តរបស់អ្នកប្រើប្រាស់កម្ពុជានៅក្នុងការធ្វើម្ហូបអាហារ។
- បច្ចុប្បន្ន មានសមាជិកចំនួន 25 នាក់ (អ្នកផលិត) ដែលផលិត និងលក់ចង្ក្រានបីម៉ូតខុសៗចន្លោះពី 500-800 គ្រឿងក្នុងមួយខែ កាន់តែមានប្រណីតភាព។
- ការប្រកួតប្រជែងខ្លាំង មានការលំបាកក្នុងការបង្កើនភាពខុសប្លែកពីគេ។ អ្នកចែកចាយមានការស្ទាក់ស្ទើរក្នុងការដំឡើងតម្លៃទិញទៅឱ្យអ្នកផលិត។
- គំនិតផ្តួចផ្តើមពីអ្នកផលិតទៅកាន់អ្នកប្រើប្រាស់។

## កត្តាអនុគ្រោះ និងកត្តាដែនកំណត់នៃកិច្ចអន្តរាគមន៍

| កត្តាអនុគ្រោះ | កត្តាដែនកំណត់ |
|---|---|
| **ចំពោះការគ្រប់គ្រងគុណភាព** | |
| • ជំនួយបច្ចេកទេសរយៈពេលវែង ការគាំទ្រផ្នែកបណ្តុះបណ្តាល ពាណិជ្ជកម្ម និងនវានុវត្តន៍ (លើសពី 10 ឆ្នាំ)៖ ជាការរួមចំណែកយ៉ាងខ្លាំងដល់ការកសាងសមត្ថភាពរយៈពេលវែង។<br>• ការបង្កើតរចនាសម្ព័ន្ធសមូហភាពអនុញ្ញាតឱ្យមានការគ្រប់គ្រងគុណភាពតាមរយៈមន្ទីរពិសោធន៍ ការអភិវឌ្ឍផ្នែកទីផ្សារ។ | • ការចំណាយលើការគ្រប់គ្រងគុណភាព មិនត្រូវបានគិតបញ្ចូលក្នុងតម្លៃលក់នៅអំឡុងពេលឥណទានកាបូន៖ ការខូចតម្លៃពិបាកស្រោចស្រង់មកវិញនៅពេលឈានទៅដំណាក់កាលទីផ្សារ។<br>• កង្វះចំណេះដឹង និងការត្រួតពិនិត្យលើការអភិវឌ្ឍផ្នែកទីផ្សារ។<br>• ស្លាកត្រូវបានគេយល់ឃើញថាជាឧបសគ្គ (តម្រូវឱ្យអ្នកផលិតបង់ប្រាក់) ជាជាងឧបករណ៍ដែលខុសប្លែកពីគេ៖ មានការពិបាកក្នុងការផ្លាស់ប្តូរគំរូ។<br>• ការខ្វែងគំនិតគ្នារវាងអ្នកផលិតលើគុណភាពដែលបានកំណត់ និងគុណភាពដែលបានផលិត។ |
| **ចំពោះការគ្រប់គ្រងអង្គភាព** | |
| • ការស្វែងរកគុណភាពពិសេស និងណែនាំការគ្រប់គ្រងគុណភាព៖ ការរួមបញ្ចូលគ្នា និងរៀបចំរចនាសម្ព័ន្ធជាតុផ្សំនៃអ្នកផលិត។<br>• អង្គភាពមានទីតាំងនៅជិតបំផុតនឹងសមាជិករបស់ខ្លួន។<br>• ការគាំទ្រពីដៃគូអភិវឌ្ឍន៍ដូចជា Geres និង SNV៖ ការកសាងសមត្ថភាពក្នុងការគ្រប់គ្រង។ | • ការត្រួតពិនិត្យគុណភាពរយៈពេលយូរដែលធានាបានតាមរយៈ Geres៖ ពិបាកក្នុងការពង្រឹងសមត្ថភាពរបស់អង្គភាព។<br>• ថ្លៃសេវាដែលប្រមូលដោយ CESPA មិនគ្រប់គ្រាន់ក្នុងការធានាឯករាជ្យភាពផ្នែកហិរញ្ញវត្ថុ និងនិរន្តរភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។ ត្រូវការការគាំទ្រផ្នែកហិរញ្ញវត្ថុពីខាងក្រៅជាបន្តបន្ទាប់។<br>• ការកាត់បន្ថយចំនួនសមាជិកជះឥទ្ធិពលលើសមត្ថភាពក្នុងការស្រោចស្រង់ការចំណាយលើការគ្រប់គ្រងគុណភាព។ |

## មេរៀន និងអនុសាសន៍សំខាន់ៗ

- ជៀសវាងការផ្លាស់ប្តូរជំនួស និងកសាងសមត្ថភាពស្ថាប័ន និងធនធានមនុស្សចាប់ពីដំណាក់កាលដំបូងនៃកិច្ចអន្តរាគមន៍។
- បញ្ចូលការចំណាយលើការគ្រប់គ្រងគុណភាពទៅក្នុងតម្លៃលក់ ក៏ដូចជាការចំណាយលើមុខងារទាំងឡាយដែលត្រូវរក្សាទុកហួសពីរយៈពេលគម្រោង និងបញ្ចូលទៅក្នុងខ្សែសង្វាក់តម្លៃ។
- រំពឹងទុកជាមុននៅពេលបញ្ចប់ការគាំទ្រពីខាងក្រៅ (ឧ. ឥណទានកាបូន) ដើម្បីព្យាករការដាក់លក់នៅលើទីផ្សារ។ បញ្ហាប្រឈមរួមមានការរក្សាគុណភាពផលិតនៅពេលដែលការគាំទ្រទាំងនេះត្រូវបានដកចេញ។
- ពង្រឹងសមត្ថភាពរបស់ដៃគូ ឬអង្គភាពក្នុងស្រុក ដើម្បីធានាបាននូវការត្រួតពិនិត្យគុណភាព។
- គាំទ្រការផ្លាស់ប្តូរគំរូដោយលើកកម្ពស់ការយល់ដឹង និងការបង្ហាញ។
- ការផ្សព្វផ្សាយតាមរយៈវិធីសាស្រ្តស្ម័គ្រចិត្ត (ស្លាក) នៅតែទាមទារឱ្យមានការគាំទ្រពីស្ថាប័នរដ្ឋាភិបាល មជ្ឈមណ្ឌលស្រាវជ្រាវ និងដៃគូអភិវឌ្ឍន៍ ដែលទទួលបានមូលនិធិសាធារណៈសម្រាប់សេវារបស់ខ្លួន។

GRET

# គម្រោងកម្មវិធីធានាដែលមានការចូលរួម សម្រាប់វិញ្ញាបនបត្របន្លែសុវត្ថិភាពក្នុងស្រុក

## ព័ត៌មានសាវតារអំពីករណីសិក្សា

- គម្រោងកសិកម្មពាក់កណ្ដាលប្រព្រលវប្បកម្មសម្រាប់កសិករខ្នាតតូចដោយប្រើសម្ភារតិច (APICI) គាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធផលិតកម្ម និងទីផ្សារកសិផលដែលមានប្រសិទ្ធភាពខ្ពស់ (ស្រូវអង្ករ ផ្លែឈើ និងបន្លែ មាន់) ដោយគាំទ្រផ្នែកកសិអេកូឡូស៊ី ការចូលទៅកាន់ទីផ្សារ និងរចនាសម្ព័ន្ធអង្គភាពកសិករអាជីព។
- រយៈពេលអនុវត្តៈ ចាប់តាំងពីឆ្នាំ ២០១០ - កំពុងដំណើរការ
- ម្ចាស់ជំនួយធំៗ៖ AFD និង CD92; ទីតាំង៖ ខេត្តសៀមរាប

## ការបង្ហាញខ្សែសង្វាក់តម្លៃ និងអង្គភាពដែលភ្ជាប់មកជាមួយ

- ភាគីពាក់ព័ន្ធ៖ កសិដ្ឋានលក្ខណៈគ្រួសារខ្នាតតូច (អ្នកទទួលផលគម្រោង) អ្នកប្រមូលទិញក្នុងភូមិ អ្នកលក់ដុំ និងអ្នកលក់រាយ សហគមន៍កសិកម្ម អ្នកប្រើប្រាស់។
- ផលិតកម្ម៖ បន្លែ និងគ្រឿងទេសច្រើនប្រភេទដែលផលិតនៅលើរានសួនបន្លែ ឬនៅលើទីវាល។
- ហាងលក់ទំនិញ៖ ផ្សារក្នុងទីប្រជុំជនខេត្តសៀមរាប ផ្សារទំនើបក្នុងខេត្តសៀមរាប ឬរាជធានីភ្នំពេញ ភោជនីយដ្ឋាន
- អង្គភាព៖ សហគមន៍កសិកម្មសុវត្ថិភាពធម្មជាតិ (ECOFARM)។ ទទួលខុសត្រូវក្នុងការប្រមូលទិញ និងលក់ផលិតផលរបស់សមាជិក និងរៀបចំប្រព័ន្ធធានាដែលមានការចូលរួម។ បង្កើតឡើងក្នុងឆ្នាំ 2015 មុនពេលក្លាយជាសហគមន៍កសិកម្មនៅឆ្នាំ 2019 បច្ចុប្បន្នសហគមន៍នេះមានសមាជិកចំនួន 125 ក្នុងនោះ 71 បានចូលរួមនៅក្នុង PGS ។

## ការកំណត់លក្ខណៈគុណភាពដែលត្រូវការ និងបញ្ហាសំខាន់ៗចំពោះអ្នកផលិត

| គុណភាពដែលត្រូវការ | បញ្ហាសំខាន់ៗ |
|---|---|
| • ផលិតផលសុវត្ថិភាពក្នុងស្រុក<br>• ផលិតផលស្រស់ និងរូបរាងល្អ<br>• បរិមាណអប្បបរមាដែលត្រូវការ<br>• ការធ្វើពិពិធកម្មផលិតផល<br>• ការផ្គត់ផ្គង់ទៀងទាត់ (ប្រចាំថ្ងៃ) សេវាដឹកជញ្ជូន | • កសិដ្ឋានលក្ខណៈគ្រួសារខ្នាតតូចមិនអាចផ្គត់ផ្គង់តាមបរិមាណដែលត្រូវការ និងមិនមានផលិតផលចម្រុះតាមតម្រូវការចំពោះបុគ្គលម្នាក់ៗនោះទេ។<br>• តម្រូវការសម្រាប់ការកសាងសមត្ថភាពបច្ចេកទេស រួមទាំងការគ្រប់គ្រងសត្វល្អិត។<br>• ពិបាកក្នុងការរក្សាផលិតកម្មជាប្រចាំពេញមួយឆ្នាំ៖ ការថយចុះទឹកនៅរដូវប្រាំង ទឹកជំនន់នៅរដូវវស្សា។<br>• ចំណេះដឹងតិចតួចអំពីតម្រូវការគុណភាពដើម្បីបំពេញតាមតម្រូវការក្នុងស្រុក និងនីតិវិធីនៃការទិញ។<br>• បញ្ហាលំហូរសាច់ប្រាក់ អ្នកទិញធ្វើការទូទាត់យឺត។<br>• ការប្រកួតប្រជែងជាមួយនឹងការនាំចូលបន្លែពីប្រទេសជិតខាង។ |

## សនិទានភាពនៃកិច្ចអន្តរាគមន៍របស់សមាជិក Gi

ដើម្បីគាំទ្រអ្នកផលិត និងអាចឱ្យពួកគេបំពេញតាមលក្ខខណ្ឌគុណភាព យុទ្ធសាស្ត្ររបស់ Gret ដំបូងឡើយរួមមានការកសាងសមត្ថភាពរបស់កសិករម្នាក់ៗ ដើម្បីកែលម្អប្រព័ន្ធដាំដុះដំណាំរបស់ខ្លួន (ទិន្នផល ការធ្វើពិពិធកម្មផលិតកម្ម ការកាត់បន្ថយសារធាតុគីមី) តាមរយៈការបណ្តុះបណ្តាលបច្ចេកទេសកសិអេកូឡូស៊ី និងការផ្លាស់ប្តូរចំណេះដឹងរវាងអ្នករួមអាជីព ផ្អែកលើបណ្តាញកសិករពិសោធន៍ក្នុងស្រុក។ ក្រោយមក គម្រោងនេះបានគាំទ្រដល់ការរួមបញ្ចូលGroupe initiativesអ្នកផលិត (បន្លែ និងមាន់) បន្ទាប់មកប្រែក្លាយខ្លួនទៅជាសហគមន៍កសិកម្ម ដែលរៀបចំការលក់ជាសមូហភាព ដើម្បីសម្រេចបានទាំងបរិមាណ និងគុណភាពតាមតម្រូវការរបស់ឈ្មួញកណ្តាល និងអ្នកលក់ដុំ ហេតុឈានទៅដល់ការចុះកិច្ចព្រមព្រៀងតាមកិច្ចសន្យាជាមួយភាគីពាក់ព័ន្ធទាំងនេះ និងកំណើនប្រាក់ចំណូលរបស់សមាជិកសហគមន៍កសិកម្មប្រកបដោយនិរន្តរភាព។ ស្ថាប័ននេះក៏បានគាំទ្រដល់អ្នកផលិតមួយចំនួនផងដែរ (អ្នកដែលមានជំនាញ និងដើមទុនដំបូង) ក្នុងការអភិវឌ្ឍវិជ្ជាជីវៈរបស់ឈ្មួញប្រមូលទិញឱ្យទទួលខុសត្រូវក្នុងការប្រមូលទិញផលិតផលរបស់សហគមន៍កសិកម្ម ស្វែងរកទីផ្សារផលិតផល រៀបចំលទ្ធកម្ម និងការផ្តល់ការណែនាំដល់សមាជិក។

ក្នុងការគ្រប់គ្រងគុណភាព ECOFARM បានកំណត់យថាប្រភេទគុណភាពផ្ទៃក្នុងស្របជាមួយនឹងប្រព័ន្ធផលិតកម្ម និងឧបសគ្គរបស់អ្នកផលិត។ ការត្រួតពិនិត្យផ្ទៃក្នុង គឺផ្អែកលើ PGS ដែលជំរុញការចូលរួមពីភាគីពាក់ព័ន្ធជាច្រើននៅជំណាក់កាលផ្សេងៗ រួមមានតំណាងក្រុមអ្នកផលិត-ទីប្រឹក្សាផ្នែកកសិអេកូឡូស៊ី គណៈកម្មាធិការគ្រប់គ្រងសហគមន៍កសិកម្ម ឈ្មួញប្រមូលទិញ អាជ្ញាធរមូលដ្ឋាន (មេភូមិ និងឃុំ) និងអាជ្ញាធរខេត្ត (តំណាងមន្ទីរកសិកម្ម) និងអ្នកប្រើប្រាស់។

## តួនាទីរបស់សមាជិក Gi អំឡុងពេលដំណើរការអភិវឌ្ឍន៍

Gret ផ្តល់ការណែនាំដល់សមាជិក ECOFARM និងគណៈកម្មាធិការរបស់ខ្លួន លើផ្នែកបច្ចេកទេស ទីផ្សារ ទំនាក់ទំនង ផ្នែករៀបចំអង្គភាព ហិរញ្ញវត្ថុ និងការគ្រប់គ្រង។ អង្គការបានគាំទ្រដល់ការរៀបចំស្តង់ដារផ្ទៃក្នុង និងការអនុវត្ត PGS ។ លើសពីនេះ គម្រោង APICI ឧបត្ថម្ភធនលើឧបករណ៍មួយចំនួនដែលប្រើប្រាស់ក្នុងដំណើរការផលិត ដូចជាធុង រានដាំដុះ សម្ភារ/សារធាតុផ្សំថ្នាំកសិកម្ម និងជីកំប៉ុស ។ល។ ចុងក្រោយ អង្គការជួយលើកកម្ពស់ការយល់ដឹងក្នុងចំណោមអាជ្ញាធរសាធារណៈ និងភាគីពាក់ព័ន្ធនៅផ្នែកលំហូរខាងក្រោមនៃខ្សែសង្វាក់តម្លៃក្នុងស្រុក និង គុណភាព ជាពិសេសតាមរយៈការពង្រឹងសមត្ថភាពរបស់ ECOFARM ទាក់ទងនឹងការតស៊ូមតិ និងទំនាក់ទំនងឌីជីថល។

## លទ្ធផលគម្រោង និងផលប៉ះពាល់

- អ្នកផលិតបន្លែសុវត្ថិភាពសរុបចំនួន 71 នាក់ ក្នុងនោះ 45 នាក់អាចផ្គត់ផ្គង់បានពេញមួយឆ្នាំ៖ ការកើនឡើងនូវចំនួនអ្នកទិញ និងបរិមាណ (បន្លែលក់បានប្រហែល 7 តោនក្នុងមួយខែ) ការផ្តល់វិញ្ញាបនបត្រផ្ទៃក្នុង កិច្ចសន្យាជាមួយភាគីពាក់ព័ន្ធនៅផ្នែកលំហូរខាងក្រោម ការលក់នៅលើទីផ្សារប្រចាំសប្តាហ៍។ល។
- តម្លៃបន្លែពិសេសពី 300 ទៅ 500 រៀល/គីឡូក្រាម កាត់បន្ថយថ្លៃដើមផលិតកម្មពី 40% ទៅ 60%។
- ការធ្វើពិពិធកម្មឱកាស៖ ៥០% លើទីផ្សារគុណភាព ១៥% លើទីផ្សារកសិករប្រចាំសប្តាហ៍នៅខេត្តសៀមរាប ២០% នៅលើទីផ្សារលក់ដុំ ១៥% សម្រាប់បុគ្គលឯកជនតាមរយៈ Facebook ។
- ការចុះទស្សនកិច្ចរបស់មនុស្សជាង 900 នាក់ (អ្នកផលិត តំណាងសហគមន៍កសិកម្ម និស្សិត អាជ្ញាធររដ្ឋាភិបាល) ទៅកាន់ ECO FARM ដើម្បីសង្កេតមើលការអនុវត្តផលិតកម្ម និងធ្វើបទបង្ហាញ PGS។
- ពង្រឹងសមត្ថភាពរបស់អ្នកផលិត ក្នុងការផលិត និងស្វែងរកទីផ្សារផលិតផលសុខភាពក្នុងស្រុក។

## កត្តាអនុគ្រោះ និងកត្តាដែនកំណត់នៃកិច្ចអន្តរាគមន៍

| កត្តាអនុគ្រោះ | កត្តាដែនកំណត់ |
|---|---|
| **ចំពោះការគ្រប់គ្រងគុណភាព** | |
| • ទិន្នផល និងស្តង់ដារស្របទៅនឹងប្រព័ន្ធបច្ចុប្បន្ន មិនតម្រូវឱ្យមានការកែប្រែជាដុំកំភួននោះទេ។<br>• ការបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងស្របទៅនឹងប្រព័ន្ធផលិតកម្មរបស់កសិករ និងទទួលស្គាល់ដោយភាគីពាក់ព័ន្ធនៅផ្នែកលំហូរខាងក្រោម។<br>• ការផ្លាស់ប្តូរព័ត៌មានជាទៀងទាត់រវាងអ្នកផលិត ដើម្បីចែករំលែកបទពិសោធន៍ ការគាំទ្រពីទីប្រឹក្សាផ្នែកកសិអេកូឡូស៊ី។<br>• អ្នកផលិតដែលមានទំនាក់ទំនងផ្ទាល់ជាមួយឈ្មួញកណ្តាល និងអ្នកលក់ដុំ ធ្លាប់មានបទពិសោធន៍ផ្នែកទីផ្សារ/ពាណិជ្ជកម្ម។<br>• ការចូលរួមរបស់អាជ្ញាធរមូលដ្ឋាននៅក្នុងកម្មវិធី PGS ដើម្បីលើកកម្ពស់ការទទួលស្គាល់កម្មវិធី (ជាពិសេសមន្ទីរកសិកម្មខេត្ត)។<br>• កម្មវិធី PGS ចំណាយអស់តិចបើធៀបនឹងកិច្ចអន្តរាគមន៍របស់ភាគីទីបី (ជាចម្បងទាមទារនូវពេលវេលារបស់គណៈកម្មាធិការផ្ទៃក្នុងដើម្បីធ្វើការត្រួតពិនិត្យ)។ | • ពេលវេលាធ្វើការច្រើនក្នុងការផលិតបន្លែសុវត្ថិភាព និង/ឬសរីរាង្គ បើធៀបនឹងបន្លែធម្មតា។<br>• ខ្វះខាតគ្រាប់ពូជបន្លែដែលមានគុណភាព។<br>• ការប្រមូលផ្តុំភាគីពាក់ព័ន្ធដើម្បីចូលរួមដំណើរទស្សនកិច្ចប្រចាំឆមាស ឬប្រចាំឆ្នាំដែលនៅតែជាបន្ទុករបស់ Gret (អាជ្ញាធរមូលដ្ឋាន មន្ទីរកសិកម្មខេត្ត)។<br>• ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុតិចតួច និងមិនសូវញឹកញាប់ (ប្រចាំឆ្នាំ) សម្រាប់គណៈកម្មាធិការត្រួតពិនិត្យ។ |
| **ចំពោះការគ្រប់គ្រងអង្គភាព** | |
| • ផលប្រយោជន៍សេដ្ឋកិច្ចរបស់អ្នកផលិត (តម្លៃពិសេស)។<br>• អង្គភាពមូលដ្ឋានបង្កើតឡើងនៅក្នុងសហគមន៍ដែលមានស្រាប់ (ការគ្រប់គ្រងសង្គម និងបទប្បញ្ញត្តិ)។<br>• អ្នកផលិតមានសមត្ថភាព និងបទពិសោធន៍ក្នុងតួនាទីគ្រប់គ្រង។ | • សហគមន៍កសិកម្មមិនមានលទ្ធភាពបង់ប្រាក់ឈ្នួលបុគ្គលិក៖ ពឹងផ្អែកលើអ្នកផលិតដែលទទួលបានការលើកទឹកចិត្ត និងមានសមត្ថភាព។ |

## មេរៀន និងអនុសាសន៍សំខាន់ៗ

- PGS ផ្តោតលើភាពចម្រុះ និងលើកទឹកចិត្តដល់កសិករខ្នាតតូច ដែលអនុញ្ញាតឱ្យពួកគេបង្កើតប្រព័ន្ធជំរុញនៅក្នុងមូលដ្ឋាន និងមានភាពបត់បែនខ្លាំង ដើម្បីបំពេញតម្រូវការបុគ្គល។
- PGS អនុញ្ញាតឱ្យកសិករទទួលបានប្រាក់ចំណូលខ្ពស់ ដោយផលិតអាហារដែលមានឥទ្ធិពលវិជ្ជមានមកលើសុខភាពមនុស្ស ការអប់រំ និងបញ្ហាបរិស្ថាន។
- PGS បានកាត់បន្ថយតម្រូវការពលកម្មចំណាកស្រុកដោយបង្កើនប្រាក់ចំណូល និងបំពេញតម្រូវការពលកម្មក្នុងស្រុកជាទៀងទាត់។



©Jean-Marie Brun (ARTE-FACT)

ការប្រមូលទិញស្រូវសេរីរាង្គក្នុងសហគមន៍កសិកម្មជាសមាជិក PMUAC ក្នុងខេត្តព្រះវិហារ

# កំណត់សម្គាល់

## សេចក្តីសង្ខេប

មានសក្តានុពលការងារជាច្រើនដែលត្រូវធ្វើការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា រាប់ចាប់ពីកសិកម្មទ្រង់ទ្រាយធំដែលត្រូវការដើមទុនច្រើន រហូតដល់ការផលិតជាលក្ខណៈគ្រួសារ និងការប្រែក្លាយគំរូប្រើប្រាស់ដីដែលមានដីជាតិតាមវិធីដែលមិនមាននិរន្តរភាព ទៅជាប្រព័ន្ធកសិអេកូឡូស៊ីដែលមាននិរន្តរភាព។ ការអនុវត្តកន្លងមករបស់កសិដ្ឋានលក្ខណៈគ្រួសារមួយចំនួន បានជួបបញ្ហាប្រឈមក្នុងការរក្សានិរន្តរភាព ប៉ុន្តែប្រឈមមុខនឹងការខ្វះខាតការទទួលស្គាល់ ជាពិសេសក្នុងចំណោមភាគីពាក់ព័ន្ធនៅផ្នែកលំហូរខាងក្រោមនៃខ្សែសង្វាក់តម្លៃ។ ក្នុងបរិបទនេះ សមាជិក Gi ប្រចាំកម្ពុជា (Agrisud International, APDRA, AVSF, Geres, Gret, Iram) បាននិងកំពុងគាំទ្រការធ្វើសមាហរណកម្មកសិករ និងសិប្បករជាលក្ខណៈគ្រួសារទៅក្នុងបណ្តាញផ្គត់ផ្គង់ក្នុងមូលដ្ឋាន នៅថ្នាក់ជាតិ និងអន្តរជាតិ អស់រយៈពេលជាច្រើនឆ្នាំមកហើយ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការចែករំលែកតម្លៃរបស់ខ្លួន និងរួមចំណែកដល់ការបង្កើនប្រាក់ចំណូល និងកម្រិតជីវភាពរស់នៅរបស់ខ្លួន។

សម្របសម្រួលដោយ

iram

49 rue de la Glacière
75013 ប៉ារីស
បារាំង
www.iram-fr.org

វិទ្យាស្ថានស្រាវជ្រាវ និងអនុវត្តវិធីសាស្ត្រអភិវឌ្ឍន៍ (Iram) បានធ្វើការក្នុងវិស័យអភិវឌ្ឍន៍អន្តរជាតិចាប់តាំងពីឆ្នាំ 1957។ គោលបំណងរបស់វិទ្យាស្ថាន គឺដើម្បីលើកកម្ពស់ការកាត់បន្ថយវិសមភាពសង្គមក្នុងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដោយរួមបញ្ចូលគ្នានូវជំនាញឯករាជ្យ ប្រកបដោយគុណភាពខ្ពស់ជាមួយនឹងគោលការណ៍ សីលធម៌ និងការប្តេជ្ញាចិត្តដ៏រឹងមាំ។ វិទ្យាស្ថានបានធ្វើសកម្មភាពនៅនឹងមូលដ្ឋានដោយសហការជាមួយបណ្តាដៃគូក្នុងស្រុកនៅគ្រប់ដំណាក់កាលនៃវដ្តគម្រោងរាប់ចាប់ពីការកំណត់អត្តសញ្ញាណជាមុនរហូតដល់ការអនុវត្ត និងពីការស្រាវជ្រាវរហូតដល់ការវាយ



អ្នកផលិតជាសមាជិក PMUAC ប្រមូលផលស្រូវដោយដៃ

## សេចក្តីសង្ខេប

បង្កើតឡើងក្នុងឆ្នាំ 1993 "កម្មវិធីគំនិតផ្តួចផ្តើម Groupe initiatives" (Gi) គឺជាបណ្តុំសមាគមសាមគ្គីភាពអន្តរជាតិជំនាញមួយផ្អែកតាមការសន្និដ្ឋាន "ថា [សមាជិកទាំងអស់] នឹងសម្រេចបានវឌ្ឍនភាពប្រសើរជាងការធ្វើការដាច់ដោយឡែកពីគ្នា ហើយ [ពួកគេ] អាចជម្នះលើការខ្វែងគំនិតគ្នា [ក្នុងចំណោមពួកគេ] និងការប្រកួតប្រជែង [ក្នុងចំណោមពួកគេ] ដោយកំណត់បញ្ហាប្រឈម និងគោលដៅរួម" (សូមមើលសេចក្តីថ្លែងការណ៍របស់ Gi)។

បច្ចុប្បន្ន សមាគមមានអង្គភាពចំនួន 15 ជាសមាជិក។ ទំនាក់ទំនងសមូហភាពប្រកបដោយសក្តានុពល បានបង្ហាញពីឆន្ទៈរួមរបស់សមាជិក ដែលបញ្ជាក់យ៉ាងច្បាស់ពីតម្លៃ និង វិធីសាស្ត្រជាក់លាក់របស់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងវិសមភាព ដើម្បីទទួលបានលំនៅឋានសមរម្យ សិទ្ធិសេដ្ឋកិច្ច សង្គម និងសិទ្ធិវប្បធម៌ និងផ្នែកសាមគ្គីភាពអន្តរជាតិ។

"*គំនិតផ្តួចផ្តើម Groupe initiatives*" គឺជាវេទិកាមួយសម្រាប់ការផ្លាស់ប្តូរ ក៏ដូចជាចែករំលែកបទពិសោធន៍ និងការអនុវត្តផ្សេងៗ សំដៅជំរុញឱ្យមានការពិចារណាពីសំណាក់ភាគីពាក់ព័ន្ធនឹងវិស័យសាមគ្គីភាពអន្តរជាតិ និងបង្កើតអនុសាសន៍ក្នុងវិស័យគោលនយោបាយសាធារណៈ។

AGRISUD INTERNATIONAL

APDRA PISCICULTURE PAYSANNE

AVSF AGRONOMES & VÉTÉRINAIRES SANS FRONTIÈRES

GRET

Ciedel

ESSOR Soutien - Formation - Réalisation Association de Solidarité Internationale

geres LA SOLIDARITÉ CLIMATIQUE EN ACTION

SEVES

grdr Migration - Citoyenneté - Développement

iram

inter aide Lancement et suivi de programmes concrets de développement

Solthis Solidarité Thérapeutique et Initiatives pour la Santé

CRAterre

iD* INITIATIVE DÉVELOPPEMENT DES PROJETS SOLIDAIRES

LE PARTENARIAT Une coopération à taille humaine

Graphic design: Terre Nourricière - 200 copies - December 2023

Groupe initiatives

45 bis, avenue de la Belle Gabrielle
94 736 Nogent-sur-Marne
contact@groupe-initiatives.org

**www.groupe-initiatives.org**